# សរសេរតាមសូត្រ

# ពន្យល់



ជឹង · ជួងហួត

បណ្ណាគារ ជឹង - ជួងហួត លេខ២៣១

វិថីសម្តេចសង្ឃនាយក ស៊ុក ភ្នំពេញ

បោះពុម្ពផ្សាយ

តម្លៃ ២៥ រៀល

CA12

# សរសេរតាមសូត្រ
# ពន្យល់

សម្រាប់រៀនសរសេរពាក្យខ្មែរឲ្យបានត្រឹមត្រូវ

រឿងសម្រាប់ហាត់សរសេរ, ពាក្យពន្យល់

ដោយ

លោក ជា-ទង់

សាស្ត្រាចារ្យ នៅពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត

បោះពុម្ពលើកទី ៤

ព.ស. ២៥០២ – គ.ស. ១៩៥៩

# បញ្ជីរឿង


| | |
|---|---|
| សេចក្ដីផ្ដើម | ង |
| អក្សរសង្ខេប | ឆ |
| ពាលទីនបណ្ឌិត | ១ |
| ព្រះពុទ្ធសាសនា | ៤ |
| ការសិក្សា | ៧ |
| វិជ្ជាជាទ្រព្យគាប់ប្រសើរ | ៩ |
| នគរវត្ត | ១១ |
| វត្តឧណ្ណាលោម | ១៣ |
| ក្រុងលង្វែក | ១៦ |
| បកករកថា | ២០ |
| រឿងមច្ឆរិយកោសិយសេដ្ឋី | ២៣ |
| រឿងអានន្ទសេដ្ឋី | ២៧ |
| រឿងអានន្ទសេដ្ឋី (ត) | ២៩ |
| រឿងអានន្ទសេដ្ឋី (តនឹងចប់) | ៣១ |

| | |
|---|---|
| ព្រះរាជពិធីតាំងតុ | ៣៣ |
| ព្រះពុទ្ធ | ៣៩ |
| ប្រជាធិបតេយ្យ | ៤៤ |
| រឿងព្រះបាទធម្មាសោករាជ | ៤៧ |
| ក្រុងភ្នំពេញ | ៥១ |
| ទន្លេមេគុង | ៥៣ |
| ទោសនៃសេចក្ដីខ្ជិល | ៥៦ |
| សេចក្ដីព្យាយាម | ៥៩ |
| ចិត្តជាទេវទត្តមាត់ជាទេវតា | ៦៣ |
| ការស្វែងរកទីពឹង | ៦៦ |
| មេត្តាព្រហ្មវិហារ | ៦៩ |
| រឿងនាងវិសាខា | ៧១ |
| ក្រុងឧដុង្គមានជ័យ | ៧៦ |
| រឿងបុឡ្យធនគុហបណ្ឌិត | ៨៨ |

—គ—


| | |
|---|---|
| ចាប់នេះចាប់នោះមិនឆ្ពោះត្រង់ណា (កាព្យ) | ៨៣ |
| រឿងចូឡធនុគ្គហបណ្ឌិត (កាព្យ) | ៨៥ |
| រឿងចូឡធនុគ្គហបណ្ឌិត (កាព្យ) (ត) | ៨៩ |
| រឿងចូឡធនុគ្គហបណ្ឌិត (តនឹងចប់) | ៩១ |
| ដំបូន្មាន (ពាក្យកាព្យ) | ៩៤ |
| រឿងពោធិរាជកុមារ | ៩៥ |
| រឿងអ្នកស្រែល្ងង់នឹងសត្វស្វា | ៩៩ |
| ព្រះរាជបុត្រដែលគួរគ្រងរាជសម្បត្តិ | ១០៣ |
| សិលាប្រាសាទនឹងខ្មែរបុរាណ | ១០៧ |
| រឿងច្មើរព្រៃម្នាក់ | ១១០ |
| រឿងបងប្អូនបីនាក់ | ១១៦ |
| រឿងព្រាហ្មណ៍ទុគ៌ត | ១១៩ |
| រឿងព្រាហ្មណ៍ទុគ៌ត (តចប់) | ១២៣ |
| រឿងខ្លាចាស់ចាំសីល | ១២៦ |

រឿងខ្លាចាស់ចាំសីល (ត) ១២៨

រឿងខ្លាចាស់ចាំសីល (ត) ១៣០

រឿងខ្លាចាស់ចាំសីល (ត) ១៣៣

រឿងខ្លាចាស់ចាំសីល (តនឹងចប់) ១៣៥

រឿងព្រះបាទតុង្គិពលរាជ ១៣៧

រឿងព្រះបាទតុង្គិពលរាជ (ត) ១៣៩

រឿងព្រះបាទតុង្គិពលរាជ (ត) ១៤១

រឿងព្រះបាទតុង្គិពលរាជ (តនឹងចប់) ១៤៤

សេចក្តីសរសើរព្រៃខមមិគទាយពន ១៤៦

# សេចក្ដីផ្ដើម

សៀវភៅ **សរសេរតាមសូត្រ ពន្យល់** នេះជាសៀវភៅរៀន សម្រាប់រៀនសរសេរតាមសូត្រខ្មែរ ឲ្យបានត្រឹមត្រូវ, ជាសៀវភៅថ្មី កើតឡើង អាស្រ័យដោយហេតុថា អ្នកសិក្សាមិនទាន់មានសៀវភៅបែបនេះនឹងសិក្សានៅឡើយ ជាហេតុនាំឲ្យលំបាកក្នុងការរៀនសរសេរតាមសូត្រខ្មែរ ឲ្យបានត្រឹមត្រូវក្រៃពេក ។ ហេតុនេះ ខ្ញុំយល់ថា គួរតែបង្កើតសៀវភៅបែបនេះឡើង ដើម្បីនឹងឲ្យអ្នកសិក្សាងាយនឹងរៀនសរសេរតាមសូត្រ ។ រីឯរឿងសម្រាប់រៀនសរសេរនីមួយ ៗ នោះសោតក៏គួរតែដកស្រង់យកពាក្យដែលជ្រាលជ្រៅ ឬ ដែលជាពាក្យបាលីនិងសំស្ក្រឹត មកអធិប្បាយពន្យល់ឲ្យអ្នកសិក្សាយល់ក្នុងចិត្តជឿជាក់ជាអាទិថា ពាក្យនេះមានសេចក្ដីអធិប្បាយយ៉ាងនេះ ត្រូវសរសេរដូច្នេះទើបត្រូវ ឯពាក្យនោះត្រូវសរសេរដូច្នោះ ព្រោះមានន័យយ៉ាងនោះ ។ ខ្ញុំយល់ទៀតថា បើបានសៀវភៅនេះកើតឡើង មុខជានឹងមានប្រយោជន៍ច្រើនដល់អ្នកសិក្សា គ្រប់ជាន់គ្រប់ថ្នាក់ ទើបក្នុងឱកាសវិស្សមកាល២ខែ គឺខែមីនានិងមេសាឆ្នាំ១៩៥២នេះ ខ្ញុំបានឆ្លៀតរៀបរៀងបង្កើតជាសៀវភៅនេះឡើង ដោយនឹកសង្ឃឹមថា មុខជានឹងបានជាទីពេញចិត្តនៃអ្នកសិក្សាតទៅពុំខាន។

បើអ្នកសិក្សាបានរៀនសរសេរតាមសូត្រ ហើយយល់ពាក្យក្នុងរឿងដែលសរសេរនោះច្បាស់លាស់តាមរបៀបក្នុងសៀវភៅនេះ តាំងពីទំព័រ ១ ដល់ទំព័រ–១៤៩ ហើយ មុខជានឹងបានកក់ក្ដៅ មិនសូវធ្ងន់ចិត្តក្នុងពេលប្រឡងម្ដង ៗ ឡើយ ព្រោះរឿងដែលធ្លាប់ប្រឡងជាញយ ៗ ដោយច្រើន ក៏មានក្នុងសៀវភៅនេះ ។ ដូច្នេះអ្នកសិក្សាគ្រប់រូបគួរតែមានសៀវភៅនេះជាគូមិត្រយ៉ាងស្និទ្ធមួយថែមទៀតដើម្បីឲ្យមិត្រថ្មីនេះជួយទុក្ខធុរៈ ខាងពន្យល់ពាក្យសរសេរតាមសូត្រ ដែលពិបាក ឬដែល

ជ្រាលជ្រៅ ព្រោះថា ការដែលគ្រាន់តែខស្សាហ៍សរសេរប៉ុណ្ណោះ ហើយមិនយល់ពាក្យក្នុងផ្ទៃរឿងដែលសរសេរនោះឲ្យជាក់ប្រាកដចូលចិត្តស៊ប់ផងទេពាក្យដែលធ្លាប់សរសេររឿយ ៗ ហើយនោះ អាចនឹងភ្លេចភ្លាំងភ័ន្តប្រឡំដោយឆាប់រហ័សពុំខាន ។

ហេតុនេះ ខ្ញុំសូមឧទ្ទិសសៀវភៅសរសេរតាមសូត្រ ពន្យល់ នេះ ចំពោះសិក្ខាកាម (អ្នកត្រូវការនឹងសិក្សា) ទាំងឡាយ សូមឲ្យបានចំរើនល្អគណាស់ដោយការសិក្សាគរៀនទៅ ! ។

*ថ្ងៃពុធ ៧ កើតខែពិសាខ ឆ្នាំរោងចត្វាស័ក ព.ស. ២៤៩៥*

*ត្រូវនឹងថ្ងៃទី ៣ មេសា ១៩៥២*

*ជា-ទន់*

*សាស្ត្រាចារ្យនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត*

# សរសេរតាមសូត្រ

# ពន្យល់

# អក្សរសង្ខេប

ដែលប្រើក្នុងសៀវភៅសរសេរតាមសូត្រ ពន្យល់ នេះ

| | | |
|---|---|---|
| កិ. | គឺ | កិរិយាសព្ទ |
| កិ. វិ. | " | កិរិយាវិសេសន៍ |
| គុ. | " | គុណសព្ទ |
| ន. | " | នាមសព្ទ |
| និ. | " | និបាតសព្ទ |
| ម. | " | មគធភាសា |
| រ. ស. | " | រាជសព្ទ |
| សំ. | " | សំស្រ្កឹត |
| អ. បិ. | " | អានថា (ត្រូវ) អានថា |

# ពាលនិងបណ្ឌិត

ដែលហៅថាមនុស្សពាល គឺមនុស្សទុជ៌ន ដែលប្រកបដោយបាបចិត្តជាអនេកប្បការ ជាមនុស្សអប្រិយ អបលក្ខណ៍ ជាអធម្មិកអាក្រក់ទាំងឫកទាំងមារយាទ ឃ្លាតចាកសុចរិតធម៌ រីកវៃតែក្នុងអសប្បុរិសធម៌ ជាអ្នកបង្កហេតុនៃកុប្បកម្ម ឲ្យមានជាទិរន្តរ៍ក្នុងប្រទេស ករណីយកិច្ចរបស់មនុស្សពាល គ្រប់ទិវារាត្រីច្រើនតែជាបទុច្ចរិត ពួកជនអ្នកធម្មគោរព ដែលមានប្រីជាអាចដឹងបានដោយប្រត្យក្ស ថាមនុស្សពាលទាំងនោះបានប្រព្រឹត្តធ្វើកិច្ចការទាំងឡាយ សុទ្ធតែជាពាលលក្ខណ៍អាចដឹកនាំអ្នកដែលមានចិត្តស្ម័គ្រស្មាគមជាមួយ ឲ្យទទួលទុក្ខព្រួយជាប្រាកដ ។

ហេតុនេះ កុលបុត្ត កុលធីតា ដែលប្រាថ្នាចង់បានសុខធម៌និងវឌ្ឍនធម៌ គប្បីជៀសវាងមនុស្សពាលទុជ៌នទាំងនោះហើយត្រូវគប់រកពួកជនជាបណ្ឌិត ដែលមានគំនិតដ៏ប្រសើរ មានអធ្យាស្រ័យដ៏បរិសុទ្ធ ព្រមទាំងមានសន្តានចិត្តបេះសន្តោស មិនស្វែងរកទោសមិត្តភក្តិគ្នា មិនដំឡើងអស្មិមានះ ប្រមាថ

មើលងាយផងឯទៀត  បេះគេក្រាសេចក្ដីសុខរវាងញាតិមិត្រមិនឲ្យបែកបាក់  ព្រោះពួកបណ្ឌិតនោះ  អាចដឹកនាំអ្នករួមរួមជាមួយឲ្យទទួលការបដិវត្តន៍ គឺផ្លាស់ឋានៈពីមូឡ្ហភាពទៅជាបណ្ឌិតភាព  ពីទុក្ខភាពទៅជាសុខភាព  ទាំងក្នុងឥធលោក  ទាំងក្នុងបរលោក ។

## ពន្យល់ពាក្យ

ពាល ន. មនុស្សល្ងង់ខ្លៅ ឬ មនុស្សកាចអាក្រក់ ។ បណ្ឌិត អ្នកដែលចេះដឹង, អ្នកប្រាជ្ញ ។ ទុជ៌ន (អ. ថ. ទុរៈជិន) ន. ជនអាក្រក់, ជនចិត្តអាក្រក់ ។ អនេកប្បការ (អ. ថ. អៈណេក័ប ប៉ៈ ៣) គុ. ដែលមានប្រការច្រើន ។ អប្រិយ (អ. ថ. អ័បប្រី) គុ. ដែលមិនជាទីស្រឡាញ់, ដែលពុំគួរស្រឡាញ់ ។ អបលក្ខណ៍ (អ. ថ. អៈប៉ៈឡ័ក) គុ. ដែលប្រាសចាកលក្ខណៈល្អ  គឺដែលឥតលក្ខណ៍,  ហីនលក្ខណ៍,  សរសេរជា អបលក្សណ៍ ក៏បាន ។ អធម្មិក គុ. ដែលមិនប្រកបដោយធម៌ ។ សុចរិតធម៌ ន. ធម៌គឺការប្រព្រឹត្តល្អ ។ អសប្បុរិសធម៌ ន.

ធម៌របស់អសប្បុរស គឺធម៌របស់មនុស្សអ្នកធ្វើអំពើអាក្រក់ដោយកាយ វាចា ចិត្ត ។ កុប្បកម្ម ( អ.ថ. កុប-ប៉ៈ-កាំ ) ន. អំពើនាំឲ្យជ្រួលច្របល់ចលាចល ឬ ភ្ញាក់ផ្អើល ។ និរន្តរ៍ ( អ. ថ. និរ៉ន់ ) ជានិច្ច, ឥតស្រាក, ឥតល្ហែ ។ ករណីយកិច្ច ( អ. ថ. ក រ៉ៈ ណី យ៉ៈ កិច ) ន. កិច្ចដែលត្រូវធ្វើ ។ ទិវារាត្រី ន. ថ្ងៃយប់ ។ ទុច្ចរិត ន. អំពើអាក្រក់ ។ ធម្មគោរិន ន. អ្នកល្អរស់នៅក្នុងធម៌ ។ ប្រីជា ន. ប្រាជ្ញា ។ ប្រត្យក្ស ( អ. ថ. ប្រត្យ៉ាក់ ) គុ. ពិ ជាក់ច្បាស់, ប្រាកដ ។ ពាលលក្ខណ៍ ( អ. ថ. ពាលៈល័ក ) ន. លក្ខណៈរបស់មនុស្សអាក្រក់ ។ សុខធម៌ ន. ធម៌នាំឲ្យបានសុខ ។ វឌ្ឍនធម៌ ន. សភាវៈនាំឲ្យបានចំរើនលូតលាស់ ។ អស្មិមានៈ ន. សេចក្ដីប្រកាន់ចិត្តរឹងត្អឹងថាមានតែអញមិនព្រមទទួលជឿស្ដាប់ពាក្យអ្នកណា ។ មូឡ្ហភាព ( អ, ថ. មូល-ប៉ៈ ) ន. ភាពជាអ្នកល្ងង់ខ្លៅ ភាពជាអ្នកមមឹងមមាំង ។ ឥធលោក ន. លោកនេះ ។ បរលោក ( អ. ថ. ប៉ៈរ៉ៈលោក ) ន. លោកខាងមុខ ។

# ព្រះពុទ្ធសាសនា

ត្រង់មាត្រា ៨ នៃរដ្ឋធម្មនុញ្ញ កម្ពុជរដ្ឋថា "ព្រះពុទ្ធសាសនា ជា សាសនារបស់រដ្ឋ" ។ ពួកពុទ្ធសាសនិកជនបានដឹងប្រាកដដូច្នេះសឹងមានចិត្តដ៏សម្បយុត្ត ដោយសោមនស្សរៀងនាគ្រប់គ្នា ដោយមានយោនិសោមនសិការៈថា ពលរដ្ឋក្នុងប្រទេសត្រូវមានព្រះពុទ្ធសាសនាទុកជាទីគោរពរាប់អាន នមស្ការបូជាជានិច្ចនិរន្តរ៍ ។ កាលបើដូច្នេះ សីលធម៌, អារ្យធម៌ និងវប្បធម៌ដ៏ឧត្តម តាមគន្លងនៃព្រះបរមពុទ្ធោវាទ នឹងអាចជ្រួតជ្រាបអប់រំក្នុងនិស្ស័យសន្ដានរបស់ពលរដ្ឋគ្រប់គ្នា ព្រោះព្រះពុទ្ធសាសនា តាមជំនឿរបស់ពួកពុទ្ធសាសនិកថា ជាសាសនាមួយដែលមានគតិដ៏ឧត្តមបំផុត អាចញុំាងអ្នកដែលជឿកាន់តាមប្រាកដឲ្យទទួលការបដិវត្តន៍ច្រើនស្ថាន មានការបដិវត្តន៍ពីហីនដ្ឋានទៅជាឧត្តមដ្ឋាន ពីមូឡ្ហភាពទៅជាបណ្ឌិតភាព, ពីទុក្ខភាព

ទៅកាន់សុខភាពជាដើម វៀរលែងតែមនុស្សដែលមិនមែនជាពុទ្ធិកជនពិតប្រាកដនោះ ព្រះពុទ្ធសាសនា មិនអាចនឹងញុំាងមនុស្សនោះឲ្យទទួលការបដិវត្តន៍បាកបកតិភាពបានឡើយ ។

ហេតុនេះ ពុទ្ធមាមកជនទាំងឡាយ ជាបព្វជិតក្តី គ្រហស្ថក្តី គប្បីបណ្តុះបសាទសទ្ធាក្នុងត្រៃរតន៍ ដែលជាមូលដ្ឋាននៃព្រះពុទ្ធសាសនា ហើយឧស្សាហ៍ត្រិះរិះពិចារណាដោយវិចារណញ្ញាណឲ្យយល់នូវអត្ថរសនៃធម្មប្បដិបត្តិដោយបច្ច័ក្ខ ហើយប្រតិបត្តិតាមកុំឲ្យឃ្លៀងឃ្លាត ដើម្បីនឹងបានទទួលនូវលទ្ធផលដែលកើតឡើង ពីពុទ្ធសាសនប្បដិបត្តិ; លទ្ធផលនោះមានគុណានុភាពជួយផ្តល់ឲ្យអ្នកប្រតិបត្តិ បានទទួលនូវយថិច្ឆិតសុខ ក្នុងឥធលោកនិងបរលោក ។

## ពន្យល់ពាក្យ

ពុទ្ធសាសនា ន. សាសនាព្រះពុទ្ធ, ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ ពុទ្ធសាសនិក (អ. ថ. ពុទ្ធ:-សាសៈ និក ន. អ្នកកាន់ពុទ្ធសាសនា ។ សម្បយុត្ត

(អ. ឋ. ស័ម ប៉ះ យុត) កិ. ប្រកបព្រម ។ យោនិសោមនសិការៈ ន. ការពិចារណាដោយឧបាយ, ដោយគំនិត ។ សីលធម៌ ន. សីលនឹងធម៌ ។ អារ្យធម៌ ន. ធម៌ដែលនាំឲ្យកើតសេចក្ដីសុខ-ចំរើន, ធម៌របស់អរិយជន ; សរសេរជា អាយ៌ធម៌ ក៏បាន ។ បរមពុទ្ធោវាទ ន. ឱវាទ ឬដំបូន្មានរបស់ព្រះពុទ្ធ ព្រះអង្គប្រសើរខ្ពង់ខ្ពស់ ។ ពុទ្ធិកជន ន. ជនអ្នកកាប់អានព្រះពុទ្ធ ។ បកតិភាព ន. ភាពប្រក្រតី ។ ពុទ្ធមាមកជន ន. ជនអ្នកកាប់អានព្រះពុទ្ធ ។ បសាទសទ្ធា ន. សេចក្ដីជ្រះថ្លា ។ ត្រៃរ័ត្ន ន. រតនៈ ៣ គឺព្រះពុទ្ធ ព្រះធម៌ នឹងព្រះសង្ឃ ។ ហីនដ្ឋាន ន. ឋានៈថោកទាប ។ ឧត្តមដ្ឋាន ន. ឋានៈខ្ពង់ខ្ពស់ ។ មូលដ្ឋាន ន. ឫសគល់ ។ វិចារណញ្ញាណ ន. ប្រាជ្ញាជាគ្រឿងពិចារណា ។ អត្ថរស ន. រសនៃសេចក្ដី ។ ធម្មប្បដិបត្តិ ន. សេចក្ដីប្រតិបត្តិនូវធម៌ ។ បច្ចក្ខ (អ. ឋ. ប៉ុប-ច័ក) កិ. វិ. ដាក់ច្បាស់, ប្រាកដ ។ លទ្ធផល ន. ផលដែលត្រូវបាន ។ យថិច្ឆិតសុខ (អ. ឋ. យៈថិប-ឆិតៈ-សុខ) ន. សេចក្ដីសុខដែលខ្លួនប្រាថ្នាយ៉ាងណា ។

---

# ការសិក្សា

ការសិក្សា គឺការរៀនសិល្បសាស្ត្រគ្រប់យ៉ាង មានអក្សរសាស្ត្រ, គណិតសាស្ត្រនិងវិទ្យាសាស្ត្រជាដើម ។ ការសិក្សានេះជាសមុដ្ឋាន នៃវឌ្ឍនធម៌និងអារ្យធម៌របស់សិក្ខាកាមជនគ្រប់ប្រទេស ៗ ប្រទេសណាសម្បូណ៌ដោយការសិក្សា ប្រទេសនោះ ទោះបីតូចតាចក្តី ក៏គង់ក្លាយទៅជាប្រទេសមានតម្លៃ អាស្រ័យនឹងជនក្នុងប្រទេសសម្បូណ៌ដោយវិជ្ជាដូចជាប្រទីបផ្កាលា ឥតមានសត្រូវណា នឹងអាចមកប្រមាថពាធាបាន, ប្រទេសណាមិនសម្បូណ៌ដោយការសិក្សា ប្រទេសនោះទោះបីធំយ៉ាងណាក៏ដោយ គង់ឥតមានតម្លៃ ដោយហេតុជនក្នុងប្រទេសនោះ ច្រើនតែងនឹងគិតតែស្វែងរកប្រយោជន៍ផ្ទាល់ខ្លួនបំពេញកិច្ចការស៊ីកមិនសមហេតុផល ៗ

ហេតុនេះ យើងគួរនឹកឃើញដល់ឥស្សរភាពនៃប្រទេសយើងក្នុងបុរាណសម័យ តាមប្រវត្តិសាស្ត្រដល់សព្វថ្ងៃនេះ ហើយត្រូវកុំប្រមាទ គួរខំស្វាហ៍សង្វាតបោះបង់នូវកោសជ្ជភាពចេញ ហើយខំ

ប្រឹងបំពេញការសិក្សាក្នុងវិជ្ជាផ្លូវលោកនិងផ្លូវធម៌ឲ្យបានគ្រប់គ្រាន់ ដើម្បីនឹងបានជាប្រទីបនៃប្រទេស ៗ ប្រទេសនីមួយ ៗ ដែលមានដំណើរឃ្លាតចេញពីទុព្វលភាព ទៅកាន់ពលភាព, ពីហីនភាព ទៅកាន់ឧត្តមភាព និងពីទាសភាពទៅកាន់ឥស្សរភាព ដោយអាស្រ័យនឹងពលរដ្ឋរបស់ប្រទេស ដែលមានកម្លាំងច្រើនប្រការ មានកម្លាំងភោគសម្ប័ទនឹងកម្លាំងបំណេះវិជ្ជាជាដើម ៗ

## ពន្យល់ពាក្យ

សិល្បសាស្ត្រ ន. ក្បួនរៀនសិល្ប, បំណេះដាង, សរសេរជា សិល៍្បសាស្ត្រ ក៏បាន។ អក្សរសាស្ត្រ ន. វិជ្ជាអក្សរ, ក្បួនប្រាប់វិធីអក្សរ ៗ គណិតសាស្ត្រ ន. វិជ្ជាខាងលេខនព្វន្តសព្វយ៉ាង ។ វិទ្យា-សាស្ត្រ ន. គម្ពីរឬក្បួនប្រាប់វិជ្ជាផ្សេង ៗ វិជ្ជាពួកមួយដែលគេរកឃើញដោយការលៃផ្សំធាតុជាដើម ។ សមុដ្ឋាន ការតាំងឡើង, ការកើតឡើង, ដើមហេតុ; សរសេរជា សមុត្ថាន ក៏បាន។ សិក្ខាកាមជន ន. ជនអ្នកពេញចិត្តនឹងការរៀនសូត្រ អ្នកស្រឡាញ់ការរៀនសូត្រ ។ ប្រមា ៥ ក.

មើលងាយ ។ ពាធា កិ. បៀតបៀន ។ ឥស្សរភាព ន. ភាពជាឥស្សរៈ គឺជាធំ ។ បុរាណសម័យ ន. សម័យបុរាណ សម័យពីដើម គឺកាលពីព្រេងនាយ ។ ប្រវត្តិសាស្ត្រ ន. ក្បួនតម្រាខាងពង្សាវតារ ។ ប្រមាទ កិ. ធ្វេសប្រហែស, បណ្តែតបណ្តោយ ។ កោសជ្ជ-ភាព ន. ភាពជាអ្នកខ្ជិលប្រអូស ។ ទុព្វលភាព ន. ភាពទន់ខ្សោយ ។ ពលភាព ន. ភាពមានកម្លាំង ។ ទាសភាព ន. ភាពជាទាសៈ គឺជាខ្ញុំគេ ។ កុជិស្សភាព ន. ភាពជាអ្នកជា ៕

## វិជ្ជាជាទ្រព្យគាប់ប្រសើរ

វិជ្ជាជាទ្រព្យដ៏ខ្ពង់ខ្ពស់ឧត្តុង្គឧត្តម បានមកពីការខំប្រឹងសន្សំសិក្សារៀនសូត្ររាល់តែទិវារាត្រី ទោះបីតិចតួចពុំដែលខាតខាន អ្នកប្រាជ្ញសម័យបុរាណរាប់វិជ្ជាថាជាទ្រព្យដ៏ប្រសើរហៅថា អត្ថសមិទ្ធិ ប្រែថា "កំណប់ទ្រព្យជាប់ដោយអង្គប្រាណ" ទៅណាយកជាប់ទៅបានពុំមាននឿយព្រួយលំបាក ៕

កុលបុត្រ កុលធីតា កាលនៅជាកុមារកុមារី គួរឧស្សាហ៍

ខ្ញុំឃ្លាតសង្វាតរៀនសូត្រអក្សរសាស្ត្រ ព្រមទាំងចតុព្វិធលេខ ជាដើមឲ្យបានចេះប្រាកដ ក្នុងកាលបឋមវ័យ លុះសម័យតពីនោះមក ត្រូវរៀនសិល្បសាស្ត្រវិទ្យា ដែលមានប្រយោជន៍គួរសិក្សាតាមសម័យនិយម កុំបណ្ដោយឲ្យខ្លួនចំរើនវ័យធំជ្រងកហួសកំណត់ខ្សត់បំណេះឥតចេះដឹងអ្វី លុះដល់មជ្ឈិមវ័យត្រូវប្រឹងប្រែងស្វែងរកទ្រព្យ ដែលគួរគាប់សមតាមអធ្យាស្រ័យ នៃបណ្ឌិតពីបូរាណ ត្រូវប្រើប្រាស់ធនធានឲ្យសមតាមបែបបទ ទើបពេញជាបុរសស្ត្រីអ្នកមានសណ្ដាប់ធ្នាប់ដ៏បវរ គួរជាទីសរសើរត្រេកអរ នៃវិញ្ញូជន ។

## ពន្យល់ពាក្យ

ឧត្តុង្គ ឧត្តម គុ. ប្រសើរ, ថ្លៃថ្លាក្រៃលែង, ប្រសើរកន្លង សរសេរជា ឧត្តុង្គ-ឧត្តម ក៏បាន ។ ចតុព្វិធលេខ ន. លេខ ៤ បែប ។ បឋម-វ័យ ន. វ័យទី១, វ័យជាបឋម ។ វិញ្ញូជន ន. ជនអ្នកចេះដឹង, អ្នកប្រាជ្ញ ។

# នគរវត្ត[១]

នគរវត្តជាបាសាណប្រាសាទ សាងក្នុងបុរាណសម័យ សព្វថ្ងៃក៏នៅមានលំអដ៏បវរឥតមានពីរ ៗ ប្រាសាទនេះមានរាងសណ្ឋានជាប្រាង្គ ស្អិតស្អាងវិចិត្រដោយក្បូរក្បាច់របនាថ្មក ១ អនេកអនគ្ឃជាចម្លាក់ល្អបណ្ដាច់ ប្រើសុទ្ធតែក្បាច់ដ៏អស្ចារ្យរបស់ខ្មែរ ដែលនិយមរាប់អានលើកសរសើរថាមានតម្លៃក្នុងសម័យនោះ ៗ តាមពាក្យបរម្បរាតមកថា ព្រះពិស្ណុការមកជួយសាង តែបើតាមសិលាចារឹកជាភ័ស្តុតាងថាជាស្នាដៃនៃពួករាជ-វង្សក៏ ជាមនុស្សជាតិមារយាទខ្ពស់ អ្នកបរិបូណ៌ ដោយសិល្ប-សាស្ត្រវិទ្យា សាងក្នុងរាជ្យព្រះកេតុមាលាសូរ្យវរ្ម័ន ក្សត្រាធិរាជខេមរជាតិ ៗ សិលាប្រាសាទនេះ មាននាមល្បីសាយសុសទៅក្នុងសាកលលោក នៃទ្វីបបញ្ចភាគ លើកដំកើងឲ្យឃើញច្បាស់ថាកម្ពុជរដ្ឋធ្លាប់មានពួកអ្នកប្រាជ្ញតក្កវិជ្ជា, បរមត្ថវិជ្ជា ព្រម

តាំងវិទ្យាអក្សរសាស្ត្រជាអាទិ តាំងពីក្នុងបុរាណកាលរៀងរហូត ដរាបមក ។

## ពន្យល់ពាក្យ

ឆត្រវត្ត ន. ឈ្មោះប្រាសាទបុរាណមួយកន្លែងតាំងនៅក្នុងខេត្តសៀមរាបសព្វថ្ងៃ ។ **បាសាណប្រាសាទ** (អ. ថ. ប៉ាសាណៈប្រាសាត) ន. ប្រាសាទធ្វើពីថ្ម, ប្រាសាទថ្ម ។ **សណ្ឋាន** ន. រាងរៅ, ទ្រង់ទ្រាយ ។ **អនេកអនន្ត** (អ. ថ. អះនែក-អះណ័ក) គុ. ដែលច្រើនកាត់ថ្លៃពុំបាន ។ **បរម្បរា** (អ. ថ. ប៉ះរុំម-ប៉ះរ៉ា) ន. ពាក្យដំណាលត ៗ គ្នាមក ។ **ព្រះពិស្ណុការ** ន. ទេវតាអ្នកមានបំណេះស្ទាត់ជំនាញខាងការជាង ជាអ្នកសម្រេចកិច្ចការថ្វាយព្រះឥន្ទ្រ ។ **រាជវឌ្ឍកី** ន. ជាងឈើរបស់ព្រះរាជា, ពួកជាងឈើរាជការ ។ **ព្រះកេតុមាលាសូរ្យវរ្ម័ន** ន. ព្រះបរមនាមនៃព្រះរាជា ១ ព្រះអង្គ សោយរាជ្យនៅនគរធំ ទ្រង់ព្រះនាមថា ជយវរ្ម័ន ទី ២ ។ **សិលាប្រាសាទ** ន. ប្រាសាទថ្ម ។ **សកលលោក** ន.

លោកទាំងមូល។ ទ្វីបបញ្ចភាគ ន. ទ្វីប ៥ ភាគ។ តាមលទ្ធិពុទ្ធសាសនាថា មហាទ្វីបមាន ៤ គឺបុព្វវិទេហទ្វីប ១ ជម្ពូទ្វីប ១ អមរគោយានទ្វីប ១ ឧត្តរកុរុទ្វីប ១ សព្វថ្ងៃនេះដែលហៅថាទ្វីបបញ្ចភាគគឺ ទ្វីបអាស៊ី ១ ទ្វីបអឺរុប ១ អាហ្វ្រិក ១ អាមេរិក ១ ទ្វីបអូស្យានី ១ ។ ឧក្កាវិជ្ជា ន. បំណេះខាងការរិះរកហេតុផលដែលប្លែក ឲ្យឃើញប្រាកដជាក់ស្ដែងដោយគំនិតខ្លួនឯង ។ បរមត្ថវិជ្ជា ន. បំណេះខាងស្បង់។ អាទិ (ស. ប. អាត) ន. ខាងដើម, ជាអាទិគឺជាដើម ។ បុរាណកាល ន. កាលពីព្រេងនាយ, កាលពីដើម ។

---

## វត្តឧណ្ណាលោម

វត្តឧណ្ណាលោម ជាវត្តធំមួយក្នុងក្រុងភ្នំពេញ ។ មានចេតិយបុរាណធំមួយ ប្រតិស្ឋានពីខាងក្រោយឧបោសថាគារ មានចេតិយធំ ៗ បន្ទាប់គ្នា ៥ ទៀតព័ទ្ធជុំវិញ ។ តាមសេចក្ដីដំណាលត ៗ មកថា នៅក្នុងមហាចេតិយនោះ គេបញ្ចុះព្រះឧណ្ណាលោម គឺរោមប្រជុំចិញ្ចើមនៃព្រះមហាថេរមួយរូប មានគោត្តនាមនឹងបកតិនាមមិនប្រាកដ ។ លុះដល់មកក្នុងបុព្វភាគនៃសតវត្សទី ២៥ នៃពុទ្ធសករាជ ( ព. ស. ២៤២៣ ) សម្ដេច

ព្រះមហាសង្ឃរាជព្រះនាមទៀត បានបញ្ចុះព្រះបរមសារីរិកធាតុនៃព្រះសក្យមុនីសម្មាសម្ពុទ្ធ ជាមកុដនៃត្រៃលោកមួយអង្គតូច ក្នុងចេតិយធំមធ្យមភាគ ។ ព្រះបរមធាតុនោះ ព្រះសិរីសុមង្គលាចារ្យជាសង្ឃនាយកនៅលង្កាទ្វីប បានចាត់ព្រះមហាថេរមួយរូប ជាសាសនទូត ឈ្មោះនាថវីរិយៈឲ្យនាំមកថ្វាយ សឹងមានអក្សរចារឹកនៅមាត់ទ្វារទាំងគូខាងមុខចេតិយធំ ជាភស្តុតាងស្រាប់ ។ វត្តនេះជាសង្ឃារាមសម្បូណ៌ដោយកុដិ សាងដោយឥដ្ឋប្រក់ក្បឿង និងសាលាសិល្បករវិទ្យាការដ៏វិចិត្រ សម្រាប់ពួកបព្វជិតវិទ្យាគវេសិនសិក្សារៀនសូត្រតាមប្រាថ្នា គួរជាទីជ្រះថ្លានិងជាទីសរសើរនៃពុទ្ធបរិស័ទក្រៃពេក ។

## ពន្យល់ពាក្យ

ឧណ្ណាលោម ន. រោមប្រជុំបិញ្ចៀម ។ ចេតិយ (ស.ប. ចេតី) ន. ទីដែលគេបូជា គឺទីណាមួយទោះមានដើមឈើជាប្រធានក្តី មានដុំថ្មធំ ៗ ជាគ្រឿងសំគាល់ក្តី ដែលអ្នកផងសន្មតថាជាទីសក្តិសិទ្ធិ ហើយធ្វើសក្ការៈគោរព

ឬជា ហៅថា **ចេតិយ**, ឥឡូវនេះ, គេហៅត្រឹមតែគារវវត្ថុដែលបញ្ចុះព្រះសារីរិកធាតុព្រះសម្មាសម្ពុទ្ធ ជាដើមប៉ុណ្ណោះ ។ **ប្រតិស្ឋាន** (ស.ប. ប្រតិស - ស្ថាន) ន. ការឋិតនៅ, ការតាំងនៅ ឬ ការកសាង ។ ប្រើជា កិ. ឬ គុ. ក៏បាន, ក្នុងទីនេះប្រើជា កិ. ។ **គោត្តនាម** ន. ឈ្មោះត្រកូល ។ **បកតិនាម** ន. ឈ្មោះប្រក្រតី ។ **បុព្វភាគ** ន. ចំណែកខាងដើម ។ **សតវត្ស** ន. ឆ្នាំមួយរយ; កាលកំណត់មួយជុំរយឆ្នាំ ឬមួយខួបរយឆ្នាំ, សរសេរជា **សតវត្សរ៍** ក៏បាន ។ **ពុទ្ធសករាជ** ន. ចំនួនថ្ងៃខែឆ្នាំរាប់តាំងពីថ្ងៃ ១ រោចខែវិសាខឆ្នាំម្សាញ់ ក្រោយថ្ងៃដែលព្រះពុទ្ធទ្រង់ចូលនិព្វានទៅ ១ ថ្ងៃរៀងមក ហៅថា **ពុទ្ធសករាជ** ។ **សារីរិកធាតុ** ន. ព្រះអដ្ឋិធាតុនៃព្រះសម្មាសម្ពុទ្ធ ។ **សាសនទូត** ន. អ្នកនាំដំណឹងខាងសាសនា ។ **សង្ឃាវាស** ន. លំនៅព្រះសង្ឃ ។ **សិល្បាគារ** ន. ទីកើតនៃសិល្បៈ កន្លែងបង្កើតសិល្ប ។ **វិជ្ជាគារ** ន. រោងរៀន, សាលារៀន ។ **វិជ្ជាគវេសិន** ន. អ្នកស្វែងរកចំណេះវិជ្ជា ។

# ក្រុងលង្វែក

ក្រុងលង្វែកជាបុរាណរាជធានី នៃកម្ពុជរដ្ឋ ឋិតនៅខាងទិស ឦសាននៃក្រុងឧដុង្គមានជ័យ សព្វថ្ងៃតាំងនៅទីរួមខេត្ត កំពង់ឆ្នាំង ។ ព្រះបាទសម្តេចព្រះកូមិន្ទ នរបតីបរមបពិត្រជាខេមរប្រមុខ ក្នុងសម័យបុរាណ បានទ្រង់ត្រាស់ព្រះរាជបញ្ជា ឲ្យកសាង ព្រះរាជនិវេសន៍វ័ងក្នុងទីនោះ ឲ្យដាំសុទ្ធតែឫស្សីរលៀកគុម្ពធំ ៗ ព័ទ្ធជុំវិញវ័ងជាភាគកំពែងដ៏ក្រាស់ជិតស្និទ្ធ គួរឲ្យទុកចិត្តថាជាបាការកាពស្មាពារ សន្មតជានគរមានគ្រឿងការពារដ៏ស្តុកស្តម្ភមាំមួន ល្មមធន់ទ្រាំទប់ទល់នឹងការពុះពារយោយីនៃពួកបច្ចាមិត្រ បើទុកជាមានបុទ្ធានុភាពខ្លាំងពូកែស័ក្តិសិទ្ធិព្រោះប្រាជ្ញ ក៏ពុំអាចនឹងប្រទូស្តបានឡើយ ។ ប៉ុន្តែដោយសារសន្តិសុខសម្រាន្តក្សាន្តបាករណភ័យ នាំឲ្យរដ្ឋាធិបតីរវាតឃ្លាតបាកសតិសម្បជញ្ញៈធ្លាក់ចុះក្នុងការធ្វេសប្រហែស រដ្ឋាភិបាលប្រើកិរិយាក្រអែសមិនសូវប្រុងប្រយ័ត្នដោយមុឹងម៉ាត់ កម្ពុជាណាចក្រ

ក៏រឹតតែទៅជាកើតកោលាហល ពលរដ្ឋទាំងសាកលភ័យជ្រួល ប្របល់របល់ទាំងមន្ត្រីទាំងរាស្ត្រ ពួកសត្រូវបានឱកាសកំលើកទ័ពចូលដល់មក ព័ទ្ធឡោមបោមវាយបន្ទាយលន្លុកបែកខ្ទេចដល់នូវបរាជ័យភាព កម្ពុជប្រទេសថយអំណាចចុះទន់ទាបព្រោះតែប្រមាទធម៌នឹងការបែកសាមគ្គី ។ គួរពួកនរៈនិងនារីខេមរជាតិឧស្សាហ៍ខ្មីឃ្មាតសង្វាតរៀនវិជ្ជា និងសីលធម៌ គួរតាំងអធ្យាស្រ័យបំពេញសាមគ្គីរសស្មោះសររកគ្នាឲ្យបរិបូណ៌ឡើង ដើម្បីកសាងមាតុភូមិយើងឲ្យបានចំរើនរុងរឿងដូចដើមឡើងវិញ ។

## ពន្យល់ពាក្យ

បុរាណរាជធានី ន. ក្រុងដែលព្រះរាជាទ្រង់គង់នៅពីដើម ។ កម្ពុជរដ្ឋ ន. ដែនកម្ពុជា ។ ឦសាន ន. ព្រះឥស្សូរ, ពន្លឺ; លំអ ។ ទិសព្រះឥស្សូរ គឺទិសតួប ឬ ទិសជ្រុងត្រង់ចន្លោះទិសខាងជើងនិងទិសខាងកើត ។ ឧដុង្គមានជ័យ ន. ឈ្មោះរាជធានីចាស់មួយរបស់កម្ពុជរដ្ឋ ឋិតនៅត្រង់ចន្លោះទិសពាយព្យនិងទិសឧត្តរនៃក្រុងភ្នំពេញ

ជាក្រុងមុនបន្ទាប់ក្រុងភ្នំពេញសព្វថ្ងៃនេះ ហៅថា **ក្រុងឧដុង្គឫជ័យ** ក៏មាន ។ **ភូមិន្ទ** ន. អ្នកដែលជាធំជាងអស់ប្រជាជនលើផែនដី (ព្រះរាជា) ; ម.ភូមិន្ទ < ភូមិ+ឥន្ទ ។ ស័ព្ទថា ភូធន,ភូធរ,ភូបាល,ភូវន័យ ជាដើម សម្រាប់ប្រើផ្លាស់ប្ដូរគ្នា ប្រែថា ព្រះរាជា ដូចគ្នា ។ **នរបតី** (អ. ថ. នរប់-ប៉ះដី) ន. ម្ចាស់នៃនរៈ (ព្រះរាជា) ។ **បរមបពិត្រ** (< ម.សំ.បរម "ខ្ពង់-ខ្ពស់, ប្រសើរ, ក្រៃលែង" + បពិត្រ < សំ. បវិត្រ "សម្បត្តិជាគ្រឿងនាំចិត្តឲ្យរីករាយ, មង្គល, សួស្ដី" ។ ពាក្យសម្រាប់ហៅព្រះមហាក្សត្រទ្រង់រាជ្យ ។ ក្នុងទីនេះប្រើជា គោរមងារព្រះនាមព្រះមហាក្សត្រទ្រង់រាជ្យ ។ **ឧត្ដមប្រមុខ** ន. អ្នកដែលជាប្រធាន, ជាធំ, ជាច្បង, ដែលប្រសើរក្រៃលែងជាងប្រជាជនជាតិខ្មែរ ។ **រាជបញ្ញា** កិ. ត្រាស់បង្គាប់, ន. សេចក្ដីបង្គាប់នៃព្រះរាជា, ព្រះរាជឱង្ការត្រាស់បង្គាប់ ។ **រាជនិវេសន៍** ន. ទីសម្រាប់គង់នៅជានិច្ចនៃព្រះរាជា, ព្រះរាជដំណាក់, ព្រះរាជវាំង ។ **ប្រាការភាព** ន. ភាពនៃកំពែង ។ **ស្ថាពរ** គុ. (សំ. ស្ថាវរ; ម.ថាវរ) មាំមួន, រឹងប៉ឹង; ឋិតថេរ ។ **សន្មត** កិ. (ម.សម្មត) ប្ដេជ្ញា; សន្យា, អនុម័ត យល់...។ **នគរ** ន.

(សំ. ម.) ក្រុង ។ បច្ចាមិត្រ ន. សត្រូវ ។ បុញ្ញានុភាព ន. អានុភាពនៃឫទ្ធិ ។ ស័ក្តិសិទ្ធិ គុ. ដែលវិសេសវិសាល, ដែលខ្លាំងពូកែ, ដែលពូកែផុតឆាប់ ។ ប្រទុស្ត កិ. បៀតបៀន, រករឿងរកហេតុធ្វើឲ្យវិនាស ។ សន្តិសុខ ន. សុខដែលកើតអំពីសេចក្ដីស្ងប់ ។ សម្រាន្ត គុ. ដែលស្ងប់ឥតទុក្ខភ័យ ។ ក្សាន្ត គុ. ដែលស្ងប់ស្ងាត់បាកទុក្ខភ័យ ។ រណភ័យ ន. (សំ.ម.) ភ័យដែលកើតពីចំបាំងឬសង្គ្រាម ។ រដ្ឋាធិ-បតី, រដ្ឋាភិបាល ន. អ្នកត្រួតត្រាដែន, អ្នកគ្រប់គ្រងរក្សាប្រទេស ។ សតិសម្បជញ្ញៈ ន. ស្មារតីនឹងសេចក្ដីដឹងខ្លួន ។ កម្ពុជាណា-ចក្រ ន. អំណាចដែលប្រព្រឹត្តទៅក្នុងមួយជុំខេត្តដែន ដូចជាពាក្យនេះ គឺ អំណាចនៃការគ្រប់គ្រងប្រទេសមួយ ៗ ផ្សាយទៅជុំវិញប្រទេសនោះ; អាណាចក្រកម្ពុជា ។ វិបត្តិ ន. សេចក្ដីវិនាស, អន្តរាយ; ការដុនដាបទន់ទាប ; ដំ-ណើរហិនហោច, ការលិចលង់ ។ កោលាហល ន. សេចក្ដីភ្ញាក់ផ្អើល; ការផ្អើលជ្រើម ។ សាកល គុ. ឬ កិ.វិ. ដែលទូទៅទាំងអស់, ទាំងមូល, ទាំងគ្រប់ ។ ដូនកាលប្រើជា សកល ។ បរាជយភាព ន.

ភាពនៃកិរិយាបាញ់ ។ **កម្ពុជប្រទេស** ន. ប្រទេសកម្ពុជា ។ **សាមគ្គី** ន. សេចក្ដីព្រមព្រៀង, សេចក្ដីព្រមព្រៀងជាមួយគ្នា, ដំណើរស្រុះស្រួលគ្នា ។ **អធ្យាស្រ័យ** ន. សភាវៈដែលដេកអាស្រ័យនៅក្នុងចិត្ត, បំណង, បំណុបចិត្ត ។ **សាមគ្គីរស** ន. រសនៃសាមគ្គី ។

---

# បរាភវកថា

## ការប្រជុំគ្នានិយាយលេង ជាហេតុនៃសេចក្ដីវិនាស

នរជនណាៗ ស្រឡាញ់បបួលមិត្រភក្តិ ឬអ្នកស្និទ្ធស្នាលជាមួយ និយាយលេងឥតប្រយោជន៍ឥតខ្លឹមសារ តពីរឿងមួយទៅរឿងមួយមិនចេះចប់ បែកសាយារមោហ្លហ្លា ឬនិយាយតិរច្ឆានកថា ហែកហួរកេរ្ដិ៍គ្នាដោយឥច្ឆាចារ ឬគតិក្រោះរបស់ខ្លួនដែលជាឥច្ឆា-បកតបុគ្គល នរជននោះ ជាមនុស្សគ្រប្រហោងក្នុងទោស ព្រោះជាអ្នកប្រាសចាកសតិសម្បជញ្ញៈនឹងហិរិឱត្តប្បៈ បណ្ដោយខ្លួនឲ្យធ្លាក់ក្នុងហេតុនៃសេចក្ដីវិនាស ។ កើតមកជាមនុស្សប្រុសស្រីគប្បី

តែខំប្រឹងបណ្តុះពូជធារនៃចំណេះវិជ្ជាសព្វយ៉ាង នឹងខំប្រឹងប្រែងស្វះស្វែងរកទ្រព្យសម្បត្តិ ដោយអនោសជ្ឈភាព មិនគួរប្រហែសធ្វេសក្អេបខ្លួន ឲ្យកាលវេលាកន្លងហួសទៅ ដោយការប្រជុំគ្នានិយាយលេងទេ ព្រោះមនុស្សសត្វមានអាយុខ្លីណាស់ គ្រាន់តែធ្មេចបើក ១ ក៏ដល់នូវជរាទុព្វលភាព ថមថយខ្សោយកម្លាំង មានស្បែកជ្រួញជ្រីវយុរយាររេខករោក ធ្មេញបាក់ សក់ស្កូវ ត្រូវរោគាពាធដុតកំដៅ រាល់អហោរាត្រ មច្ចុរាជយាមាត់បង្គ្រិនចាំតែត្របាក់ស៊ីនូវជីវិតិន្ទ្រិយនៃសត្វ ចុះបើអាត់តែយកពេលទៅប្រជុំគ្នានិយាយលេងឥតប្រយោជន៍អស់ទៅហើយ តើបានពេលណានឹងធ្វើប្រយោជន៍ ? យើងកើតមកក្នុងវង្សត្រកូលឥតបុណ្យស័ក្តិ ឥតទ្រព្យសម្បត្តិបើយើងមិនខំប្រឹងប្រែងស្វែងរកចំណេះវិជ្ជា ទ្រព្យសម្បត្តិ កសាងសន្សំបុណ្យកុសលធ្វើជីវិតឲ្យថ្លៃថ្នូរទេ នោះយើងឈ្មោះថាកើតមកពីទីងងឹត ត្រឡប់ទៅកាន់ទីងងឹតវិញហៅថា តមោតមបរាយនបុគ្គល ជាអ្នកបំផ្លាញ

ខ្ញុំនឹងឲ្យសាបសូន្យបាតប្រយោជន៍ក្នុងលោកទាំងពីរ ។

## ពន្យល់ពាក្យ

តិរច្ឆានកថា (អ.ថ. តិរ័ច្ឆាន៉ះកៈថា) ន. សំដីទទឹងផ្លូវធម៌របស់សប្បុរស ។ តណ្ហាចារ (អ.ថ. តិនហាចា) ន. មារយាទ, ចិត្តគំនិត ឬការប្រព្រឹត្តប្រកបដោយការចង់បាន ឬសេចក្ដីលោភ ។ អភិគ្រោះ ន. (< សំ. អភិគ្រោហ) ការកំហែង, គំរាម ឬសង្កត់សង្កិន ។ តណ្ហាបកតបុគ្គល ន. បុគ្គលដែលសេចក្ដីលោភគ្របសង្កត់ គឺបុគ្គលដែលលុះក្នុងអំណាចនៃសេចក្ដីលោភ ដែលល្មោភចង់បានហួសហេតុឥតអៀនខ្មាស ។ ហិរិឱត្តប្បៈ ន. (< ម, ហិរិ+ឱត្តប្ប) សេចក្ដីខ្មាសបាបនឹងសេចក្ដីខ្លាចបាប ។ ជរាទុព្វលភាព ន. ដំណើរថមថយខ្សោយព្រោះចំណាស់ (ការចាស់គ្រាំគ្រា) ។ អនោសជ្ជភាព (អ.ថ. អៈណោស័ចជៈភាព) ន. (< ម អន "មិន, មិនមាន, មិនមែន, ឥត, ពុំ" + ឱសជ្ជ "លះបង់, លះចោល, បោះបង់" + ភាវ "ភាព") ការមិនលះបង់នូវព្យាយាម ឬ គំនិត ឬ កិច្ចការងារណាមួយចោល ។ អហោរាត្រ ន. ថ្ងៃ

និងយប់ (មួយថ្ងៃមួយយប់) ។ **មច្ចុរាជ** ន. ស្ដេចគឺសេចក្ដីស្លាប់ ឬ សេចក្ដីស្លាប់ទុកដូចជាស្ដេច ។ **ជីវិតិន្ទ្រិយ** ន. ឥន្ទ្រិយគឺជីវិត, អំណាច ឬ កំលាំងនៃជីវិត ។ **តមោតមបរាយណបុគ្គល** ន. បុគ្គលដែលល្ងិត ឬ ងងឹតល្ងង់ មានការងងឹតជាទីប្រព្រឹត្តទៅក្នុងខាងមុខ ។

---

# រឿងមច្ឆរិយកោសិយសេដ្ឋី

មានសេចក្ដីដំណាលថា មានសេដ្ឋីម្នាក់ឈ្មោះ មច្ឆរិយ-កោសិយសេដ្ឋីជាអ្នកមានសេចក្ដីកំណាញ់ទ្រឹស្ដិស្បរហួសប្រមាណ មានទ្រព្យសម្បត្តិចំនួន ៨០ កោដិ គ្រឹហាស្ថាននៅក្នុងសក្ករនិគម មិនឆ្ងាយប៉ុន្មានពីនគររាជគ្រឹះ ។ សេដ្ឋីនោះជាមនុស្សជ្វជាតិ ចិត្តអសប្បុរស សូម្បីរបស់បន្តិចបន្តួច ដូចជាប្រេងល្ងជាដើម ត្រឹមតែប៉ុនចុងស្នោ ក៏គាត់មិនដែលឲ្យទៅនរណាម្នាក់សោះ ទោះបីខ្លួនឯង ក៏មិនហ៊ានចាយវាយប្រើប្រាស់ឲ្យសមតាមធនធានដែលខ្លួនមានដែរ ។ ភោគសម្បទ៍ទាំងអស់របស់គាត់ សុទ្ធ

សឹងតែអសារឥតការ គ្មានបុត្រធីតាណា ឬក៏ស្មូមយាចកកបណក ទុគ៌ត មនុស្សទ័លក្រកំព្រាតោកយ៉ាកណា បានទទួលការ អនុគ្រោះសន្តោសប្រោសប្រាណ អំពីសំណាក់ធនិននោះឡើយ ជារបស់អបរិភោគរកអ្នកណាមួយប្រើប្រាស់មិនបាន ប្រាកដ ដូចជាអម្ពុជាគារ ឬ ស្រះដែលមានអារក្សទឹកហួងហែងរក្សា ។

ថ្ងៃមួយខាងក្រោយមក, ជាភ័ព្វគាប់ប្រសើររបស់គាត់ គឺ ក្នុងថ្ងៃនោះព្រះបរមសាស្ដា ទ្រង់ចេញពីមហាករុណាសមាបត្តិ ប្រមើលមើលសត្វជាផៅពង្សពោធនេយ្យ ក្នុងសកលលោកធាតុ នាបច្ចូសសម័យបានឃើញឧបនិស្ស័យវាសនា នៃសោតាបត្តិមគ្គ គឺលោកុត្តរធម៌ដើមខ្សែជាន់ខ្ពស់ របស់សេដ្ឋីនោះព្រមទាំងភរិយា ទើបព្រះសាស្ដា មានព្រះពុទ្ធដីកាប្រាប់ព្រះមហាមោគ្គល្លាន ឲ្យទទួលភារៈជាអ្នកទូន្មានសេដ្ឋី ដោយឥទ្ធិពលរបស់ខ្លួន ត្រាតែ សេដ្ឋីបានប្រតិស្ឋស៊ប់សួនក្នុងមគ្គផលដ៏វិសេស តាមសមគួរ ដល់បុញ្ញានិសង្ស ដែលបានកសាងសន្សំអប់រំទុកមក ពីក្នុង បុរេជាតិ ។

# ពន្យល់ពាក្យ

ឫទ្ធិស្សរ (អ. ថ. ឫទ្ធិះ-ឥស្សរ) គុ. ឬ ន. ដែលប្រកាន់ទិដ្ឋិព្រមទាំងមានចិត្តក្សរផង ។ ទ្រឹហាស្វាន ន. ?ះ ។ អសប្បុរស ន. ប្រុសអ្នកមិនស្ងប់ ជានដល់ជនអ្នកប្រព្រឹត្តធ្វើអំពើអាក្រក់ដោយកាយវាចាចិត្ត អ្នកមានចិត្តអាក្រក់ ។ ធនធាន ន. ទ្រព្យសម្បត្តិ ។ ភោគសម្បន្ន ន. (ម. ភោគ "ទ្រព្យ, សម្បត្តិ, ការបរិភោគ, ស្រួយ, ភ្លេន, ឆ្អែត, សេចក្តីសុខ. . . " + សម្បទា "ការដល់ព្រម, សេចក្តីសម្រេច") ការបរិបូណ៌ដោយភោគៈ ។ យាចក ន. សូម, អ្នកសូម ។ កបណក ន. អ្នកកំព្រា ។ ធនិន ន. អ្នកមានទ្រព្យ ។ អបរិភោគ គុ. ដែលប្រើប្រាស់មិនកើត ។ អម្ពុជាករ ន. ស្រះ, ត្រពាំងឬបឹង ។ មហាករុណាសមាបត្តិ ន. (<ម. មហាករុណា "សេចក្តីអាណិតធំ ឬច្រើន គឺការអាណិតចំពោះសត្វសត្វមិនរើសមុខ ចង់ឲ្យរួចចាកទុក្ខភ័យទាំងអស់គ្នា... + សមាបត្តិ "ការដល់ព្រម, ការបណ្តាលឲ្យកើតមានឡើង, ការសមប្រកប, ការជួបប្រទះ, ការភពប្រសព្វ, ការសម្រេច; ការចូលឈានតាមលំដាប់ភ្ជាប់ទាំង៨ គឺរូបជ្ឈាន៤ អរូបជ្ឈាន៤ ") សមាបត្តិប្រកបដោយមហាករុណា ។

**ពោធនេយ្យ** គុ. ដែលគួរឲ្យត្រាស់ដឹងបាន, សត្វដែលមានបុញ្ញាភិនីហារកសាងសន្សំទុកមកពីក្នុងជាតិមុន មានឧបនិស្ស័យគួរត្រាស់ដឹង, ល្មមត្រាស់ដឹងបាន ។ **សកលលោកធាតុ** អ.ថ. (សៈ កៈ ល៉ៈ លោកៈធាតុ) ន. ទំហំលោកក្នុងមណ្ឌលចក្រវាឡទាំងមូល ។ **សោតាបត្តិមគ្គ** ន. ឈ្មោះលោកុត្តរធម៌ដើមខ្សែថ្នាក់មគ្គ ។ **លោកុត្តរធម៌** ន. ធម៌ចម្លងសត្វឲ្យចេញផុតចាកលោក ។ ធម៌នោះមាន ៩ យ៉ាង គឺមគ្គ ៤ គឺសោតាបត្តិមគ្គ ១ សកទាគាមិមគ្គ ១ អនាគាមិមគ្គ ១ អរហត្តមគ្គ ១; ផល ៤ គឺសោតាបត្តិផល ១ សកទាគាមិផល ១ អនាគាមិផល ១ អរហត្តផល ១ និងនិព្វាន ១ ទៀតត្រូវជា ៩ ហៅថា នព្វលោកុត្តរធម៌ ។ **មហាមោគ្គល្លាន** ន. ព្រះនាមព្រះថេរជាសាវ័កឆ្វេង ( ទុតិយសាវ័ក ) នៃព្រះសក្យមុនីគោតមបរមសាស្តារបស់យើង ។ ព្រះថេរអង្គនេះ កាលនៅជាគ្រហស្ថ មានបកតិនាមថា **កោលិត** លុះបួសក្នុងពុទ្ធសាសនា ព្រះបរមសាស្តាទ្រង់ត្រាស់ហៅថា **មោគ្គល្លាន** ព្រោះលោកជាបុត្រនៃនាងព្រាហ្មណី ឈ្មោះ **មោគ្គល្លី** ។ តាមសេចក្តីម្យ៉ាងទៀតថា ព្រោះលោកកើតក្នុងត្រកូលមោគ្គល្លាន ។ **ឫទ្ធិពល** ន. កម្លាំងនៃឫទ្ធិ ។ **ប្រតិស្ឋ** ក. តាំង, ដំកល់, ស្ថិតនៅស៊ប់ ។ **បុញ្ញាភិសង្ស** ន.

អានិសង្សនៃបុណ្យ គឺការបានសម្រេចសេចក្ដីសុខ សេចក្ដីចំរើនរុងរឿងដោយសារបុណ្យបង្ហូរផ្ដល់មកឲ្យមិនដាច់ ។ បុរេជាតិ ន. ជាតិមុន ។

# រឿងអានន្ទសេដ្ឋី

បានឮមកថា មានសេដ្ឋីម្នាក់ឈ្មោះអានន្ទៈ ជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភរាប់កោដិ តែជាអ្នកកំណាញ់ស្វរជូជាតិ រាល់តែអន្លូងមាស គាត់តែងសន្និបាតញាតិមិត្តជិតឆ្ងាយទាំងអស់ ហើយហៅកូនប្រុសរបស់គាត់ឈ្មោះមូលសិរី មកឲ្យឱវាទដំបូន្មានថា "ម្នាលកូនសម្លាញ់ឪពុក ទ្រព្យសម្បត្តិសម្បុកទ្រព្យរបស់យើង ចូរកូនចាំថែទាំរក្សាឲ្យល្អ កុំទុកស្មានថាទ្រព្យប្រមាណ ៤០ កោដិនេះច្រើនឡើយ, ទ្រព្យដែលមានហើយ ចូរកូនកុំឲ្យទៅអ្នកដទៃ ត្រូវខំឃ្លាតខ្ចីបង្កបង្កើតទ្រព្យសម្បត្តិថ្មី ឲ្យបរិបូណ៌ឡើងទៀត ត្រូវចៀតឱកាសស្វែងរកទ្រព្យសម្បត្តិកុំបីប្រហែស បើអ្នកបេះតែចាយវាយប្រើប្រាស់កញ្ចះកញ្ចាយដោយខ្លួនឯង ឬឲ្យទានដល់ស្មូមម្ដ៍ ១ សេន១កាក់១រៀលតែរាល់ថ្ងៃទៅ មិនយូរឡើយទ្រព្យ

ជននេះនឹងអស់លើងទៅពុំខាន ; នែកូន! គ្រហស្ថដែលបេះដៃ ខ្លួនគេឲ្យទៅជាអ្នកមានបាន ព្រោះគេមានស្មារតីរស់រវើកជានិច្ច គេមានកលកិច្ចឧបាយច្រើនយ៉ាងណាស់ គេឃើញច្បាស់ ប្រត្យក្សជាក់នឹងភ្នែកគេ នូវការអស់ទៅនៃថ្នាំបន្តក់ភ្នែក ១ ដំណក់ម្ដង ៗ , នូវការកើតនៃសត្វកណ្ដៀរ, នូវការផ្សំសន្សំនៃភមរជាតិមានឃ្មុំជាដើម ។ ហេតុនេះ បូរកូនខំប្រឹងប្រែងស្វែងរកទ្រព្យកុំធ្វេសទ្វេឡើយ" ។ អានន្ទសេដ្ឋី តែងកុំញាតិមិត្រកូនចៅឲ្យខំរក្សាយ៉ាងនេះរាល់កន្លះខែឥតមានល្ហែលំហខានឡើយ ។

## ពន្យល់ពាក្យ

ស្ទូរ គុ. កំណាញ់រិតត្បិតតតក្ខួស, កំណាញ់ក្រៃពេក ។ អឌ្ឍមាស ន. រាល់តែកន្លះខែ ។ សន្និបាត កិ. ជុំ, ប្រជុំ ។ ស្មូម អ្នកសូម ។ គ្រហស្ថ ន. អ្នកមានផ្ទះ, អ្នកគ្រប់គ្រងផ្ទះ ។ ស្មារតី ន. សេចក្ដីនឹកឃើញ ការចាំបាន ។ ភមរជាតិ ន. សត្វល្អិតពួកកន្លង់, ឃ្មុំ, ព្រូត, ម្រោម ហៅថា ភមរជាតិ ។

# រឿងអានន្ទសេដ្ឋី (ត)

អានន្ទសេដ្ឋី ជាអ្នកមានទ្រព្យស្តុកស្តម្ភក៏ពិតមែន ប៉ុន្តែគាត់មិនដែលឲ្យទាន ធ្វើបុណ្យកុសលអ្វីសោះ លុះសម័យខាងក្រោយមក ត្រូវរោគាព្យាធិបៀតបៀន មច្ចុសង្គ្រាមក៏រុករានទន្ទ្រានចូលមកផ្តាច់ផ្តិលជីវិតទ្រើយគាត់ កណ្តាលគំនរសម្បុកសម្បត្តិដ៏ច្រើន ៗ សេដ្ឋីអនិច្ចកម្មទៅដោយនូវសេចក្តីប្រមាទ នឹងសេចក្តីកំណាញ់កាញ់ទ្រព្យសម្បត្តិទុក មិនបានប្រាប់នូវមហាកំណប់ដល់កូនរបស់ខ្លួន គាប់ជួនជាសេចក្តីស្លាប់មកដល់ គាត់ក៏លាកលេះលោកនេះទៅកាន់បរលោក បានទៅចាប់បដិសន្ធិក្នុងផ្ទៃនៃស្រីចណ្ឌាល ទាស្រុកមួយក្បែរក្រុងសាវត្ថី ។ ព្រះភូមិន្ទនរបតីជាប្រមុខរដ្ឋ ក៏តាំងកូនគាត់ឈ្មោះមូលសិរី ក្នុងសេដ្ឋីដ្ឋានតរៀងមក ៗ

គួរឲ្យសង្វេគ ។ ចាប់តាំងពីថ្ងៃដែលអានន្ទសេដ្ឋី ទៅចាប់កំណើតក្នុងត្រកូលចណ្ឌាលនោះវេលាណា, ត្រកូលនោះទៅជាអភ័ព្វ ជាឧបទ្រពចង្រៃអពមង្គល ទាំងស្វែងរកធ្វើការឈ្នួល ឬ

ប្រកបការរេបរចិញ្ចឹមជីវិតក៏មិនបានសោះ ម្ល៉ោះហើយ ជនទាំងនោះក៏កើតជម្លោះទាស់ទែងគ្នាបែកខ្ញែកជាពីរដោយគិតថា កាឡកណ្ណី កើតឡើងក្នុងត្រកូលនេះ ។ ឯស្ត្រីចណ្ឌាល ដែលអានន្ទសេដ្ឋីទៅចាប់បដិសន្ធិនោះ ជាស្ត្រីរស់នៅដោយត្រដាបត្រដួសពេកណាស់ បានព្រឹកខ្វះល្ងាច បានល្ងាចខ្វះព្រឹក គឺជាទុក្ខវេទនារបស់នាង ដែលកើតឡើងដោយសារអានន្ទសេដ្ឋីទៅចាប់កំណើតក្នុងគភ៌នោះឯង ។

## ពន្យល់ពាក្យ

បុណ្យ ន. គុណជាតជាគ្រឿងជំរះសន្តានចិត្ត, អំពើល្អ, សេចក្ដីសុខ ។ ធ្វើបុណ្យគឺធ្វើសេចក្ដីល្អខាងផ្លូវកាយវាចាចិត្តឲ្យកើតមានដោយកិច្ចនិងទំនងផ្សេងៗ ។ កុសល ន. កម្មដែលកំចាត់បង់នូវអំពើអាក្រក់ ។ រោគាព្យាធិ ន. ជម្ងឺផ្សេង ៗ, ជម្ងឺច្រើនយ៉ាង ។ មច្ចុសង្គ្រាម ន. ចំបាំងគឺសេចក្ដីស្លាប់, សេចក្ដីស្លាប់ដែលទុកដូចជាចំបាំង ។ អនិច្ចកម្ម ន. កម្មមិនទៀង (សេចក្ដីស្លាប់), កិ. ស្លាប់។ពាក្យសំរាប់ប្រើខាងសាធារណជនជាគ្រហស្ថ។ចំណែកខាងបព្វជិត

ប្រើពាក្យថា អចិន្ត្យធម្ម ។ ប្រមាទ ន. ការភ្លេចស្មារតី, ធ្វេសស្មារតី, សេចក្ដីប្រហែស ។ បដិសន្ធិ ន. តំណកំណើតសត្វ ។ សេដ្ឋដ្ឋាន ន. ទីឬដំណែងនៃសេដ្ឋី ។ កាឡកណ្ណី (អ.ប. កាល-កណ្ណី) ន. មនុស្សធ្វើនូវវិស្ស័យនៃខ្លួនឲ្យប្រាកដស្មើដោយវត្ថុមានពណ៌ខ្មៅ : មនុស្សចិត្តខ្មៅ, មនុស្សឥតបុណ្យ, មនុស្សចង្រៃ ។ ប្រើឃ្លាតក្លាយជា កាឡកិណី ក៏មាន ន័យរបស់ពាក្យដូចគ្នា ។

---

## រឿងអានន្ទសេដ្ឋី(ត)

អានន្ទសេដ្ឋីកើតមកមានរូបអាក្រក់ហួសប្រៀប ដៃ ជើង ក្ញក ត្រចៀក ច្រមុះ មុខ មាត់ សុទ្ធសឹង វិកលវិការ មិនតាំងនៅតាមយថាឋានឡើយ ។ ទារកនោះប្រកបដោយអង្គវិកល្ល មានរូបអាក្រក់ដូចជាបិសាចគួរខ្លាចក្រៃពេក ។ សម្បើមយ៉ាងនេះក៏មាតាមិនលះបង់ទារកនោះចោលឡើយ ស៊ូទ្រាំចិញ្ចឹមកូននោះតាំងទុក្ខវេទនារហោមរហាមក្រៃលែង កាន់អំបែងដើរសូមទានគេតាមភូមិស្រុក គេគ្រាន់តែឃើញមុខ គេខ្ពើមឆ្អើម

ដេញកាយថែមទៀត ។ ថ្ងៃមួយក្រោយមក នាងជាមាតា, ដោយនាងលំបាកទីងស្វែងរកអាហារចិញ្ចឹមជីវិតពេក ហើយដោយកូននាង ក៏ចំរើនវ័យធំល្មមដើរសូមទានគេចិញ្ចឹមជីវិតដោយខ្លួនឯងបានផង, ក៏និយាយនឹងកូនថា "ម្នាលកូនសម្លាញ់ម្ដាយ! ម្ដាយតាំងពីកូនមកចាប់បដិសន្ធិក្នុងផ្ទៃរហូតមកដល់ថ្ងៃនេះ បានសេចក្ដីទុក្ខលំបាកខ្លាំងណាស់ ឥឡូវម្ដាយក៏កាន់តែចាស់ថមថយខ្សោយកម្លាំង ទីងពកូនដើរសូមទានគេតាមប្រក្រតីធម្មតាពុំបាន ហេតុនេះ ចូរកូនកាន់អំបែងដើរសូមទានគេចិញ្ចឹមជីវិតចុះ!" ។

ចាប់តាំងពីថ្ងៃនោះរៀងរាបដរាបមក កុមារអភ័ព្វនោះ ក៏កាន់អំបែងខ្លួនឯង ដើរសូមទានគេចិញ្ចឹមជីវិត រស់នៅបានដោយត្រដាបត្រដួស ឥតមានអ្នកណាជួយអាណិតសន្ដោសប្រោសប្រាណឡើយ ។

## ពន្យល់ពាក្យ

វិកាល (ស.ថ.-កល់) គុ. ដែលខ្វះខាត, មិនគ្រប់គ្រាន់ ។ វិការ ន.

ការធ្វើប្លែកចាកប្រក្រតីដើម, ការប្រែប្រួលចាកភាពប្រក្រតី, ការប្លែកខុសធម្មតា ។ **យថាឋាន** ន. កន្លែងដើម, កន្លែងដដែល, ទីដដែល។ **អង្គវេ-កល្យ** ( អ.វ.-កល់ ) ន. ភាពជាអ្នកមិនគ្រប់គ្រាន់ដោយរាងកាយ, ភាពជាអ្នកវិកលអវយវៈ (មានដៃបមាត់ ខ្វាក់ភ្នែក ស្រលៀងស្រលើកើជាដើម) ។ **បិសាច** ន. អមនុស្សជាអបាយិកសត្វ ដែលកើតនៅក្នុងមនុស្សលោកនេះ ។ អមនុស្សនេះមានច្រើនពួក មានអមនុស្សដែលលិទ្ធជញ្ជក់ឈាមស្រស់ ឬ ដែលជញ្ជក់យករសតំរង់សាកសពផ្សេងៗជាដើម ។ **សន្តោស** ន. សេចក្តីត្រេក-អរ ពេញចិត្តចំពោះវត្ថុជារបស់ខ្លួន គឺបានប៉ុន្មានល្មមចិត្តត្រឹមប៉ុណ្ណោះ មិនរវះរវាមហួសហេតុហួសទំនង ។ ខ្មែរច្រើនប្រើជាកិរិយាស័ព្ទ សំដៅសេចក្តីថា អាណិតមេត្តាត្រាប្រណី ឧ. ត្រូវអាណិតសន្តោសគ្នា ! ។ **ប្រោសប្រាណ** កិ. ប្រោសដោយមេត្តាត្រាប្រណី ។

---

## ព្រះរាជពិធីតាំងតុ

*ព្រះរាជពិធីតាំងតុ ជាព្រះរាជពិធីទ្វាទសមាសមួយជាប់ជាប្រពៃណីរៀងមក ដែលនាហ្មឺនមុខមន្ត្រីគង់ក្រុងនិងខេត្តក្រៅនៅព្រះរាជអាណាចក្រប្រារព្ធធ្វើឡើង ដើម្បីចំរើនព្រះជន្មវស្សា*

ព្រះមហាក្សត្រិយ៍ ឲ្យបានគង់ក្នុងសិរីពេជសម្បត្តិស្ថិតស្ថេរចីរកាល ជានិរន្តរ៍តទៅអនាគត ។ ពិធីនេះគេតាក់តែងធ្វើខាងក្នុងកំពែងព្រះបរមរាជវាំង ។ នៅបរិវេណខាងមុខ មានរៀបពិធីតាំងតុគ្រប់ល្វែង ។ ក្នុងល្វែងនីមួយ ៗ មានតាំងវិជភណ្ឌច្រើនអនេកអនន្តមហគ្ឃមហន្តផ្សេង ៗ មានគ្រឿងយុទ្ធោបករណ៍, គ្រឿងទូរគមនាគមន៍ នឹងគ្រឿងក្សួរក្សាប់បេនាជាដើម ៗ

តាមទ្វារប្រវេសន៍ខាងត្បូង មានមនុស្សប្រុសស្រីក្មេងចាស់ កម្លោះក្រមុំស្លៀកពាក់គយាវជវជាយប្រជ្រៀតគ្នាឮអឺះអ៉ះ ចូលទៅមើលពិធីតាំងតុ ដើរឈូឆរអ៊ូអរកុះករមីរដេរដាសឈរមើលកាំជ្រួចរន្ទាក់ទៀនដែលជារស្មីម៉ត់បែកពន្លឺព្រោងព្រាតព្វដំនកាល័យវេហាស៍ មៀងមើលទៅលើកំពូលទេវាវិនិច្ឆ័យ ឃើញពន្លឺប្រទីបផ្កាឈាក្ដីប្រុះចាំងរូបនាគានិងរូបគ្រុឌ មើលទៅខាងលើបំផុតឃើញមុខព្រហ្មបួន បែរគក្រ្តញញឹមពព្រាយជំភ្ញប្រិយ ហាក់ដូចជាស្ដីមកកាន់អ្នកផង បក្សីពត្រីបរ មៀម ខ្វែងស្រាក ហើរ

យំផ្អើលផ្អួនទ្រហឹងអឹងអាប់ ឮសូរសព្ទភ្លេងពិណពាទ្យ និង ចម្រៀងល្ខោនព្រះរាជទ្រព្យ លេងនៅប្រាសាទគោជនីយ ឲ្យប្រជាជនប្រុសស្រីមើលកំសាន្តសាធារណ៍ នៅខាងក្រៅកំពែងព្រះបរមរាជវាំង មានឈ្មួញលក់ដូរភោជ្យភ័ស្តុ និងបូរិភ័គតិផ្សេងៗ មានលេងល្បែងឯទៀត ៗ ជាគ្រឿងកំសាន្តដល់មហាជនគ្រាតែហើយបុណ្យតាំងតុ ។

## ពន្យល់ពាក្យ

ទ្វាទសមាស ន. (ម.) ខែដប់ពីរ, មួយខួបខែ, មួយឆ្នាំ ។ ក្នុងកម្ពុជប្រទេសយើង, ប្រើជាឈ្មោះបុណ្យ ឬ ព្រះរាជពិធីដែលធ្វើក្នុងមួយខែម្ដង ជាទំនៀមតាមរាជប្បវេណី ហៅថាពិធី ទ្វាទសមាស ៗ ប្រពៃណី ន. ទំនៀម, ពូជពង្ស ដំណវង្សត្រកូល ។ ប្រើជា បវេណី ឬប្រវេណី ក៏បាន, ន័យរបស់ពាក្យដូចគ្នា ។ ជន្មវស្សា ន. អាយុ ។ ស្ថិតស្ថេរចិរកាល ន, កាលក្រា, ពេលដែលឋិតថេរយូរអង្វែង ។ និរន្តរ៍ ក. វិ. ដែលឥតមានចន្លោះ, ឥតស្រាក, ឥតឈប់, ឥតល្ហែ, ជានិច្ច ។ អនាគត ន, កាលដែលមិន

កាន់មានមក, កាលខាងមុខ ។ បរិវេណ ន. ទីជិតខាងដែលព័ទ្ធជុំវិញ, របង ឬថែវដែលព័ទ្ធជុំវិញ ។ វិវិធភណ្ឌ ន. ភណ្ឌផ្សេងៗ, របស់ច្រើនមុខ, អីវ៉ាន់ច្រើនយ៉ាង ។ អនេក គុ. ដែលមិនមែនតែមួយ, គឺច្រើនដែលរាប់ពុំបានប្រមាណពុំត្រូវ ។ អនេកអនន្ត គុ. ច្រើនក្រៃលែងមិនមានទីបំផុត ។ មហគ្ឃមហន្ត គុ. ដែលធំ, ច្រើន, សំបើម, ប្រសើរ, សុទ្ធសឹងតែមានថ្លៃច្រើនសម្បើម ។ យុទ្ធោបករណ៍ ន. គ្រឿងប្រដាប់សម្រាប់ច្បាំង, គ្រឿងចំបាំង ប្រើជា យុទ្ធុបករណ៍ ក៏មាន ។ ទូរគមនាគមន៍ ន. គ្រឿងប្រដាប់សម្រាប់ធ្វើដំណើរទៅកាន់ប្រទេស ឬ ទីឆ្ងាយ ។ ទ្វារប្រវេសន៍ ន. ទ្វារសម្រាប់ចូល, ទ្វារចូល ។ គឃារ គុ. ដែលស្អុយ, ស្រុងខ្លាំងពេក ។ ជរជាយ គុ. ដែលមានជរនៅជាយស្អុយច្រសាយលយចេញទៅខាង ។ រស្មីមត គុ. មានពន្លឺរស្មី ។ ធនាល័យ ន. លំនៅនៃពពក ពីមេឃ ។ វេហាស៍ ន. ប្រទេសជាទីរីករាយនៃបក្សី, អាកាស, មេឃ ។ ទេវវិនិច្ឆ័យ .ន ការវិនិច្ឆ័យនៃទេវតា, ការសម្រេចសេចក្តីរបស់ទេវតា ។ ពាក្យនេះ ខ្មែរយើងប្រើឲ្យឈ្មោះប្រាសាទមួយជាស្ថានសំរាប់ប្រជុំធំនៅក្នុងព្រះបរមរាជវាំង ជាប្រាសាទដែលធំកល់ស្វេតច្ឆត្រសម្រាប់រាជ្យ ។

**ជ្វាលា** ន. អណ្ដាតភ្លើង, សេចក្ដីរុងរឿង, ពន្លឺដែលភ្លឺប្រុះព្រោងព្រាត ។

**នាគា** គុ.បុ.ន. (អ. នាគ; ពហុ. នាគា "នាគទ.") ។ ពាក្យថា នាគ នេះប្រែបានច្រើនយ៉ាងណាស់ ប្រែថា "ប្រសើរ, បំបង, បរិសុទ្ធ; ព្រះពុទ្ធ, ព្រះអរហន្ត, អ្នកមិនធ្វើបាប, ដំរី, ពស់; ដើមខ្លឹង, សំណ" ។ មយ៉ាងទៀត បុរសដែលបំរុងខ្លួន នឹងបួសជាសាមណេរ ឬភិក្ខុ ក៏ហៅថា នាគ ដែរ ដោយសំដៅយកសេចក្ដីថា "អ្នកមិនធ្វើបាប, អ្នកប្រសើរ" ព្រោះមានវិគ្រោះថា **ន អាគុំ ករោតីតិ នាគោ** "អ្នកណាមិនធ្វើបាប អ្នកនោះហៅថា នាគ" ប៉ុន្តែក្នុងទីនេះសំដៅយករូបនាគតែម្យ៉ាងប៉ុណ្ណោះ ។ **គ្រុឌ** ន. (សំ.គរុឌឬគរូឌ; ម គរុឡ "គ្រុឌ") ឈ្មោះបក្សីមានក្នុងរឿងបុរាណថា ជាយានជំនិះនៃព្រះនារាយណ៍ ។ ក្នុងប្រទេសយើង ពួកជាងច្រើនធ្វើរូបគ្រុឌ ប្រើជាគ្រឿងរចនាមួយយ៉ាងរបស់ប្រាសាទ, វិហារអាគារធំៗ ។ **ព្រហ្ម** ន. សេចក្ដីចំរើន, សេចក្ដីរីករាយ, សេចក្ដីប្រសើរ ។ ទេវតាដែលកើតនៅព្រហ្មលោកដោយអំណាចផលនៃឈាន ។ មាតាបិតាក៏ហៅថា ព្រហ្ម (របស់បុត្តធីតា) ដោយអាងព្រះពុទ្ធដីកាថា **ព្រហ្មាតិ មាតាបិតរោ** "មាតាបិតាហៅថាព្រហ្ម" ព្រោះមានព្រហ្មវិហារផ្សាយទៅរកបុត្រធីតា ។ ព្រះសម្មាសម្ពុទ្ធ នឹងព្រះអរហន្តក៏ហៅថា **ព្រហ្ម** ព្រោះមានចរិយធម៌ដ៏ប្រសើរបំផុត ។ ក្នុងទីនេះសំដៅយកព្រះព្រហ្ម ដែលកើតនៅព្រហ្មលោក ។ ព្រះព្រហ្មបានជាគេ

ធ្វើមានមុខ៤ ព្រោះសំដៅសេចក្ដីថា ជាអ្នកមានព្រហ្មវិហារធម៌ផ្សាយទៅគ្រប់ទិសទាំង ៤ ។ ព្រហ្មវិហារ ប្រែថា "ធម៌ជាទីនៅនៃព្រហ្ម ធម៌ជាលំនៅនៃចិត្តដ៏ប្រសើរ" ; មាន ៤ យ៉ាងគឺ :

១– មេត្តា ផ្សាយសេចក្ដីរាប់អានទៅរកសព្វសត្វ ;

២- ករុណា ផ្សាយសេចក្ដីអាណិតទៅរកសព្វសត្វ;

៣– មុទិតា ផ្សាយអំណរទៅរកសព្វសត្វដែលបានសេចក្ដីសុខ-ចំរើន;

៤– ឧបេក្ខា ផ្សាយសេចក្ដីស្មោះស្មើទៅរកសព្វសត្វ ។ គុ. ប្រសើរ, ខ្ពង់ខ្ពស់, ឧត្តុង្គឧត្តម ។ ភក្ត្រ ន. (សំ. វក្ត្រ; សំ.ក្ល.វ. < ព = ពក្ត្រ ខ្មែរប្រែក្លាយមកជា ភក្ត្រ) មុខ ។ ភក្ត្រាប្រិយ គុ. គួរស្រឡាញ់ ។ បក្សី ន. សត្វមានស្លាប (សត្វស្លាប) ។ រាត្រីចរ ន. សត្វដែលចេញរកស៊ីតែក្នុងវេលាយប់ មៀម, ខ្លែងស្រាក, ពាក្លក់ ជារាត្រីចរ ។ ជួនកាលប្រើជា រត្តិចរ តាមបាលី, ន័យរបស់ពាក្យដូចគ្នា ។ ពិណពាទ្យ ន (សំ.ម.វីណា «ចាប៉ី» + សំ. វាទ្យ «គ្រឿងប្រគំ, គ្រឿងភ្លេងជេញជំផ្លុំគួត» គ្រាន់តែផ្លាស់វ ជាពទៅជា ពិណពាទ្យ ។ ជាឈ្មោះតន្ត្រីសម្រាប់ដំភាយផ្លុំប្រគំ មួយវង់ ។

ភោជនីយ គុ. ដែលគួរបរិភោគ, គួរប្រើប្រាស់ ។ ន. ល្បែកៈប្រាសាទម្ហូបក្នុង ព្រះបរមរាជវាំង ដាក់ខ្វែងសម្រាប់លៀងភ្ញៀវក្នុងព្រះរាជពិធីធំ ៗ ម្តង ៗ ហៅឲ្យត្រូវ ជាប្រាសាទភោជនីយសោភ័ណ ។ ភោជ្ជវត្ថុ ឬ ភោជ្យវត្ថុ ន. (ម ភោជ្ជ + វត្ថុ; សំ. ភោជ្យ + វស្តុ; វ > ព > ភ) វត្ថុដែលគួរបរិភោគ, គ្រឿង ស៊ីផ្សេង ៗ ។ បូរ្វិភាត (អ. ថ.) ប៉ូវៈ រិ-កាត់) នំប្លែក ៗ, នំផ្សេង ៗ ច្រើនយ៉ាង ។

---

# ព្រះពុទ្ធ

ប្រមាណ ២៥៣៤ ឆ្នាំហើយ មានអច្ឆរិយបុរសម្នាក់ឧប្បត្តិ ឡើងក្នុងលោកនៅមជ្ឈិមប្រទេស គឺប្រទេសឥណ្ឌៀសព្វថ្ងៃ នេះ ។ ព្រះបាទសិរីសុទ្ធោទន៍ ព្រះចៅក្រុងកបិលពស្តុជាព្រះ រាជបិតា មានព្រះវររាជជននីនាថ ព្រះនាមសិរីមហាមាយា កាលនៅជាព្រះរាជកុមារ ទ្រង់ព្រះនាមថាសិទ្ធត្ថរាជកុមារ ទ្រង់ ប្រសូតក្រោមដើមសាលព្រឹក្ស ក្នុងសួនលុម្ពិនីវ័នឧទ្យានដែល ឋិតស្ថានត្រង់ចន្លោះនគរកបិលពស្តុ នឹងទេវទហៈ ខាងទិស ពាយ័ព្យនៃនេបាលរដ្ឋ នាថ្ងៃពេញបូណ៌មីខែពិសាខ ឆ្នាំច មុន

ពុទ្ធសករាជ ៨០ ឆ្នាំ ។ កាលព្រះអង្គព្រះជន្មបាន ១៦ វស្ស
ព្រះវររាជបិតា បានរៀបមង្គលាភិសេកជាមួយព្រះនាងពិម្ពាយសោ
ធរា ឲ្យសោយរាជ្យស្នងព្រះអង្គ ទ្រង់គង់នៅជាសុខសាន្ត មា
រាជបរិពារស្រីស្នំក្រមការហោមរោមហែហមជាបរិវារគ្រប់ទីរាជគ្រឹះ

ថ្ងៃមួយព្រះមហាសត្វ ពិចារណាឃើញទោសក្នុងបញ្ចក
ដោយវិចារណញ្ញាណរបស់ព្រះអង្គ ទ្រង់ក៏មានព្រះទ័យធុ
អាល័យក្នុងសិរីរាជសម្បត្តិ លុះដល់ពេលពាក់កណ្តាលអធាត្រ
ស្ងាត់ ថ្ងៃពេញបូណ៌មីនៃឧត្តកសាឡ្ហមាស ក្នុងឆ្នាំថោះ ព្រ
មហាបុរសក៏កាត់ព្រះទ័យចេញចាកព្រះបរមរាជវាំង ដោយព្រ
ទីនាំងអស្សតរឈ្មោះកណ្ឋកៈ មានតែអាមាត្យម្នាក់ឈ្មោះឆន្ន
ដែលហែតាមព្រះអង្គទៅកាន់មហាភិនិក្ខមនដ្ឋាន ទ្រង់សា
បព្វជ្ជាតាមពុទ្ធប្បវេណី នាឆ្នេរខាងនាយនៃស្ទឹងអនោមានទី
តពីនោះ ព្រះអង្គបានតាំងព្យាយាមយ៉ាងមាំប្រព្រឹត្តទុក្ករកម្ម អស
ប្រាំមួយវស្សាគត់ ក៏រលត់រាគាទិក្កិលេស ជាទីរាវសេស បាន

បម្រើបនូវអនុត្តរសម្មាសម្ពោធិញ្ញាណ បានត្រាស់ជាព្រះសព្វ-

ញ្ញូពុទ្ធប្រសើរផុតក្នុងលោក ។

# ពន្យល់ពាក្យ

ប្រមាណ ន. ការរាប់, ការស្ទង់, ការស្មាន ។ កិ. រាប់, ស្ទង់, ស្មាន, ហែល... ។ អច្ឆរិយបុរស ន. បុរសដែលគួរស្ងើចក្រៃពេក, ប្រុសដែលគួរស្ងើចសរសើរក្រៃពេក, បុរសអស្ចារ្យ ។ ឧប្បត្តិ (អ. ថ. អ៊ុប-ប៉ត) . ការកើតឡើង ។ កិ. កើត, កើតឡើង ។ មជ្ឈិមប្រទេស ន. ប្រ-សភាគកណ្តាលនៃជម្ពូទ្វីប, ប្រើជាមជ្ឈិមប្រទេសក៏បាន ។ សិរីសុទ្ធោទន៍ (ម. សិរី+សុទ្ធោទនៈ សិរីប្រែថា "សួស្តី, សេចក្តីសុខ, សេចក្តីចំរើន, លំអដែលគួរស្រឡាញ់ពេញចិត្ត, តេជះ, អំណាច, ភ័ព្វ, សំណាង ... ", សុទ្ធោទន ប្រែថា បាយសុទ្ធ ឬ បាយស " ។ ព្រះបរមនាមព្រះវររាជបិតា នៃព្រះសក្យមុនីគោតមបរមសាស្តា: ព្រះបាទសិរីសុទ្ធោទន៍, ប្រើជា ស្រីសុទ្ធោទន៍ ក៏មាន ។ កបិលព័ស្តុ ន. ឈ្មោះរាជធានីនៃព្រះសក្យមុនីគោតមបរមសាស្តា ។ . កបិលវស្តុ ខ្មែរផ្លាស់ វ ជា ព ជាកបិលពស្តុ ហើយក្លាយជា

កបិលពស្តុ ។ **មហាមាយា** ន.(< ម.គុ. មហា «

ច្រើន, ប្រសើរ, សំភើម, ខ្លាំង, + មាយា « ស្ត្រីបណ្ដើរកូន, កិច្ចកល »

ព្រះនាមព្រះអគ្គមហេសី នៃព្រះបាទសិរីសុទ្ធោទន៍, ជាពុទ្ធមាតានៃព្រះ

សព្វញ្ញូពុទ្ធ ។ **សិទ្ធត្ថរាជកុមារ** ន. ព្រះរាជកុមារព្រះនាមសិទ្ធត្ថ

សិទ្ធត្ថ ប្រែថា "អ្នកមានប្រយោជន៍សម្រេចហើយ អ្នកសម្រេចប្រយោជ

គ្រប់យ៉ាង" ។ ព្រះសក្យមុនីសម្ពុទ្ធរបស់យើង កាលប្រសូតបាន ៥ ថ្ងៃ ព្

ព្រាហ្មណ៍ហោរាចារ្យបានថ្វាយព្រះនាមថា សិទ្ធត្ថៈ ។ **លុម្ពិនីវ័ន** ន

ព្រៃឈ្មោះលុម្ពិនី ។ ជាឈ្មោះកន្លែងដែលព្រះសក្យមុនីសម្មាសម្ពុទ្ធទ្រង់ប្រសូត

សព្វថ្ងៃហៅថា រុម្មិនេឌៃ ។ **ឧទ្យាន** ន. សួនដែលមានដើមឈើខ្ពស់

ស្រឡូតស្រឡះមានផ្កាផ្លែនឹងកាំអគួរឲ្យចង់ដើរមើលកំសាន្តចិត្ត, សួនឈើដែលមា

ម្លប់ត្រឈឹងត្រឈៃសម្រាប់ដើរកំសាន្តកែអផ្សុក ។ ច្រើនប្រើក្លាយជា ឱទ្យាន

**ប្រតិស្ឋាន** ន. ការបិតនៅ, ការតាំងនៅ ។ ប្រើជា កិ. ឬ គុ. ក៏បាន

**ពាយ័ព្យ** ន. ឈ្មោះទិសតូចមួយបែកនៅត្រង់ចន្លោះទិសខាងលិចនឹងខាងជើង

**នេបាលរដ្ឋ** ន. ដែនឈ្មោះនេបាល ។ ជាឈ្មោះថ្មីនៃដែនសក្កៈពីជំនា

ពុទ្ធកាល ។ រាជធានីនៃនេបាលរដ្ឋឈ្មោះកដ្ឋមណ្ឌូ ។ **មជ្ឈលាភិសេ**

. ការស្រោចទឹកជាមង្គល, ការស្រោចទឹកឲ្យមានមង្គល ។ **បញ្ចក្ខន្ធ** ន,
ប្រាំ គឺរូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ។ **វិចារណញ្ញាណ** ន.
ណជាគ្រឿងពិចារណា ប្រាជ្ញាដែលផុសផុលឡើងព្រោះការពិចារណា ប្រាជ្ញា
ម្រាប់ពិចារណា ។ **អធ្រាត្រ** ន. ពាក្យប្រើក្លាយមកពីសំ. អធិរាត្រី
អធិរាត្រ « ពាក់កណ្ដាលយប់ » ។ **ឧត្តរាសាឍ្ហមាស**
ខែអាសាឍក្រោយ ( ខ្មែរធ្លាប់ប្រើជាទុតិយាសាឍ ) ។ ខែនេះ
នតែក្នុងឆ្នាំដែលលើកខែ (តាមអំណាចបន្ធគតិ) ត្រូវលើកត្រង់អាសាឍនេះឲ្យ
រខែ, ខែអាសាឍមុនហៅថា បុព្វាសាឍ ឬ បុព្វាសាឍ្ហ ប្រែថា អាសាឍមុន,
អាសាឍក្រោយហៅថាឧត្តរាសាឍ ឬ ឧត្តរាសាឍ្ហ ប្រែថា អាសាឍក្រោយ ។
យើងច្រើនប្រើជា បឋមាសាឍ ទុតិយាសាឍ ប្រែថា អាសាឍទី ១
សាឍទី ២ វិញ ។ **អស្សតរ** ន. សេះល្អ, សេះលឿន ។ **អ-**
**ត្យ** ន. មន្ត្រីអ្នកស្និទ្ធជិតនឹងព្រះរាជា មន្ត្រីជាទីប្រឹក្សាកិច្ចការផែនដីរបស់
ជា, នាហ្មឺន ។ ជួនកាលប្រើជា **អាមាត្យ** ក៏មាន, ន័យរបស់ពាក្យ
។ **មហាភិនិក្ខមនដ្ឋាន** ន. ទីកន្លែងជាទីធ្វើនូវការចេញទ្រង់ព្រះ
នព្រះមហាសត្វក្នុងបច្ឆិមភព; កន្លែងជាទីធ្វើនូវការចេញដើម្បីគុណដ៏ធំក្រៃលែង ។

ពុទ្ធប្បវេណី ន. ទំនៀមទម្លាប់នៃព្រះពុទ្ធ ។ ទុក្ករកម្ម ន.
អំពើកម្រ; អំពើដែលកម្រអ្នកណាធ្វើបាន ។ រាគាទិក្កិលេស ន.
កិលេសមានរាគៈជាដើម ។ និរាវសេស គុ. ដែលមិនមានសេសសល់
ដែលគ្មានសល់ ។ អនុត្តរសម្មាសម្ពោធិញ្ញាណ ន. ញាណ
ឬ ប្រាជ្ញានៃព្រះសម្មាសម្ពុទ្ធ ដែលប្រសើរផុតឥតមានអ្វីប្រៀបស្មើបាន ។

---

# ប្រជាធិបតេយ្យ

ពាក្យថាប្រជាធិបតេយ្យ គឺជាអភិធេយ្យនៃលទ្ធិមួយ
ដែលគ្រប់គ្រងរដ្ឋដ៏ល្អវិសេសទាន់សម័យ ជាបិយលទ្ធិនៃសេ
ប្រជាជាតិទូទៅក្នុងលោក ។ លទ្ធិនេះ ជាប្រភពនៃសេរីភាព
សមភាព នឹងឥស្សរភាព ព្រមទាំងមានអានុភាពអាចស្រោ
ស្រពប្រស់ព្រំមនុស្សជាតិ ឲ្យមានជីវភាពដុះលូតលាស់ស្រស
បំប្រែប្រកបដោយសេចក្ដីកក់ក្ដៅ នឹងសេចក្ដីសង្ឃឹម បំពោ
ជោគវាសនាអនាគតរបស់ខ្លួនដោយឥតមានសេចក្ដីរង្កៀសសង្ស
សង្ស័យអំពីការបៀតបៀនលោក នៃមនុស្សជាតិផងគ្នា ។

លទ្ធិប្រជាធិបតេយ្យ ជាគ្រឿងអលង្ការដ៏ពិសិដ្ឋសម្រាប់ប្រមិតសម្រាំងប្រដាប់តាក់តែង នូវជីវភាពនៃមនុស្សជាតិក្នុងស-លលោកឲ្យមានលំអដ៏បវរសក្តិសម ឲ្យប្រកបការរបរលៀងជីពនបានដោយសេរី ឲ្យមានជីវិតរស់នៅក្នុងលោកបានដោយសេរីប្រាសចាកការសង្កត់សង្កិនរបជាន់លោកនៃជនជាដើម ។ តែ លុះណាតែជនជាតិទាំងសកល មូលមិត្តរួមចិត្តមួយប្រព្រឹត្តមលក្ខណៈដោយបរិបូណ៌ ទើបលទ្ធិប្រជាធិបតេយ្យអាចផ្តល់នូវផ្លផលគ្រប់យ៉ាងបាន ។ បើគ្រាន់តែយកនាមលទ្ធិនេះ មកដោយឥតតាំងចិត្តប្រព្រឹត្ត ធ្វើតាមរបៀបប្រជាធិបតេយ្យសោះះមុខជានឹងមិនបានទទួលនូវផលល្អសមដូចសេចក្តីប្រាថ្នាទេជាគ្រឡប់ប្រែខ្វាបែរជា បាននូវផលផ្ទុយនឹងសេចក្តីប្រាថ្នាវិញមាន ។

## ពន្យល់ពាក្យ

ប្រជាធិបតេយ្យ ន. ភាពនៃប្រទេសដែលមានប្រជាជនជាធំ, ធិបតី, ជាជាងហ្វាង, ក្នុងការជ្រើសរើសឥស្សរជនឲ្យជាអ្នកសម្រេចកិច្ចការក្នុង

ព្រះនគរ ។ អភិជេយ្យ ន. ឈ្មោះ ។ លទ្ធិ ន. ការឃើញ
សេចក្ដីយល់ឃើញ, សេចក្ដីប្រកាន់, ជំនឿ, ការប្រកាន់ជឿ, បែបបទ, កា
និយម ។ បិយលទ្ធិ ន. លទ្ធិជាទីស្រឡាញ់ ។ ប្រភព ន
ដែនកើត, ដែនបណ្ដាលឲ្យកើត ។ សេរីភាព ន. អំណាចដែលអាចធ្វើ
បានតាមអំពើចិត្ត, អំណាចពេញទី ។ សមភាព ន. ភាពស្មើគ្នា,
ដំណើរស្មើមុខគ្នា ។ សមភាពមាន ៤ យ៉ាងគឺ

១.-ភាពស្មើគ្នាដោយកិច្ច គឺមានកិច្ចការដែលត្រូវធ្វើស្មើគ្នា

២.-ភាពស្មើគ្នាដោយអានុភាព គឺមានអំណាចស្មើគ្នា,

៣.-ភាពស្មើគ្នាដោយសីល គឺមានមារយាទល្អស្មើគ្នា,

៤.-ភាពស្មើគ្នាដោយទិដ្ឋិ គឺមានការយល់ឃើញស្របគ្នា ។

ឥស្សរភាព ន. ភាពនៃអ្នកធំ, ភាពជាធំ ។ អានុភាព
ន. អំណាច, សេចក្ដីអាច, សេចក្ដីក្លាហាន, សេចក្ដីអង់អាច, តេជះ ។ ជីវភាព
ន. ភាពនៃការរស់នៅ, សេចក្ដីរស់នៅ ។ អលង្ការ ន. គ្រឿងប្រដាប់សម្រាប់

តាក់តែងកាយឲ្យល្អ ។ ពិសិដ្ឋ គុ. ដែលឧត្តម, ខ្ពង់ខ្ពស់,ប្រសើរ,ល្អ,ថ្លៃថ្លា។ ជីពជន្ម ន. ជីវិត ។ ឥដ្ឋផល ន. ផលជាទីពេញចិត្ត, ផលដែលគួរប្រាថ្នា, គួរត្រូវការ ។

---

# រឿងព្រះបាទធម្មាសោករាជ

ព្រះបាទធម្មាសោករាជ ជាបរមក្សត្រាធិរាជប្រទេសឥណ្ឌា ក្នុងបុរាណសម័យ ។ ព្រះភូវន័យជៀសួជ័យអង្គនេះ ទ្រង់មានព្រះរាជហឫទ័យ ធ្ងរឆេវគ្រេវគ្រោធខ្លាំងណាស់ បើទ្រង់ព្រះពិរោធនឹងនរណា ក៏ត្រាស់ព្រះរាជបញ្ជាឲ្យប្រហារពិឃាតនរនោះ មួយរំពេច ឥតបង្អែបង្អង់ឡើយ សូម្បីព្រះអនុជកនិដ្ឋារបស់ព្រះអង្គ ក៏ទ្រង់ធ្វើគត់ផ្ទាល់ព្រះហស្ត អស់ ៩៩ ព្រះអង្គ តែអំណើះតមកទ្រង់បានព្រះសណ្ដាប់ពុទ្ធភាសិតមធុរស ដែលនិគ្រោធសាមណេរជាព្រះភាគិនេយ្យ របស់ព្រះអង្គសំដែងថ្វាយ ទ្រង់ក៏ជ្រះថ្លារីករាយ មានព្រះទ័យប្រីតាប្រាមោទ្យចំពោះភាសិតនោះ ទើបទ្រង់លះបង់នូវអំពើទុច្ចរិត ជាបាបកម្មទាំងអស់

ត្រឡប់ជាមានធម៌សប្បុរស ប្រតិបត្តិទសពិធរាជធម៌ បរិបូណ៌ ដោយសីលាចារ ឧបត្ថម្ភព្រះពុទ្ធសាសនា មានព្រះរាជសទ្ធា ជាកិយោភាព បានកសាងសេនាសនៈ មានវិហារ កុដិ សាលា ចេតិយ បូជនីយព័ស្តុជាដើម ។

បំណោរតមកខាងក្រោយ ទ្រង់បានព្រះសណ្ដាប់ព្រះធម្មទេសនា នៃព្រះមោគ្គលីបុត្តតិស្សត្ថេរថែមទៀត ក៏រឹងរឹតតែជ្រះថ្លាដ៏ក្លាខ្លាំង បានសាងវិហារនិងចេតិយស្ថានជាអនុស្សាវរីយ៍ ប្រាំបីម៉ឺនបួនពាន់ បូជាឧទ្ទិសព្រះធម្មក្ខន្ធ គ្រប់ខេត្តខណ្ឌនគរក្នុងជម្ពូទ្វីបទាំងមូល មិនតែប៉ុណ្ណោះ ព្រះធរណិន្ទបានបំពេញព្រះរាជកុសលដទៃទៀតជាច្រើន មានការឧបត្ថម្ភក្នុងការធ្វើតតិយសង្គាយនាជាដើម ដរាបដល់ល្បីរន្ទឺខ្ចរខ្ចាយនូវព្រះបរមនាមថា ព្រះបាទអសោកធម្មិករាជ ឬព្រះបាទធម្មាសោករាជ ។

## ពន្យល់ពាក្យ

ធម្មាសោករាជ (< ម. ធម្ម "ធម៌" +

អសោក "ដែលឥតសោក, ឥតស្តាយស្រណោះ" + រាជ "ស្តេច") ព្រះបរមនាមមហាក្សត្រមួយព្រះអង្គក្នុងប្រទេសឥណ្ឌៀ ក្នុងសតវត្សរ៍ទី ៣ នៃពុទ្ធសករាជ ជាក្សត្រប្រកបដោយធម៌ ។ បរមក្សត្រាធិរាជ ន. ព្រះរាជាជាធំចំបង, ជាក្សត្រប្រសើរក្រៃលែង ។ ឥណ្ឌៀ ន. ឈ្មោះភូមិប្រទេស១ប៉ែកធំទូលាយ ក្នុងទ្វីបអាស៊ី មានទន្លេឥណ្ឌុសឧបពីខាងលិច ដែលក្នុងបុរាណសម័យហៅថា ប្រទេសសិន្ធុរៈ ឬ សិន្ធុព, តមកហៅក្លាយជា ហិណ្ឌូ, តមកទៀតហៅ ឥណ្ឌា (អង់គ្លេសហៅប្រទេសនោះថា ឥណ្ឌៀ) ។ ភូវន័យ ន.ព្រះរាជា ។ ជេដ្ឋជ័យ គុ. ដែលធំបំផុត ជាចំបង ថែមទាំងមានជ័យជំនះផង ឬមានជ័យជំនះជាងអ្នកដែលជាចំបង ។ ហឫទ័យ ន. បេះដូង, ដួងចិត្ត, ចិត្ត, ទ្រូង ។ ពិរោធ ន. កំហឹង, កំហុស, សេចក្តីស្អប់ ។ កិ. ខ្ញាល់, ខឹង ។ អនុជ ន. អ្នកកើតបន្ទាប់, អ្នកកើតក្រោយ (ប្អូន) ។ ភិន្នោទរ ន. បងប្អូនដែលកើតអំពីមាតាផ្សេងគ្នា តែរួមបិតាមួយ គឺបងប្អូនឪពុកតែមួយម្តាយទីទៃ ។ ឃាត កិ. ប្រហារ, កាប់, ពិឃាត, សម្លាប់ ។ ពុទ្ធភាសិត ន. ពាក្យដែលព្រះពុទ្ធទ្រង់សំដែង, សំដីព្រះពុទ្ធ, ព្រះពុទ្ធដីកា ។ មធុរស ន. រសទឹកឃ្មុំ, រសផ្អែម, រសឆ្ងាញ់ ពីរោះ ។ ភាគិនេយ្យ ន. កូនប្រុសរបស់បង

ស្រី ឬរបស់ប្អូនស្រី (ក្មួយប្រុស) ។ **ប្រីតាប្រាមោទ្យ** គុ. ឆ្អែតចិត្ត ដោយអំណរដ៏វិសេស ។ **បាបកម្ម** ន. អំពើអាក្រក់ ។ **ទសពិធ-រាជធម៌** ន. រាជធម៌ ១០ យ៉ាង, ធម៌ ១០ ប្រការ សម្រាប់ព្រះរាជាប្រព្រឹត្ត ។ ទសពិធរាជធម៌នោះគឺ ១. ការឲ្យទាន ; ២. ការរក្សាសីល ៥ ជានិច្ច ឬ រក្សាសីល ១០ តាមកាលគួរ ៣. ការបំណាយព្រះរាជទ្រព្យទំនុកបំរុងព្រះនគរ, ៤. មានសេចក្ដីត្រង់, ៥- មានសេចក្ដីទន់ភ្លន់ស្លូតសុភាពរាបសា, ៦- ការរក្សាឧបោសថសីលតាមកាលកំណត់, ៧- មិនកំដៅអ្នកដទៃឲ្យក្ដៅក្រហាយ : ៨- មិនបៀតបៀនអ្នកដទៃ, ៩- មានសេចក្ដីអត់ធន់, ១០- មិនបំពានលើធម៌ ឬ លើច្បាប់ ។ **សីលាចារ** ន-សីលនិងមារយាទ ។ **ឧបត្ថម្ភ** កិ- ទំនុកបំរុង, ទល់ទ្រ, គាំទ្រ ។ ន ការទំនុកបំរុង, ការទល់ទ្រ, ការគាំទ្រ ។ **កិយ្យោភាព** ន-ដំណើរច្រើនក្រៃលែង, ភារៈលើសលែង ។ **សេនាសនៈ** ន-ទីដេកនិងទីអង្គុយ ។ **ចេតិយ** ន. ទីដែលគេគោរពបូជា ។ **បូជនីយវត្ថុ** ន. វត្ថុដែលគួរបូជា ។ **មោគ្គលីបុត្តតិស្សត្ថេរ** ន- ព្រះថេរឈ្មោះតិស្សៈ ជាបុត្ររបស់នាងព្រាហ្មណីឈ្មោះមោគ្គលី ។ **អនុស្សាវរីយ៍** ន. ទីកន្លែងដែលគេកសាង ទុកជាទីរលឹកនឹកឃើញ ។ **ធម្មក្ខន្ធ** ន. ពួកធម៌ កងធម៌, ចំនួនកងធម៌ ជាពុទ្ធវចនៈ ក្នុងព្រះត្រៃបិដក ។ **ធរណីន្ទ**

ន. អ្នកកើតជាធំលើផែនដី (ព្រះភគវា) ។ តតិយសង្គាយណា ន.( <ម. តតិយ "ទីបី, ជាគំរប់បី" សង្គាយណា "ការប្រជុំសូត្រឲ្យត្រូវគ្នាតែបែបមួយ, ការប្រជុំផ្ទៀងធម៌ ឬច្បាប់ឲ្យត្រឹមត្រូវ មិនឲ្យល្អៀងឃ្លៀងឃ្លាតអំពីបែបដើម) សង្គាយណាលើកទីបី ។ ធម្មិករាជ ន. ស្ដេចប្រកបដោយធម៌ ។

# ក្រុងភ្នំពេញ

ភ្នំពេញជារាជធានីនៃកម្ពុជរដ្ឋនឹងបច្ចុប្បន្នសម័យ កំណត់នាមាភិធេយ្យតាមឈ្មោះនៃសុទ្ធបំសុបពិត ៗ គន់មើលពីចម្ងាយមក ឃើញស្តូបមួយខ្ពស់ត្រដែត រាងស្តុកស្តម្ភ ទំហំសមទីកំពស់ មានកំពូលខ្ពស់ត្រដង់ទៅលើវេហាស៍ រំលេចរចនាដោយក្បូរក្បាច់ដ៏ល្អក្រៃពេក ៗ មានព្រះបរមរាជវាំង តាំងនៅពីខាងទិសបស្ចិម នៃមហានទីសង្គមចតុម្មុខ ដោយហេតុនេះទើបគេសន្មតនាមប្រាកដមួយយ៉ាងទៀតថា ចតុម្មុខនគរ តាមនាមដំបូងនៃរាជ-ទេវដ្ឋាន ៗ ជានគរមានប្រាសាទវិមានដ៏វិចិត្រ មានវត្តអារាមធំតូច ជាទីប្រតិស្ឋាននៃបូជនីយវត្ថុ ជាភស្តុតាងតំណាងទង់ជ័យ

អរហន្តដែលពួកពុទ្ធបរិស័ទ គឺស្រមណ៍បព្វជិត អ្នកប្រព្រឹត្តសីល-ធម៌ ស្លៀកដណ្តប់បិទបាំងសពាង្គកាយ ដានគរសុខសប្បាយក្សេមក្សាន្ត ពុំសូវមានឧបស័គ្គគ្រោះថ្នាក់ជាអវកដអ្វីឡើយ ។

## ពន្យល់ពាក្យ

បច្ចុប្បន្នសម័យ ន. សម័យដែលកំពុងតែមានក្នុងទីចំពោះមុខ គឺសម័យសព្វថ្ងៃ ។ នាមាភិធេយ្យ ន. ឈ្មោះ ។ សុទ្ធបិ-សុបពិត ន. ភ្នំដារិការនៃអាចម៍ដីតុរូ ។ បស្ចិម ន. (ម. បច្ឆិម) ទិសដែលមានក្នុងខាងក្រោយ, ទិសខាងលិច ។ គុ. ដែលមានក្នុងទីបំផុត, ខាងក្រោយ ។ មហានទីសង្គមចតុម្មុខ ន. ទន្លេធំភ្ជុំប្រសព្វមុខបួន ។ ចតុម្មុខនគរ ន. ក្រុងតាំងនៅត្រង់ទន្លេប្រសព្វមុខបួន ។ រាជន្តេបុ-រដ្ឋាន ន. ទីកន្លែងជាទីតាំងនៃព្រះរាជវាំង ។ ប្រាសាទ ន. គ្រឹហាជាទីនាំចិត្តឲ្យជ្រះថ្លា គឺផ្ទះមានជាន់ខ្ពស់ស្រឡះល្អគួរជ្រះថ្លា ។ វិមាន ន. លំនៅ, ប្រាសាទ, ដំណាក់ដែលល្អវិសេស សម្រាប់ព្រះមហាក្សត្រ ។ វិចិត្រ គុ. ដែលលាយចំរុះ ឬរំលេចព័ណ៌ ដែលរំលេចឆ្លាក់ក្បាច់របនា, ដែលផ្ទុះផ្លាស់. ល្អប្លែកអនេកអនគ្ឃ ។ អារាម ន ប្រទេស ឬទីជាទីញុំាងចិត្តឲ្យរីករាយ

សប្បាយ; សួន, ក្ដួនច្បារ, អាវាសដែលមានក្ដួនច្បារ និងកុដិលំនៅនៃពួកបណ្ឌិត ។ **បូជនីយពស្ត្រ** ន. សំពត់ដែលគួរបូជា ។ **អរហត្ត** ន. ឈ្មោះលោកុត្តរធម៌ ថ្នាក់ខ្ពស់បំផុត ដែលព្រះអរហន្តបានសម្រេច, ភាវៈនៃខ្លួនជាព្រះអរហន្ត, ភាពជាព្រះអរហន្ត; *បូជនីយពស្ត្រ* **ជាក់ស្តុតានដំណាន ទង់ជ័យអរហត្ត** គឺសំពត់ជ្រលក់ទឹកអម្ចត់ សម្រាប់បណ្ឌិតស្លៀកដណ្ដប់ ។ **ពុទ្ធបរិស័ទ** ន. (ពុទ្ធ+បរិស័ទ) ពួកជនដែលស្ម័គ្រចិត្តពួតរួមគំនិតធ្វើការ ដើម្បីព្រះពុទ្ធសាសនា បរិស័ទព្រះពុទ្ធ ។ **ស្រមណ៍** ន. (ម.សមណ) អ្នកមានព្យាយាមដុតកំដៅបាប, អ្នកខំប្រឹងប្រព្រឹត្តធម៌ ធ្វើកាយវាចាចិត្តឲ្យស្ងប់ចាកបាប, អ្នករម្ងាប់បាប (អ្នកបួស) ។ **បព្វជិត** ន. អ្នកបួស ។ គុ. ដែលបួសរួចហើយ ។ **ឧបស័គ្គ** ន. ឧបទ្រព, ចង្រៃ គ្រឿងទើសទាក់, គ្រឿងជំទាស់, គ្រឿងរាំង ។ **អរគាដ** គុ. ដែលមានដំណើររអាក់រអួលផ្សេងទីទៃពីគ្នា ។

---

# ទន្លេមេគង្គ

*មេគង្គ ជាមហាទន្លេមួយក្នុងអាស៊ីទ្វីប មានឈ្មោះប្រាកដក្នុង*

ភាគភូមិសាស្ត្រលោក ។ មានបណ្ឌិតអត្ថកោវិទខ្លះយល់ថា ទន្លេនេះឈ្មោះមេគង្គ ទើបសមនឹងសណ្ឋានភាព ព្រោះមានសណ្ឋានធំមហិមា ជាងមហាសិន្ធូនានាក្នុងកម្ពុជរដ្ឋ ប៉ុន្តែជនជាតិខ្មែរបែរជាហៅមហាជលមគ៌ានេះថា ទន្លេធំ វិញ ។ ទន្លេនេះ មានសីសប្រភពចេញមកពីមហាបព៌ត នៅប្រទេសទីបេត៍ ដែលជាសម្ពន្ធវង្សនៃភ្នំហិមពាន្តមានជលធ្លាយធ្លុះហូរចុះកាត់តាមណាខេត្តចិននឹងលាវ មកដល់ភូមិភាគ មឿង ខូង នឹង ខន ត្រង់ព្រំប្រទល់រដ្ឋលាវនឹងខ្មែរ បែរជាកែលវិបរិតខុសពីធម្មតា ដោយមានក្ដុំ, ក្រួសនឹងពំនូកថ្មតានធំ ៗ រដិបរដុបដេរដាស មានអាការដូចគោះដុះទាំងជាទំនប់បាំង ទប់កាំងជលបថឲ្យបាល់ មិនឲ្យហូរត្រចាញ់ស្មើភាគគ្នាបាន ទឹកហូរចំហុងព្រយុងធ្លាក់ពីលើចុះមកក្រោម សូរស័ព្ទរំពងខ្លាំងប្រចាំងប្រទើស ហាក់ដូចជាប្រណាំងប្រជែងដណ្ដើមផ្លូវគ្នា ជាឧបសគ្គរាំងរាមិនឲ្យនាវាចរចុះឡើងបាន ។ ទន្លេមេកុងមានជលហូរកាត់ធ្លុងមកដល់ស្ថាន

បំពីខាងបូព៌ាទិសនៃព្រះបរមរាជវាំង ក្រុងភ្នំពេញ បែកចេញជា បួនមុខ ហាក់ដូចជាប្រតិស្ឋាននាមទុកឲ្យរាជធានីនេះ មាន ឈ្មោះថា ចតុមុខនគរ ។

## ពន្យល់ពាក្យ

មហានទី ន. ទន្លេធំ ។ អាស៊ីទ្វីប ន. ទ្វីបអាស៊ី។ អត្ថ-កោវិទ ន. អ្នកល្អស,អ្នកស្ទាត់ជំនាញក្នុងអត្ថ ។ មេគង្គ ន. ទន្លេធំ ។ ទន្លេនេះមានក្បាលហូរចេញមកពីភ្នំទីបេត៍ (ប្រទេសចិនប៉ែកខាងលិច) ចម្ងាយប្រហែល ៤.៥០០ គីឡូម៉ែត្រ ។ សណ្ឋានភាព ន. ភាពនៃទ្រង់ទ្រាយ, រូប,រូបរាង រាងរៅ បែបភាព ។ មាឌ (អ.ថ. មាត) ន. (សំ.កិ. ាស់; ក្លឹង; ក្បុង;ទ. រង្វាស់, ទម្ងន់, ប្រមាណ, ចំនួន) ទំហំ ។ មហាសិន្ធុ (ម. មហាសិន្ធុ ) ទន្លេ, ស្ទឹង, សមុទ្រ, ធ្លារទឹកធំ ។ មហាជលមាលា ន. ផ្លូវទឹកធំ ។ សីសប្រភព ន. (ម. សីសប្បភវ ) ដែនកើត, ទីកើតនៃក្បាល, មានក្បាលហូរចេញមក ។ មហាបព៌ត ន. ភ្នំធំ ។ សម្ពន្ធវង្ស ន. វង្សដែលជាប់គ្នា ៗ មកអំពីដាប់, វង្សដែលជាប់ទាក់ទងនឹងគ្នា ។ ហិមពាន្ត ន.

(ពាក្យក្លាយមកពីបាលីថា ហិមវន្ត "មានទឹកសន្សើម" <ហិមវន្ត រ >ព, ព > ៣) ភ្នំមានទឹកសន្សើម ។ សព្វថ្ងៃនេះ ហៅថា ភ្នំហិមាល័យ ឬ ហិមាលយា ហិមាល័យ ឬ ហិមាលយា ជាពាក្យសំស្ក្រឹតនឹងមគធៈ ( <ហិម "ទឹកសន្សើម" + អាលយ "លំនៅ" "លំនៅនៃទឹកសន្សើម" ។ **អាណាចក្រ** ន. ទេ... ដែនដែលនៅក្នុងអំណាចការគ្រប់គ្រងនៃមហាក្សត្រឬរដ្ឋាភិបាលមួយ ៗ (ម.អាណា ចក្ក) ។ **វិកាល** គុ. ដែលខុះខាត, មិនគ្រប់គ្រាន់ ។ **វិបរិត** គុ. ដែល ប្រែប្រួល, ផ្លាស់ប្រែ, ដែលមិនពិត, ដែលជាទំនាស់នឹងគ្នា, ដែលផ្សេងគ្នា ។ ន. ដំណើរប្រែប្រួល, ការផ្លាស់ប្រែ (ម.វិបរីត) ។ **ជលបថ** ន. ផ្លូវទឹក ។ **ឧបស័គ្គ** ន. គ្រឿងទើសទាក់ ។ **នាវា** ន. ទូក, សំពៅ ។ **បូព៌ា** ទិស ន. ទិសខាងដើម, ទិសខាងមុខ, ទិសខាងកើត ។

---

# ទោសនៃសេចក្តីខ្ជិល

*សត្វនិករក្នុងត្រៃភព សុទ្ធសឹងតែចង់បានសេចក្តីសុខ ស្អប់ ខ្ពើមសេចក្តីទុក្ខ, ចង់បានទ្រព្យសម្បត្តិ ធុញទ្រាន់នឹងសេចក្តី ទាលក្រ, ចង់បេះដូង ស្អប់ខ្ពើមសេចក្តីល្ងង់, ចង់បានបាន:*

ន៍ខ្ពស់ ខ្វាបអោបានៈហោកតាប, ស្រឡាញ់នេះស្អប់នោះ
ប៊ីនប្រការអេប្បមាណ ៗ អ្នកខ្លះបានសម្រេច សមតាម
ណង អ្នកខ្លះមិនបានសម្រេចឡើយ ៗ អ្នកដែលមិន
ានសម្រេចសមតាមបំណង មកតែពីសេចក្ដីខ្ជិល ៗ សេចក្ដី
លជាទោសជាតនាំបំផ្លិចបំផ្លាញ នូវផលប្រយោជន៍ ទាំងផ្លូវ
ហាកទាំងផ្លូវធម៌ នាំឲ្យវេតឃ្លាតចាកការងារជាគាតព្វកិច្ច ដែល
ាំងមនុស្សជាតិឲ្យមានដំណើរឆ្ពោះទៅកាន់វឌ្ឍនធម៌ និងអារ្យ·
ម៌ ៗ នរជនណាធ្វេសប្រហែសបណ្ដោយឲ្យសេចក្ដីខ្ជិលជះ
ាន់ញាំញីបានហើយ នរជននោះមិនសម្រេចសមតាមសេចក្ដី
បាថ្នាឡើយ ៗ

មនុស្សខ្ជិល សូម្បីខ្លួនជាកម្លោះក្រមុំមានកម្លាំងបរិបូណ៌ក៏
នបង់ធ្វើការអ្វី បើទុកជាធ្វើអ្វីក៏ធ្វើដោយខ្ជីខ្ជា បែបជ្រលៀក
ណាគហៅថា សិថិលបរក្កមៈ គឺព្យាយាមធូរ ៗ ៗ មនុស្សខ្ជិល
នះ ទៅជាអ្នកល្ងង់ខ្លៅ ទៅជាអ្នកក្រីក្រ ៗ សេចក្ដីទ័លក្រ

នាំចិត្តឲ្យអាក្រក់ ចិត្តអាក្រក់ និយាយអាក្រក់ ធ្វើការងារអាក្រ
គឺរកស៊ីធ្វើចោរ យក្ស មារ លេងល្បែងពាលា បៀរប៉ោ
អាប៉ោង ឯបុកពាក់ប្រឡោងខាមរទិងរទាំង មិនមានសណ្ដា
ធ្លាប់ល្អ ។ ហេតុនេះ នរជនទាំងឡាយ គួរលះបង់នូវកោសជ្
ចេញ ហើយខំបំពេញសេចក្ដីព្យាយាមឲ្យមាំមួនឡើង ។

## ពន្យល់ពាក្យ

សត្តនិកាយ ន- ពួកសត្វ ។ ត្រៃភព ( ម. តិភវ ) ភព
( ទីសម្រាប់ពួកសត្វកើត ហៅថា ភព ) ភព ៣ គឺកាមភព ១ រូបភព
អរូបភព ១ ។ កាមភពមាន ១១ ជាន់ គឺ ឋានសួគ៌ ៦ ជាន់
ឋានមនុស្ស ១, អបាយភូមិ ៤, រូបភពមាន ១៦ ជាន់, អរូបភពមាន ៤ ជាន់
អប្បមាណា គុ- ដែលប្រមាណពុំបាន, ដែលរាប់ពុំអស់ ។ កាតព្វ
កិច្ច ន. កិច្ចការដែលគួរធ្វើ, ដែលត្រូវធ្វើ ។ សិថិលបរក្កមៈ
ន. សេចក្ដីព្យាយាមធូរ, សេចក្ដីប្រឹងប្រែងធូរ, តេ្បីយ, យ៉ាងពោះតើយ,
យ៉ាងប៉ករវើយ ។ កោសជ្ជៈ ន. សេចក្ដីខ្ជិល, សេចក្ដីខ្ជិលច្រអូស ។

# សេចក្ដីព្យាយាម

សេចក្ដីព្យាយាម ជាគុណធម៌ដ៏ឧត្ដម ជាធម៌ជ្រោមជ្រែង
បានសេចក្ដីសុខក្សេមក្សាន្ត ឲ្យបានចំរើនកុះករបរិបូណ៌ដោយ
ណៈវិជ្ជា សេចក្ដីឈ្លាសវៃ និងទ្រព្យសម្បត្តិគ្រប់យ៉ាងទាំងអស់
បារមីមួយយ៉ាង ហៅថា វីរិយបារមី ដែលព្រះជិនស្រីអប់រំ
ទៀមកអស់ជាតិជាអនេក ដរាបដល់បានបរមាភិសេកជាព្រះ
ញ្ញពុទ្ធ ជាមកុដត្រៃលោក និងជាជំហរ ឬជាពានទ្រនូវ
ប្ញុទ្ធការគ្រប់ប្រការ ហៅថា វីរិយិទ្ធិបាទ ។ សេចក្ដីព្យាយាម
គុណនាំឲ្យសម្រេចផលប្រយោជន៍ ជាអនេកប្បការ តាម
មគ្គដល់ឧបនិស្ស័យវាសនា របស់ខ្លួនពិតប្រាកដ ។

កុលបុត្ត កុលធីតា ត្រូវតែព្យាយាមសិក្សារៀនសូត្រទាំង
ញ្ញជិតទាំងគ្រហស្ថ ឲ្យចេះដឹងគ្រប់គ្នា កុំបណ្ដោយខ្លួនឲ្យល្ងង់
ៗ បើមានសិស្សគណកូនចៅត្រូវឲ្យរៀនសូត្រសព្វសាស្ត្រវិជ្ជា
ងឡាយ តាំងពីកាលនៅជាកុមារ កុមារី កំពុងមាននិស្ស័យ

ទន់ខ្ចី អាចបង្អោនចិត្តផ្តិតយកវិជ្ជាថ្មីបានដោយងាយ ដូចគំនូ
ដែលគេគូរនឹងកាដន់ថ្មី ហើយសឹមយកទៅដុតឱ្យឆ្អិន តែងជាប
ឋិតថេរបីរកាលស្ថាពរតទៅអនាគតយូរអង្វែង ៗ ហេតុនេះ ត្រូ
តែប្រឹងប្រែងរៀសរវៃប្រកបការងារ កុំឱ្យពេលវេលាកន្លងទៅ
ដោយភ្លេចស្មារតី ត្រូវតែខំឃ្មាតខ្មីសិក្សារៀនសូត្រ, រកទ្រព្យ
សម្បត្តិធ្វើបុណ្យសុន្ទរទាន រក្សាសីល ធ្វើជីវិតឱ្យថ្លៃថ្នូរ កុំបង្អ
បង្អង់អល់អែកស្ទាក់ស្ទើរ ត្រូវមានស្មារតីជានិច្ច ក្នុងយប់មួយថ្ង
មួយ ត្រូវមានឧបាយកលកិច្ចគិតតែលៃលករកប្រយោជន៍ដល់ខ្លួ
ធ្វើខ្លួនឱ្យជាមនុស្សទាន់សម័យ គេធ្វើអ្វីដែលជាអំពើឥតទោស
ពៃរ៍ទេ យើងត្រូវគ្នាន់គ្នេរធ្វើនឹងគេដែរ កុំឱ្យធ្ងន់នឹងក្អក លោក
ធ្វើការគ្រប់ចំពូក ត្រូវប្រយ័ត្នកុំឱ្យភ្លេចស្មារតី គួរខំឃ្មាតខ្មីស្រវា
ស្រទេញធ្វើការនោះ ឱ្យបានសម្រេចកុំបីខាន ៗ

## ពន្យល់ពាក្យ

ព្យាយាម ន. (សំ.វ្យាយាម; ម.ភិយាម) សេចក្ដីខំប្រឹងប្រែង,ការ

ងប្រែង, ដំណើរខ្មីឃ្លាត, សង្ងាត ។ ខ្មែរប្រើជា កិ. ខំប្រឹង, សង្ងាត ។

ណាជមិន. ធម៌ដែលមានដំណើរបំរើនសេចក្ដីសុខទុក្ខតាមជាន់តាមថ្នាក់

នខាងអំពើល្អអាក្រក់ដែលបុគ្គលធ្វើ, សេចក្ដីល្អ ។ ក្សេមក្សាន្ត គុ.

ប់.) ដែលមានសេចក្ដីសុខសាន្ត ។ បារមី ន. គុណជាតិដ៏ល្អដែល

គ្គលគួរបំពេញ ឬចរិយាដ៏ប្រសើរលើសដែលបុគ្គលគួរបំពេញ មាន ១០ យ៉ាងគឺ

១– ទាន: ការឲ្យទាន;

២– សីល: ការរក្សាកាយវាចាឲ្យរៀបរយបរិសុទ្ធល្អ;

៣– នេក្ខម្ម: ការចេញចាកកាម គឺការបួស;

៤– បញ្ញា ការដឹងច្បាស់នូវសេចក្ដីពិត,

៥– វីរិយ: ព្យាយាម,

៦– ខន្តិ: អំណត់;

៧– សច្ច: ការកាន់ពាក្យពិត,

៨– អធិដ្ឋាន: ការតាំងចិត្តឲ្យឃើញជាក់ស្តែងតាមការណ៍ពិត ,

៩– មេត្តា ការផ្សាយសេចក្ដីរាប់អានចំពោះសព្វសត្វមិនរើសមុខ,

១០– ឧបេក្ខា ដំណើរតាំងចិត្តព្រងើយដោយស្មើស្មោះ ។

*ទសពិធបារមី* (បារមីទាំង ១០ ប្រការ) នេះឯង ព្រះពោធិសត្វគ្រប់
ព្រះអង្គបំពេញគ្រប់គ្រាន់ហើយបានត្រាស់ជាព្រះពុទ្ធ ។ **ជិនស្រី** ន. (សំ, , ម
ជិន+សិរី) លោកអ្នកឈ្នះមានសិរីសួស្តី (ព្រះពុទ្ធ) ។ **បរមាភិសេក** ន.
ការអភិសេកដ៏ឧត្តម គឺការបានត្រាស់នៃព្រះសម្មាសម្ពុទ្ធ ដែលពួកទេវតាត្រេកអរ
សាទរបាចសាចផ្កាទិព្វផ្សេង ៗ ទាំងរលាស់ទឹកក្រអូប បូជាថ្វាយជ័យមង្គល ។
**សំបុទ្ធិការ** ន. ការសម្រេចផល-សម្រេចប្រយោជន៍ ។ **វិរឡិទ្ធិធាន**
ន. ជំហរនៃសេចក្ដីសម្រេច, សេចក្ដីចំរើន ។ **ឧបនិស្ស័យ** ន. កុសល
ធម៌ដែលកើតឬអាស្រ័យនៅក្នុងខន្ធសន្ដាន គឺកុសលដែលបានកសាងសន្សំអប់រំទុក
មក, សំណាង, ភ័ព្វព្រេងសំណាង ។ **វាសនា** ន. ចរិយា ឬ ចរិត
ដែលអប់រំសន្សំទុកក្នុងចិត្ត, ចរិយាដែលជ្ជក់ស៊ាំជាប់ជាទម្លាប់កែប្រែ ឬ លះបង់
ចេញមិនបាន ។ ប៉ុន្តែខ្មែរប្រើពាក្យនេះសំដៅសេចក្ដីថា "ភ័ព្វព្រេងសំណាង" ។
**កុលបុត្ត** ន. កូនប្រុសរបស់ត្រកូល, កូនប្រុសអ្នកមានត្រកូល ។ **កុល-
ធីតា** ន. កូនស្រីនៃត្រកូល, កូនស្រីអ្នកមានត្រកូល ។ **សិស្សគណ** ន.
ពួកសិស្ស ។ **សព្វសាស្ត្រវិជ្ជា** ន. បំណេះវិជ្ជាក្បួនច្បាប់ក្រឹត្យក្រមគ្រប់
យ៉ាង ។ **និស្ស័យ** ន. ធម៌ជាទីនៅអាស្រ័យ, ដំណើរនៅអាស្រ័យ ។

សុវណ្ណធាន ន. ទានល្អ, អំណោយដែលឲ្យដោយប្រពៃ ។ ស្មារតី ន. (ម. សតិ) សេចក្ដីនឹកឃើញ, ការរលឹកបាន, ការរលឹកឃើញមិនភ្លេច; ការចាំបាន, ការប្រុងប្រយ័ត្នមិនភ្លេច ។ ឧបាយ ន. (សំ.ម.) ល្បិចល្បង, កិច្ចកល ។ ឧបាយកល ន. ល្បិចល្បងយ៉ាងល្អិត ។ វៃរ៍ ន. (សំ.វៃរ; ម.វេរ) ពៀរ, ពំនៀរ ។ ប្រើជាបរិវារពាក្យទោស ជា *ទោសវៃរ៍* ទោសនឹងពៀរ ។

---

# ចិត្តជាទេវទត្ត មាត់ជាទេវតា

*សុភាសិតនេះពុទ្ធសាសនិកជន សឹងជ្រាបស្រាប់ហើយ ដោយធ្លាប់បានស្ដាប់អ្នកប្រាជ្ញ ជាធម្មកថិកសំដែងជារឿយ ៗ ។ ទេវទត្តជាឈ្មោះភិក្ខុមួយរូប ជាព្រះអនុជជីដូនមួយនឹងព្រះពិជិត-មារសក្យមុនីគោតមបរមសាស្ដា (ប៉ែកខាងព្រះវរមាតាព្រះអង្គ) ។ ទេវទត្តនេះ, កាលដើមឡើយ ជាអ្នកមានបសន្នចិត្តក្នុងព្រះពុទ្ធ-សាសនា បានស្ម័គ្រចិត្តចូលបួសជាមួយនឹងក្សត្រិយ៍ ៥ អង្គ គឺ ភទ្ទិយសក្យរាជ ១ អនុរុទ្ធ ១ អានន្ទ ១ ភគុ ១ កិម្ពិល ១ លុះបួស*

ហើយមិនយូរប៉ុន្មាន ជាអចិរប្បត្តជិត កំតាំងចិត្តជាសត្រូវ ជាមិត្តទ្រុស្តប្រទូស្តចំពោះព្រះសមុទ្ទ ខំប្រឹងព្យាយាមទនះនរនាខសម្លាប់ព្រះអគ្គិ ប៉ុន្តែមិនសម្រេចដូចបំណង ត្រាតែព្រះធរណីស្រូបខ្លួនទៅ ។

អ្នកប្រាជ្ញបុរាណាចារ្យរបស់យើង បានដឹងរឿងរ៉ាវនេះហើយ ទើបប្រឌិតភាសិតនេះឡើងថា "ចិត្តជាទេវទត្ត មាត់ជាទេវតា" ដោយសំដៅសេចក្តីថា មនុស្សទ្រុះមិត្រចិត្តអាក្រក់ប្រហែលនឹងទេវទត្ត ប៉ុន្តែសំដីដែលចេញពីមាត់ទន់ផ្អែមពីរោះ គួរនឹងឲ្យទុកចិត្តថាពិតប្រាកដដូចជាសំដីទេវតា ។ មនុស្សទុជ៌នតែងនិយាយសំដីពីរោះផ្អែមល្ហែម គួរជាទីពេញចិត្ត តែបុគ្គលកុំគប្បីលង់គំនិតស័គ្រស្មាគមស្មោះស្មានរាប់អានជាមិត្រស្និទ្ធស្នេហ៍ ដោយហេតុត្រាន់តែសំដីពីរោះនោះឡើយ ។ សំដីពីរោះប្រៀបដូចមធុរសជិតនៅចុងអណ្តាត ឯក្នុងចិត្តវិញ ពេញពោរដោយពិសពុលដ៏ក្តៅក្រហាយ ។

# ពន្យល់ពាក្យ

ធម្មកថិកា ន. អ្នកសំដែងនូវធម៌ ។ ពិជិតមារ ន. (ម. វិជិតមារ) លោកអ្នកឈ្នះមារ (មានមារឈ្នះហើយ) ។ ព្រះឈ្នះមារ ។ សក្យមុនី ន. អ្នកប្រាជ្ញរបស់ពួកសក្យៈ (ព្រះសមណគោតមបរមសាស្តា) ។ បសន្នចិត្ត គុ. ដែលមានចិត្តជ្រះថ្លា ។ ស្ម័គ្រចិត្ត ក. ពេញចិត្តពីខ្លួនឯងឥតអ្នកណាបង្ខំ ។ អចិរប្បព្វជិត គុ. ដែលបួសហើយ អស់កាលមិនយូរប៉ុន្មាន (ទើបតែនឹងបួស) ។ មិត្តទ្រុស្ត គុ. ដែលទ្រុស្តមិត្រ ។ ប្រទុស្ត ក. (ម. បទុដ្ឋ, សំ. ប្រទុស្ត) បៀតបៀន, ធ្វើឲ្យវិនាស ។ ឆឆះឆរឆាឆ ក. គគាគឈ្លានពាន, គឃ្លើន ។ ធរណី ន. ផែនដី ។ បោរាណាចារ្យ ន. អាចារ្យមានក្នុងកាលមុន ឬ កាលពីដើម ។ ប្រឌិត ក. តាំងឡើង, ផ្ដើមឡើង ។ ទ្រុះមិត្រ ន. អ្នកបៀតបៀនមិត្រ អ្នករករឿងបៀតបៀនមិត្រ, អ្នកចង់ឲ្យមិត្រវិនាស ។ ទ្រុះ (< សំ. ទ្រុហ, ហ>:= ទ្រុះ) បៀតបៀន, ស្អប់, ចងគំនុំ ។ ពាក្យថា ទ្រុស្តមិត្រ នឹង ទ្រុះមិត្រ ទាំងពីរយ៉ាងនេះប្រើបានដូចគ្នាព្រោះថាក្នុងពាក្យ មិត្តទ្រុស្ត

សរសេរបានពីរយ៉ាងដែរ សរសេរជា មិត្តទ្រុះ ក៏បាន ។ ស្មគ្រស្មាគម ន. (ម. សមគ្គ + សមាគម, សំ. សមគ្រ + សមាគម " ការមកជួបជុំ " ការប្រជុំ, ការរួបរួមគំនិតគ្នា ") ។ ក្នុងទីនេះប្រើជា កិ. ពេញចិត្តរួមគំនិតធ្វើកិច្ចការជាមួយ ។ ស្មោះស្មាន កិ. រាប់អានដោយត្រង់អស់ពីចិត្តឥតកិច្ចកលមាយា ។ ស្និទ្ធ គុ. (សំ សិគ្ធ. ម. សិនិទ្ធ) ដែលជាទីស្រឡាញ់, ជាទីពេញចិត្ត ។ ប្រើជា កិ. ស្រឡាញ់អស់ពីចិត្តឥតរង្កៀស, ស្រឡាញ់ទុកចិត្តស៊ប់ ។ ស្នេហ៍ ន. (សំ. ស្នេហា, ម. សិនេហ) សេចក្ដីស្រឡាញ់ ។ មធុរស រសទឹកឃ្មុំ, រសផ្អែម, រសឆ្ងាញ់ ។

---

## ការស្វែងរកទីពឹង

នៅប្រទេសខ្មែរ កម្ពុជាផនកាន់ព្រះពុទ្ធសាសនាយូរយារមកហើយ នៅតែមានមនុស្សខ្លះក័ន្តប្រឡំប្រកាន់ជឿអារក្សអ្នកតាទេពារក្សព្រៃភ្នំក្រឹបនៅឡើយ ព្រោះហេតុនេះហើយបានជាក្នុងមួយឆ្នាំ ៗ គេឃើញអ្នកលៀងអារក្ស ទំវាយស្គរគូតទ្រ ប្រគំដេញដំលាន់ឮទ្រហឹង ស្ទើរគ្រប់ភូមិស្រុក មកពីជំនឿប្រាស

ដោយហេតុផល ជាជំនឿខុសឆ្គាំងល្ងៀងឆ្ងៀងឃ្លាតពីសេចក្ដី ពិត បណ្ឌិតធម្មកោវិទមិនរាប់ជំនឿបែបនេះថា ត្រឹមត្រូវតាមផ្លូវ ពុទ្ធសាសនាទេ ។ តាមច្បាប់ព្រះពុទ្ធសាសនាថា អ្នកណា មានភ័យសេចក្ដីតក់ស្លុតរន្ធត់មកគម្រាម ហើយរត់ទៅបន់ស្រន់ ទេពារក្ស, អារក្ស, អ្នកតា នោះមិនឈ្មោះថា ស្វែងរកនូវទីពឹង ដើម្បីខ្លួនឡើយ ។

លុះតែអ្នកណាមួយ បានដល់នូវព្រះត្រៃរ័ត្ន គឺព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃ ជាទីពឹងពំនាក់អាស្រ័យ ពិចារណា ឃើញច្បាស់នូវចតុរារិយសច្ច ដោយវិចារណបញ្ញាដ៏ប្រពៃ អ្នក នោះទើបឈ្មោះថាស្វែងរកនូវទីពឹងដ៏ក្សេម ជាទីពឹងដ៏ឧត្ដម ។ ពុទ្ធសាសនិកជនរមែងរួចស្រឡះ ចាកទុក្ខភ័យឧបទ្រពចង្រៃទាំង ពួង ព្រោះអាស្រ័យនូវទីពឹងនោះឯង ។

## ពន្យល់ពាក្យ

កម្ពុជជន ន. ជនអ្នកនៅក្នុងប្រទេសកម្ពុជា ។ អារក្ស (ម.

អារក្ខ) ការបីបាច់, ការថែទាំរក្សា, ការគ្រប់គ្រង, ការជួយរក្សាគាំពារ, ការរក្សាការពារ ។ ខ្មែរប្រើពាក្យ **អារក្ស** នេះ ជាឈ្មោះខ្មោចល្បាក់សា, ខ្មោចមេមត់, ឬ បិសាច, អសុរកាយ ដោយសំដៅសេចក្ដីថា " ខ្មោចអ្នកបីបាច់រក្សា " ។ **អ្នកតា** ន. អ្នកជីតា ។ ពាក្យសម្រាប់ហៅខ្មោចពិសាចប្រុស ឬ ទេវារក្សប្រុសដែលមានខ្ទម ឬ រោងអាស្រមជាលំនៅ ឬ ឥតលំនៅក៏មាន ។ **ទេវារក្ស** ន. (សំ. ទេវ + អារក្ស, ម. ទេវ + អារក្ខ) ទេពតាអ្នករក្សាមនុស្ស ឬ រក្សាអ្វី ៗ ។ កុំសរសេរជា **ទេព្វារក្ស** ន. ខុសឃ្លាតឆ្ងាយណាស់ ។ **ធម្មគោរវ** ន. អ្នកល្បុកសរៃក្នុងធម៌ ។ **ត្រៃរត្ន** ន. (សំ. ត្រិរត្ន, ម. តិរតន) រតនៈ ៣ គឺ ព្រះពុទ្ធ, ព្រះធម៌ និង ព្រះសង្ឃ ។ *រតនៈ* ប្រែថា " វត្ថុ ឬ របស់ដែលញុំាងចិត្តឲ្យរីករាយ " ។ **ចតុរារិយសច្ច** ន. ពាក្យសម្រាប់ហៅនូវអរិយសច្ចទាំង ៤ ដោយរួបរួម ។ អរិយសច្ចទាំង ៤ នោះគឺ *ទុក្ខៈ* សេចក្ដីព្រួយលំបាក, *សមុទយ* កំណើតនៃសេចក្ដីទុក្ខ, *និរោធៈ* សេចក្ដីរលត់ទុក្ខ, *មគ្គៈ* ឧបាយជាគ្រឿងរំលត់ទុក្ខ ។ **វិចារណបញ្ញា** ន. ប្រាជ្ញាសម្រាប់ពិចារណា ។ **ឧបទ្រព** ន. (សំ. ឧបទ្រវ. ម. ឧបទ្ទវ) ចង្រៃ, គ្រោះកាច, ភ័យ, អន្តរាយ, ហេតុអាក្រក់ ។

# មេត្តាព្រហ្មវិហារ

មេត្តាធម៌ ជាសាកលណីយធម៌ដ៏ប្រសើរបំផុត ក្នុងព្រះពុទ្ធសាសនា ជាធម៌ញុំាងនរជនឲ្យរួចរដោះចាកពៀរ ព្យាបាទ គឺការគុំគួនប្រមាថប្រទូសរ៉ាយអ្នកដទៃ ឲ្យរួចចាកចង្រៃឧបទ្រពគ្រប់ប្រការ ឲ្យបានសន្តិសុខសម្រាន្តនឹងសុវត្ថិភាពសព្វកាល ។ មេត្តាធម៌នេះជាសស្ត្រាវុធមួយយ៉ាងពូកែស័ក្តិសិទ្ធ ដែលបណ្ឌិតហៅថា មេត្តាវុធ សម្រាប់កាប់ផ្តាក់រំលើងនូវឧបក្កិលេស មានក្រោធៈ ដែលជាមូលហេតុនៃព្យាបាទជាដើម; ជាធម៌ដ៏ត្រជាក់សម្រាប់រម្ងាប់នូវអធិករណ៍ នឹងការវិវាទប្រកួតប្រកាន់គ្រប់ប្រភេទ ជាធម៌ប្រៀបដូចជាទឹកបន្សាប សម្រាប់ផ្សារមិត្តភាពរវាងប្រជាករទូទៅ ឲ្យមូលមិត្តព្រមព្រៀងស្រុះស្រួលនឹងគ្នា ទាំងជាធម៌សម្រាប់ផ្សះផ្សាសត្វលោក ដែលប្រេះឆាបែកខ្ញែកគ្នា ឲ្យមានសាមគ្គីព្រមព្រៀងស្និទ្ធស្នាលនឹងគ្នាជានិរន្តរ៍ ។ មេត្តាធម៌នេះមានផលានិសង្សជាក់ច្បាស់ ក្នុងបច្ចុប្បន្ននឹងបរលោក ។

អ្នកចំរើនមេត្តាគប្បីពិចារណារឿយ ៗ ថា ធម្មតាមនុស្សក្នុងលោកនេះ មានគេស្រឡាញ់ មានគេស្អប់ មនុស្សមួយរូប ៗ មិនមែនសុទ្ធតែគេស្រឡាញ់ ឬគេស្អប់ទាំងអស់គ្នាទេ, ជួនកាលមនុស្សដែលយើងស្អប់ ក៏គង់មានគេស្រឡាញ់រាប់អាន; ជួនកាលមនុស្សដែលយើងស្រឡាញ់រាប់អាន ក៏មានគេស្អប់ ៗ យ៉ាងទៀត គប្បីពិចារណាឲ្យញឹកញយថា "មនុស្សនោះទោះបីគ្មានគុណសម្បត្តិសមត្ថភាព ឬ សេចក្ដីល្អដល់អាត្មាអញក៏ពិតមែន ប៉ុន្តែគេមានសេចក្ដីល្អណាមួយ ដល់អ្នកដទៃឯទៀតខ្លះមិនខាន បើមិនច្រើនក៏តិច" ៗ កាលបើពិចារណាយ៉ាងនេះហើយ គួរតាំងមេត្តាចិត្តផ្សាយ ចំពោះសត្វក្នុងលោកទាំងអស់ គួរតាំងអធ្យាស្រ័យបំពេញសាមគ្គីរសស្មោះសររកគ្នាឲ្យបរិបូណ៌ឡើង ៗ

## ពន្យល់ពាក្យ

សារាណីយធម៌ ន. ធម៌គួរនឹករលឹក, ធម៌ដែលគួរនឹកមិនភ្លេច។

ចាំនៀរ ន. ពៀរ. ដំណើរចងពៀរ ។ ព្យាបាទ ន. ដំណើរចង

ត្តិតធ្វើអ្នកដទៃឲ្យវិនាស, សេចក្តីគុំគួន, គំនុំ ។ សុវត្ថិភាព ន. ការមានសួស្តី, ការប្រកបដោយសេចក្តីសុខ ។ សស្ត្រាវុធ ន. គ្រឿងប្រដាប់ធ្វើដោយដែក មានមុខមុត មានកាំបិតផ្គាក់ ដាវ លំពែងជាដើម, គ្រឿងប្រក្តឹនឹងអាវុធ ។ ឧបក្កិលេស ន. គ្រឿងសៅហ្មង, សេចក្តីមិនបរិសុទ្ធ, មន្ទិល, គ្រឿងសៅហ្មងចិត្ត ។ អភិជ្ឈា, ព្យាបាទ, សេចក្តីក្រោធជាដើម ជាឧបក្កិលេស ។ អធិករណ៍ ន. ការអាងហេតុផល, ទាស, រឿងហេតុ, ជម្លោះ, ការទាស់ទែងខ្វែងគំនិតគ្នា, ការប្តឹងប្រកាន់គ្នា ។ ិវាទ ន. ដំណើរទាស់ទែងគ្នា, ដំណើរឈ្លោះគ្នា, ដំណើរឈ្លោះប្រកែកគ្នា ។ ិវាទាធិករណ៍ ន. អធិករណ៍ដែលកើតព្រោះដំណើរទាស់មាត់ពាក្យគ្នា, ការឈ្លោះព្រោះសំដី ។ ប្រជាការ ន. ពពួកសត្វ ។ ផលានិសង្ស ន. អានិសង្សនៃផល, ការហូរមកនៃផលគឺសេចក្តីសុខសេចក្តីចំរើនដែលកើតអំពីផល ។ គុណសម្បត្តិ ន. សេចក្តីដល់ព្រមដោយគុណ, ការបរិបូណ៌ដោយសេចក្តីល្អ ។ សមត្ថភាព ន. ភាពនៃសេចក្តីអាចហាន, សេចក្តីអង់អាច, សេចក្តីមុះមុត ។

## រឿងនាងវិសាខា

នាងវិសាខា ជាធីតានៃធនញ្ជយសេដ្ឋី នឹងនាងទេវី ឈ្មោះ

សុមនា ត្រូវជាចៅរបស់មេណ្ឌកសេដ្ឋី ក្នុងនគរឈ្មោះភទ្ទិយៈ អង្គរដ្ឋ ។ នាងជាស្ត្រីភាពកបកល្យាណី បរិបូណ៌ដោយលក្ខណា កុំថាតែមនុស្ស ទោះទេវតា មារ ព្រហ្ម យម យក្ស ក៏ទាន សរសើរនាងពុំបាន នាងជាស្ត្រីមានសទ្ធានចិត្តស្អិតនៅក្នុងធម៌ មានបុញ្ញាកិទីយារដ៏បវរ ល្អគ្រប់សព្វឥតមានខ្ចោះសោះឡើយ ។ កាលដែលនាងមានអាយុ ១៦ ឆ្នាំ មេណ្ឌកសេដ្ឋីជាជីតាបានប្រើ នាងព្រមទាំងពួកទាសីប្រាំរយរូបជាបរិវារ ឲ្យចេញទៅធ្វើបច្ចុគ្គ-មនាការព្រះសក្យមុនីទសពល ដែលយាងមកដល់នគរខ្លួន ដោយក្បួនរថដ៏អឹកអធឹក ៗ ព្រះទសពលទ្រង់ឆ្លុះញាណយល់ឧបនិស្សយ-សម្បត្តិរបស់នាងប្រត្យក្សជាក់ច្បាស់ ទើបទ្រង់ត្រាស់សំដែងធម៌ប្រោសប្រទានដល់នាង ព្រមទាំងពួកស្ត្រីជាបរិស័ទ ដើម្បីបំបាត់ទុក្ខភ័យ ៖ បាទវ៉ឧបទ្រពក្នុងភពវដ្តសង្សារ លុះចប់ព្រះធម៌ទេសនា សេដ្ឋីជីតាក៏បានលុះសោតាបត្តិផលដំកល់ចិត្តស៊ប់ក្នុងអចលសទ្ធា ឯពួកបរិវារគ្រប់គ្នា ក៏បានសម្រេចធម្មាភិសម័យ

តាមសមគួរដល់ឧបនិស្ស័យវាសនា ដែលបានកសាងសន្សំ
អប់រំទុកមកពីក្នុងបុរេជាតិ ដោយសារកុសលធម៌ជាញាតិមិត្រគួរ
ឲ្យមានសម្ភាពន៍ជាអស្ចារ្យ ដែលពួកពុទ្ធបរិស័ទកល់គ្នាខំធ្វើដោយ
ចិត្តពិតប្រាកដ ដែលដល់កាលកំណត់ តែងចេញមុខឲ្យផល
ាដែលខាន ។

## ពន្យល់ពាក្យ

វិសាខា ន. ឈ្មោះរបស់ស្រីម្នាក់ជាមហាឧបាសិកាក្នុងព្រះពុទ្ធសាសនា ជា
បដ្ឋាយិការបស់ព្រះសក្យមុនីសម្ពុទ្ធ បានកសាងវត្តបុព្វារាមជិតក្រុងសាវត្ថីថ្វាយព្រះ
ហស្ដ ។ ធីតា ន. ស្ត្រីដែលមាតាបិតាទ្រទ្រង់, កូនស្រី ។ ធនញ្ជយ-
សេដ្ឋី ន. ឈ្មោះសេដ្ឋីម្នាក់ជាកូនរបស់មេណ្ឌកសេដ្ឋី ។ ទេវី ន. ភរិយាធំ។
សុមនា ន. អ៊ិះរួត ។ ឈ្មោះកូនប្រសាស្រីរបស់មេណ្ឌកសេដ្ឋីជាមាតានៃនាង
សាខា ។ មេណ្ឌកសេដ្ឋី ន. សេដ្ឋីឈ្មោះមេណ្ឌកៈ ។ សេដ្ឋីនេះបានជា
ឈ្មោះ មេណ្ឌកៈ ដូច្នេះ ព្រោះមានរឿងដំណាលថា មានរូបពពែមាសជាច្រើន
នដំរីខ្លះ ប៉ុនសេះខ្លះ ប៉ុនគោបាខ្លះ ប្រជ្រៀតប៉ះខ្នងគ្នាផុសទម្លុះផែនប្រឹថពីលេច
ឡើងមីរជើរជាស ជាគ្រឿងប្រកាសនូវបុញ្ញកម្មរបស់លោក ក្នុងទីប្រហែលប្រវែង
ប្រាំបីករីសៈ ជាខាងក្រោយគេហស្ថានរបស់លោក ។ មានឆ្នុកសូត្រប្រាំព័ណ៌ពុក

មាត់ពពៃទាំងនោះ ។ បើសេដ្ឋីត្រូវការរបស់អ្វី នោះជាភោជ្ជភ័ក្ត្រ ទឹកដោះ ប្រេង ទឹកឃ្មុំ ស្ករអំពៅ ឬត្រូវការសំលៀកបំពាក់ គ្រឿងប្រាក់មាស ត្បូង ពេជ្រជាដើមក្ដី សេដ្ឋីគ្រាន់តែមានប្រសាសន៍ឲ្យគេដកឆ្នុកពីមាត់ពពៃចេញ , វត្ថុដែលត្រូវការទាំងប៉ុន្មាននោះ ហូរចេញមកឥតខ្វះសោះឡើយ ។ ព្រោះតែលោកមានបុណ្យអស្ចារ្យយ៉ាងនេះឯង បានជាលោកមានល្បីរន្ទឺលេចឮទាំងថា **មេណ្ឌកសេដ្ឋី** ដូច្នេះ ។ សេដ្ឋីនេះមានបុណ្យសន្សំមកពីក្នុងជាតិមុនច្រើនណាស់ (បើមានឱកាស សូមរកមើលរឿងប្រវត្តិរបស់លោក ក្នុងគម្ពីរព្រះធម្មបទដ្ឋកថាភាគ៣ត្រង់រឿងនាងវិសាខា ទំព័រ ៧៩; ភាគ ៧ ត្រង់រឿងមេណ្ឌកសេដ្ឋី ទំព័រ ៦៣ នឹងបានឃើញសេចក្ដីអស្ចារ្យប្លែកៗ ដែលគួរគ្បីសរសើរភ័ព្វព្រេងសំណាងរបស់លោក) ។ **ភទ្ទិយ** ន. ដែនឈ្មោះអង្គៈ ។ ឈ្មោះដែនដែលសេដ្ឋីខាងលើនេះនៅ ។ **កល្យាណី** គុ. ដែលមានលំអគួររាប់អាន ។ **លក្ខណា** ន. គ្រឿងសំគាល់; គុណ-សម្បត្តិ ។ ស្ត្រីមានលក្ខណ៍ គឺមានឫកពាកិរិយាមារយាទសណ្ដាប់ធ្នាប់ល្អ ។ **បុញ្ញាភិនីហារ** ន. (ម. បុញ្ញ “បុណ្យ” + អភិនីហារ “ការតាំងចិត្តប្រាថ្នា, សេចក្ដីប្រាថ្នា, បំណង, ការកសាងសន្សំ, ការអប់រំ”) ការកសាងសន្សំបុណ្យ សេចក្ដីប្រាថ្នាដ៏ក្លៀវក្លាចំពោះទៅរកបុណ្យ, បុណ្យដែលអាចឲ្យសម្រេចសេចក្ដីសុខសមតាមប្រាថ្នា ។ **ជីតា** ន. ឪពុករបស់មាតាបិតា ។ **ទាសី** ន. បាវស្រី, ខ្ញុំស្រី ។ **បរិចារៈ** ន. អ្នកហោមរោមកំដរ, អ្នកហែហមអមកំដរ, អ្នកត្រៀមខ្លួន

ប៊ើ ។ **បច្ចុគ្គមនាការ** ន. អាការៈនៃកិរិយាទទួល, អាការគឺកិរិយាទៅទទួល ឬ ក្រោកទទួល ។ **ទសពល** គុ. ដែលមានកម្លាំង១០គឺមានកម្លាំងស្មើនឹងដំរីដំរីសេស ១០ ។ ន. ព្រះសម្មាសម្ពុទ្ធ, ព្រះទសពល ។ **រេច** (អ.ថ. ត់) ន.រទេះដែលគេទឹមដោយសេះ, រទេះសេះ ។ **ឧបនិស្សយសម្បត្តិ** ន. ការដល់ព្រម ឬការបរិបូរណ៍ដោយឧបនិស្ស័យ ។ **ឧចាជ៌រ** (អ.ថ. អ៊ុជាត) ន. ឧបទ្រព, ចង្រៃ (ពាក្យនេះក្លាយមកពីឧបទ្ទវ) ។ **វដ្តសង្សារ** ន. (ម. វដ្ដ "ដែលវិលមូល, ដែលជាវង់មូល" + សំសារ "ដំណើរអន្ទោលទៅមក, ការអន្ទោលកើតស្លាប់ឥតឈប់ឥតស្រាក") ដំណើរអន្ទោលវិលស្លាប់វិលកើត ។ **សេដ្ឋីធីតា** ន. (ម. សេដ្ឋី+ធីតា) កូនស្រីរបស់អ្នកមានទ្រព្យស្តុកស្តម្ភ, កូនស្រីរបស់សេដ្ឋី ។ **សោតាបត្តិផល** ន. ឈ្មោះលោកុត្តរធម៌ដើមខ្សែថ្នាក់លេខ ២ ។ **អចលសទ្ធា** (អ.ថ. អៈចៈលៈសទ្ធា) ន. ការជឿស៊ប់មិនកម្រើក, មិនកក្រើក, មិនរំភើប គឺការជឿស៊ប់ឥតងាកបែរ ។ **បរិវារ** ន. (ដូចគ្នានឹង បរិពារ ម. ព. នោះ) ។ **ទារិកា** ន. (ម.) ក្មេងស្រី, កុមារី ។ **ធម្មាភិសម័យ** ន. ការត្រាស់ដឹងនូវធម៌, ការបានសម្រេចនូវមគ្គនិងផល, ការដឹងជាក់ ឬ ការយល់ច្បាស់នូវសច្ចធម៌ ។ **បុរេជាតិ**

ន. ជាតិមុន ។ សម្ភាពន៍ ន. ( ម. សម្ភាវន ) ការស្ញើចសរសើរ
សេចក្ដីសរសើរ ។ អស្ចារ្យ គុ. (ម, អច្ឆរិយ) ដែលគួរកោត, គួរសរសើរ
គួរស្ញើច ។ សុទ្ធចិត្ត ន. ចិត្តស្អាត, ចិត្តផូរផង់, ចិត្តឥតមន្ទិល, ចិត្តស្មោះ
ស្មើ, ចិត្តជ្រះ, ចិត្តបរិសុទ្ធ ។

---

# ក្រុងឧដុង្គមានជ័យ

ព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី ជាព្រះរាជ
អយ្យកោល្អតនៃព្រះករុណា ជាអម្ចាស់ជីវិត ព្រះប្រិយមហាក្សត្រ
ជាប្រមុខរដ្ឋសព្វថ្ងៃនេះទ្រង់សោយរាជ្យគ្រប់គ្រងកម្ពុជរដ្ឋ តាំង
ព្រះបរមរាជវាំងសារពើយុត្ត មានប្រាសាទជាព្រះរាជនិវេសន៍ទាំ
ម័យ នៅក្រុងឧដុង្គមានជ័យ ជាព្រះរាជធានីមួយចាស់មុនគ
ចតុម្មុខ គឺក្រុងភ្នំពេញសព្វថ្ងៃនេះ ។ បុរាណរាជធានីនោះ ចិ
នៅក្នុងទិសពាយ័ព្យឆៀងឧត្តរនៃក្រុងបច្ចុប្បន្ន សព្វថ្ងៃជាឈ្មោះ
ស្រុកមួយ ហៅថា ស្រុកឧដុង្គ ក្នុងទីរួមខេត្តកំពង់ស្ពឺ ជាក្រុ
មានភូមិភាគរាបស្មើ ស្ទើរតែសព្វអន្លើ វៀរលែងតែបព្វតជួ

ទីនក្នុំព្រះរាជទ្រព្យចេញ ។ នៅលើកំពូលបពិត្រព្រះរាជទ្រព្យ មានមហាចេតិយដ្ឋាននានា សុទ្ធសឹងវិចិត្រដោយក្បូរក្បាច់ចេនា ជាស្នាដៃនៃពួករាជវង្សក៏ ជាអ្នកជំនាញការក្នុងគ្រានោះ ជាចេតិយសម្រាប់បញ្ចុះអដ្ឋិធាតុ នៃព្រះរាជានឹងព្រះអភិអគ្គមហេសី ព្រមទាំងក្សត្រាក្សត្រីជាបុព្វបុរសរបស់ព្រះរាជវង្សខ្មែរ ។ ក្រុងឧដុង្គមានវត្តអារាមជាច្រើនដែលជានិវេសនដ្ឋាន នៃពួកស្រមណ៍បព្វជិត បណ្ឌិត កវី ជាអាចារ្យបព្វាចារ្យរបស់ជាតិយើង ។

## ពន្យល់ពាក្យ

ហរិរក្ស ន. (សំ < ហរិ "ព្រះនារាយណ៍, ព្រះឥន្ទ, ព្រះអាទិត្យ, សីហៈ, មាស, សម្បុរបៃតង, ពណ៌លឿង" + រក្ស "អ្នករក្សា") អ្នកក្សាព្រះនារាយណ៍ ។ ជាព្រះបរមនាម នៃព្រះករុណាជាអម្ចាស់ជីវិតមួយព្រះអង្គទ្រង់សោយរាជ្យ គង់នៅក្រុងឧដុង្គមានជ័យ ព្រះបាទសម្ដេចព្រះហរិរក្សរាមា ឥស្សរ-ធិបតី ។ រាជអយ្យកោលួត ន. ជីតាលួត, តាលួត (សម្រាប់ប្រើតែក្នុងរាជស័ព្ទ) ។ ប្រិយមហាក្សត្រ ន. មហាក្សត្រជាទីស្រឡាញ់ ។ ប្រមុខរដ្ឋ ន. ព្រះរាជាជាប្រធានរបស់រដ្ឋ (រាស្ត្រ) ។ សារពើយុត្ត

គុ. ( សំ. សរិ. + យុក្តៈ ម. សព្វ + យុត្ត ) ដែលប្រកបដោយលំអគ្រប់យ៉ាង រាជនិវេសន៍ ន. លំនៅរបស់ព្រះរាជា, ព្រះរាជវាំង ។ ទារុម័យ គុ ដែលគេធ្វើដោយឈើ, ធំហើយដោយឈើ ។ បព្វតដ្ឋាន ន. កន្លែងនៃ ភ្នំ ។ មហាចេតិយដ្ឋាន ន. កន្លែងនៃមហាចេតិយ ។ វិចិត្រ គុ ដែលលាយចំរុះ ឬ វិសេសព័ណ៌ៈ ដែលវិសេស ឬ ឆ្លាស់ក្បាច់រចនា, ដែលឆ្លុះឆ្លាស់ ល្អប្លែក ៗ ប្រើជា គុ. ក៏មាន ៗ អដ្ឋិធាតុ ន. ឆ្អឹងដែលធ្វើឈាបនកិ សុសហើយ ។ អភិអគ្គមហេសី ន. ព្រះអគ្គមហេសីដែលមានតៃ ឬដែលថ្លៃថ្លា គឺ ខត្តិយកញ្ញា ជាព្រះអគ្គមហេសី ដែលបានមុទ្ធាភិសេករួមរាជាសន ជាមួយនឹងព្រះរាជា ជាព្រះរាជស្វាមី ៗ ការី ន. អ្នកប្រាជ្ញដែលចេះតែ ឆន្ទ, កាព្យឃ្លោង, អ្នកមានថ្វីមាត់, អ្នកប្រាជ្ញខាងសំដី ៗ អាចារ្យប្បា ចារ្យ ន. អាចារ្យជាប្រធានរបស់អាចារ្យ ឬអាចារ្យរបស់អាចារ្យ ៗ អាចារ្យ ន. ( សំ. អាចាយ៌, ម. អាចរិយ ) អ្នកប្រព្រឹត្តល្អ, អ្នកដែលសិស្សត្រូវគោរព អ្នកធ្វើប្រយោជន៍ដល់សិស្ស, អ្នកបង្រៀនចំណេះគេ, គ្រូបង្រៀន ។

---

## រឿងចូឡធនុគ្គហបណ្ឌិត

មានមាណពម្នាក់ មិនប្រាកដជាគោត្តនិងនាមអ្វី បើ

នៅក្នុងក្រុងពារាណសី ដែលសព្វថ្ងៃហៅតាមភាគភូមិសាស្ត្រ ផែនទីលោកថា បេណារេស ក្បែរស្រុកកលិង្គរាស្ត្រ ឆៀងខាងទិសបូព៌ានៃមជ្ឈិមប្បទេស ។ មាណពនោះ និរាសប្រាសចាកគ្រឹហាស្ថាន ស្វះស្វែងកាត់ស្រុកតូចធំ និគម ជនបទ រាជធានី ខេត្តខណ្ឌសីមា ទៅដល់ក្រុងតក្កសិលា ដែលសម័យឥឡូវហៅថាអហ្វូឃានិស្ថង់ ក្នុងបច្ចិមទិសប្រទេសវិហារ បានចូលទៅសិក្សាធនុគ្គហសាស្ត្រ ក្នុងសំណាក់អាចារ្យទិសាបាមោក្ខ មិនយូរប៉ុន្មាន ក៏បានចេះស្ទាត់ជំនាញក្នុងការបាញ់ធ្នូ ទើបបាននាមប្រាកដ ដែលអាចារ្យសន្មតថា ចូឡធនុគ្គហបណ្ឌិត មានចំណេះវិជ្ជាសក្តិសិទ្ធិ ពិតពេញបុកពាកិរិយាមារយាទសុចរិត ស្រគត់ស្រគំ សមរមពន់ប្រមាណ; អាចារ្យមានមនោរម្យជាអារម្មណ៍ប្រាសចាកសេចក្តីបារម្ភ ទើបឧបត្ថម្ភប្រគល់ធីតាខ្លួនឲ្យជាភរិយាទុកជាកេរ្តិ៍មតិកពីអាចារ្យមក ។

អំណើះកាលតមកខាងក្រោយ មាណពនោះលោគ្រូនាំ

ភរិយាត្រឡប់ទៅកាន់ជាតិភូមិវិញ ត្រាច់ចរដោយបាទចារ កាត់ផងព្រៃមហាវ័ន ស្រាប់តែជួបប្រទះនឹងចោរហាសិបនាក់ បានបាញ់សម្លាប់អស់ នៅសល់តែចោរជេដ្ឋម្នាក់ លុះអស់ព្រួញទើបស្ទុះផ្លោះណោតទៅប្រវាយប្រតប់គ្នាទៅវិញទៅមក ។ ស្វាមីស្រែកហៅភរិយាឲ្យហុចដាវមកឲ្យ ឯភរិយាជាស្ត្រីមានចិត្តក្បត់ប្រតិពទ្ធចំពោះមេចោរ បានហុចដាវខាងដងឲ្យទៅចោរ ខាងផ្លែទៅភស្តាខ្លួន មេចោរគន្ត្រាក់បានដាវ ក៏ប្រហារពិឃាតស្វាមីស្លាប់ក្នុងមហារណ្យនោះទៅ ។

## ពន្យល់ពាក្យ

ចូឡធនុគ្គហបណ្ឌិត ន. បណ្ឌិតឈ្មោះចូឡធនុគ្គហៈ; បណ្ឌិតនេះបានជាឈ្មោះដូច្នេះ, ព្រោះគាត់ជាអ្នករៀនខាងបាញ់ធ្នូ លុះអស់បំណេះអំពីគ្រូហើយ ទើបគ្រូឲ្យឈ្មោះតាមបំណេះដែលខ្លួនរៀនចេះនោះ ។ មាណព ន. (ម. មាណវ) ប្រុសកម្លោះ, បុរសធំទង់ ។ គោត្ត ន. វង្ស, ត្រកូល, សែ ។ ពារាណសី ន. ឈ្មោះរាជធានីមួយ ក្នុងដែនកាសី ( ប្រទេស–

តណ្ឌៀ) ក្នុងពុទ្ធសម័យ ។ កាលិង្គរាស្ត្រ ន. (សំ.) ដែនកលិង្គ ។

ទិសបុព្វា ន. ទិសខាងកើត ។ ទិស ន. ភាគ, ចំណែកមុខ ក្រោយ ឆ្វេង ស្តាំ ព្រមទាំងជ្រុងជាចន្លោះទាំងបួន និងខាងលើ ខាងក្រោម ឬត្រង់កណ្តាល រួមជា ១០ គឺ

១- បុព្វ ឬ បុព្វា ខាងដើម ខាងមុខ, ខាងកើត, ទិសខាងកើត ។ ប្រើជា បុព្វទិស ឬ បុរត្ថទិស ក៏បាន ។

២- អាគ្នេយ៍ ន. (សំ. អាគ្នេយ) ទិសដែលអគ្និទេពគ្រប់គ្រង គឺទិសដែលតាំងនៅត្រង់ចន្លោះទិសខាងកើតនិងខាងត្បូង ។

៣- ទក្ខិណា (ស. ថ. ទ័កសិន) ន. ទិសខាងស្តាំ, ទិសខាងត្បូង ។ ទិសនេះនៅប្រទល់គ្នា នឹងទិសឧត្តរ (ខាងជើង) ។ ប្រើជា ទក្ខិណាទិស ឬ ទក្ខិណទិស ក៏បាន ។

៤- និរតី ន. ឈ្មោះទិសតូចនៅត្រង់ចន្លោះទិសខាងត្បូងនឹងខាងលិច ។

៥- បស្ចិម ន. ទិសខាងក្រោយ, ទិសខាងលិច ។ ជួនកាលប្រើជា បស្ចិមទិស ឬ បច្ឆិមទិស ក៏បាន ។

៦- ពាយព្យ ន. ទិសដែលនៅត្រង់រវាងទិសខាងលិចនិងខាងជើង ។

៧- **ឧត្តរ** ន. ទិសខាងឆ្វេង, ទិសខាងបុង, ទិសខាងជើង ។ ជួនកាលប្រើជា **ឧត្តរទិស** ក៏មាន ។

៨-ឦសាន ន. ទិសព្រះឥសូរ គឺទិសដែលនៅត្រង់ចន្លោះទិសខាងជើងនិងខាងកើត ។

៩-ខាងលើ (ម. ឧបរិមទិស, អ. ថ. ឧប៉ះរ៉ិមៈទិស) ។

១០-ខាងក្រោម (ម. ហេដ្ឋិមទិស អ. ថ. ហេត ថិមៈ ទិស) ។

គ្រឹហាស្ថាន ន. ផ្ទះ, លំនៅ ។ និគម ន. ប្រជុំភូមិច្រើន ។ **ជនបទ** ន. ទីប្រជុំជន គឺទីដែលមានប្រជាជនកុះករ មានអ្នករាជការរដ្ឋបាលកាន់កាប់រក្សា បានដល់ទីរួមខេត្ត ។ **រាជធានី** ន. ទីក្រុងដែលព្រះរាជាគង់នៅ ។ **ខេត្ត** ន. ស្រែ, ភាគផែនដីដែលចែកជាអន្លើ ៗ ។ **ខណ្ឌ** ន. សង្កាត់, ប៉ែក ។ នាទីដែលមានឃុំច្រើនឡើង ហើយដែលមានចៅហ្វាយខណ្ឌកាន់កាប់រក្សា. សព្វថ្ងៃហៅថា ស្រុក ។

សីមា ន. ទីព្រំ, ព្រំប្រទល់, ព្រំដែន, ព្រំដី ។ តក្កសិលា ន. ឈ្មោះក្រុងមួយ នៅប្រទេសឥណ្ឌា ។ ធនុគ្គហសាស្ត្រ ន. វិជ្ជា ឬក្បួនតម្រាខាងការបាញ់ធ្នូ ។ អាចារ្យ ន. អាចារ្យអ្នកបង្រៀន ។

**សាស្ត្រ** ន. ច្បួន, ច្បាប់, វិជ្ជា, ការសិក្សា ។ **ទិសាបាមោក្ខ** ន. អាចារ្យជាប្រធានក្នុងទិស, អាចារ្យជាប្រធាននៃសិស្សគ្រប់ទិស គឺអាចារ្យចំបង ដែលចេះវិជ្ជាសម្រាប់ប្រើ តាមសម័យនិយម ជាអ្នកអាចបង្ហាត់បង្រៀនពួកសិស្ស ដែលកាត់មកពីគ្រប់ទិសតំបន់ ។ រោងរៀន ឬសាលារៀនរបស់អាចារ្យនោះ ហៅថា សាលាទិសាបាមោក្ខ (អ. ឋ.-ប៉ាម៉ោក)។ **មនោរម** គុ. ដែលជាទីរីករាយចិត្ត, ដែលគួរឲ្យសប្បាយចិត្ត ។ **អារម្មណ៍** ន គ្រឿងពោងចិត្ត, គ្រឿងទង់ទាញចិត្ត, គំនិត, ការដឹង . . . ។ **ចារិក្ក** ន. ដំណើរនឹកចប់ ឬនឹកព្រួយជាមុន ។ **ឧបត្ថម្ភ** ន. ប្រើជាកិ. ជួយទំនុកបំរុង ។ **បាទចារ** ន. ការដើរដោយជើង (ឥតយានជំនិះ) ។ **ចោរជេដ្ឋក** ន. ចោរជាធំ, ជាច្បង, ជាបំផង, មេចោរ ។ **ប្រតិពទ្ធ** កិ. ស្រឡាញ់ជាប់ចិត្ត ។ **ភស្តា** ន. (ម.ភត្តា<ភត្តុ) ប្ដី ស្វាមី ។

---

# ហប់នេះហប់នោះមិនឆ្ពោះត្រង់ណា (១)

## បទកាកគតិ

**នរជនចូរចាំ បុរាណលោកផ្ដាំ ពាក្យពិតមួយម៉ាត់ ត្រូវ**

---

១- ស្រង់ពីសៀវភៅកិច្ចសិក្សាសាលាវត្ត ឆ្នាំ ១៩៤៣ ។

យើងគេក្បា ទុកកុំឲ្យបាត់ គ្រាន់នឹងលះកាត់ ទូរចិត្តស្រើប ស្រាល ៗ ថាអ្នករៀនសូត្រ មិនត្រូវស្ទុះស្រូត តាមចិត្ត ត្រអាល ចាប់នេះចាប់នោះ មិនព្រោះគ្រប់កាល ផ្អើលក្បាក់កល ដាល មិនពិតប្រាកដ ៗ បើរៀនបែបនេះ លោកថាមិនផែះ គ្មានបានហ្មត់ចត់ លំបាកតែកាយ នាំឲ្យនឿយហត់ លោក ទាយកំណត់ ថាគ្មានបំណាច់ ៗ មនុស្សណាសស្វិត រៀន តាំងពីកើត ទល់គ្នានឹងស្លាប់ ក៏នៅតែស្ទើរ មិនពិតគ្រប់ច្បាប់ គ្មានបានស្វាហាប់ មាំទាំក្នុងកាយ ៗ មនុស្សចិត្តសាហ៊ី តែង នាំអាត្មា ឲ្យក្ដៅក្រហាយ ដុតដាលពេលពល វិនាសអន្តរាយ ដូចមានអធិប្បាយ ក្នុងរឿងមួយនេះ ៗ រឿងនោះដទៃ យក មកឧបមេយ្យ ឲ្យឃើញដូច្នេះ ថាមនុស្សសាហ៊ី រៀនអ្វីមិន ចេះ ចាប់អ្វីចេះ គ្មានផែះទាំងអស់ ៗ

# រឿងបូទ្យផន្គុហបណ្ឌិត

## បទព្រហ្មគីតិ

ក្នុងអតីតកាល      មានដំណាលរឿងប្រត្យក្ស
ព្រាហ្មណម្នាក់      ឈ្មោះបូទ្យផន្គុហ: ។
នៅក្រុងពារាណសី      លុះដឹងក្តីកើតវិតក្ក:
ចង់ទៅរៀនសិល្ប:      ឯដែនតក្កសិលា ។
បានចូលទៅសូមរៀន      មន្តរបៀនដែលត្រូវការ
ក្នុងសំណាក់អាចារ្យ      ឈ្មោះថាទិសាបាមោក្ខ ។
លុះរៀនបានបេះពិត      គាត់ប្រសិទ្ធិជ័យជោគ
ល្បងមើលសិល្បផ្លូវលោក      ជាប់ប្រយោគយ៉ាងគួរសម ។
អាចារ្យស្រឡាញ់ណាស់      ឃើញសិស្សច្បាស់ជាមួនមាំ
យកធីតាមកផ្សំ      រៀបចំឲ្យជាភរិយា ។
បុរសនោះឯងណា      លាអាចារ្យនាំភរិយា
ដើរកាត់ព្រៃព្រឹក្សា      គិតប្រាថ្នាទៅស្រុកខ្លួន ។

លុះអស់ស្បៀងចំណី ឃើញដំរីធំមាំមួន
បុរសលបចាំពួន បាញ់ត្រូវខ្លួនដំរីក្ស័យ ។
ហើយថានាងបំអិន បរិភោគសិនណាបរណៃ
សឹមយើងត្រាច់រំពៃ ដើរកាត់ព្រៃមាសវរល័ក្សណ៍ ។
លុះស្រេចកិច្ចភោគ្គា ខំយាត្រាឥតសម្រាក
ជួបចោរហាសិបនាក់ ចាំវាយស្ទាក់យកធីតា ។
ស្វាមីខឹងគ្នាន់គ្នាញ់ ចាប់ព្រួញបាញ់ឥតតក្កមា
ត្រូវចោរស្លាប់អសារ រាប់ឃើញថានៅសល់ម្នាក់ ។
លុះអស់ព្រួញពីខ្លួន ប្រាប់ថាស្ងួនកែវវរល័ក្សណ៍
ហុចដាវមកសម្ងះ កាប់ចោរម្នាក់ឲ្យក្សីណក្ស័យ ។
ឯស្រីចិត្តសាហ៊ំ កើតស្នេហាអាក្រក់ក្រៃ
ឃើញចោរហ៊ានតដៃ ស្ត្រីចង្រៃលង់គំនិត ។
ផ្គងចិត្តគិតដូច្នេះ ថាចោរនេះគ្មានភ័យភិត
ហ៊ានស៊ូប្ដូរជីវិត ស្លាប់មិនគិតព្រោះតែអញ ។

ដូច្នេះគួរអញយក ចោរនោះមកជាសម្លាញ់
ទើបស្រួលជាន់ប្ដីអញ ហើយក៏បាញ់ចិត្តបំណាន់ ។
ហុចផ្លែដាវទៅប្ដី ចោរអប្រិយឲ្យខាន់ជន់
ចោរគ្មានគិតសៅហ្មង ផ្ដាច់សុនបុរសក្ស័យ ។

# ពន្យល់ពាក្យ

គាគតិ ន. ដំណើរនៃក្អែក, ដំណើរក្អែកហោត ។ ជាឈ្មោះបទកាព្យពាក្យបួន របស់ខ្មែរយើង ។ ស្វាហាប់ (សំ. ស្វាហាបតិ “ព្រះអគ្គិ”) ន. ប្រើជា កិ. សំដៅសេចក្ដីថា “មាំមួន, រឹងប៉ឹង, ម៉ឺងម៉ាត់” ។ សាវ៉ា គុ. ដែលឆាប់រើរុះ, ដែលរាយមាយតែពាស, ដែលមិនប្រាកដ ។ អតីតកាល ន, កាលដែលកន្លងទៅហើយ, កាលពីព្រេងនាយ ។ ប្រារភ កិ. ផ្ដួចផ្ដើម, ផ្គងចំពោះ, រៀបរប ។ វិតក្កៈ ន. សេចក្ដីត្រិះរិះការជញ្ជឹង, រំពឹង ។ ខ្មែរប្រើជា កិ. ក៏មាន ដូចក្នុងផ្ទៃរឿងនេះជាដើម “ត្រិះរិះ, គិត, ជញ្ជឹង, រំពឹង” ។ សិល្បៈ ន. សិល្បៈ ។ ជំនាង, ការជាងផ្សេង ៗ, ហត្ថកម្មគ្រប់យ៉ាង, បំណេះដែលត្រូវសិក្សា មានការជាងឈើ, ការឆ្លាក់,

គូរ, រៀបឥដ្ឋ, បូកបាយអ រហូតដល់ការបង្ហាត់ដំរី, សេះ និងបំណោះខាងភ្លេងតន្ត្រី, ចម្រៀង រាំជាដើម ឬ ការរចនាវិចិត្រផ្សេង ៗ ហៅថា **សិប្បៈ** ឬ **សិល្បៈ** ទាំងអស់ ។ **មន្ត** ន. ពាក្យដែលបងក្រងជារបៀបសម្រាប់សូត្រសែកស្ដោះផ្លុំ ឬ ពាក្យសក្តិសិទ្ធិ សម្រាប់សូត្រប្រសិទ្ធិឲ្យកើតសុខសួស្ដី ។ **រៀន** ន. បំណេះដែលចេះព្រោះបានរៀន ។ សិល្បសាស្ត្រ, មន្ត, វិជ្ជាការ, អាគម, គាថា ហៅថា **រៀន** ៗ **ប្រសិទ្ធិ** ន. ការពាក់តែង, ការធ្វើឲ្យសម្រេច ។ ខ្មែរយើងប្រើជា កិ. សំដៅសេចក្ដីថា "ធ្វើឲ្យសម្រេច, ធ្វើឲ្យពូកែ, ធ្វើឲ្យមានសិរីសួស្ដី " ។ **ក្ស័យ** ន. ការអស់ទៅ (ម. ខយ) ។ ខ្មែរប្រើជា កិ. សំដៅសេចក្ដីថា "អស់ជីវិត, ស្លាប់ " ។ **ចរណៃ** គុ. ឬ ន. កែវ ឬត្បូងដែលគេច្នៃរួចហើយ ។ បុរសប្រៀបស្ត្រីទៅនឹងកែវចរណៃដោយអាងសេចក្ដីថាគួរភ្ញាក់ភ្ញម, គួរថែទាំរក្សាឲ្យបានល្អដូចជាកែវចរណៃ ។ ច្រើនប្រើតែក្នុងពាក្យកាព្យ ។ **ភោក្តា** កិ. (សំ, ភុក្ត. ម. ភុត្ត) បរិភោគរួចហើយ, ស៊ីផឹករួចស្រេចហើយ ។ **យាត្រា** ន. ការដើរ, ការចេញចរ ។ ប្រើជា កិ. "ដើរ, ចេញចរ" ។ **អសារ** គុ. ដែលឥតប្រយោជន៍, ឥតអំពើ ។ **វរលក្សណ៍** ន. លក្ខណៈដ៏ប្រសើរ ។ គុ. ដែលមានលក្ខណៈដ៏ខ្ពង់ខ្ពស់, ដែលមានលក្ខណៈគួរជ្រះថ្លា ។ **សម្មៈ** ន. សម្លាញ់ ។ **ក្សីណក្ស័យ** ន. ការបាត់បង់

ក្សូន្យទៅ ។ ប្រើជា កិ. "ស្លាប់" ។ ស្នេហា ន. សេចក្តីស្រឡាញ់ជាប់
ចិត្តស្អិតដូចជ័រ ។ អប្រិយ កិ. ដែលមិនជាទីស្រឡាញ់, ដែលពុំគួរស្រឡាញ់ ។
សុរជ៍ ន. ក ។

---

# រឿងបុប្ផទុគ្គហបណ្ឌិត (ត)

មេហោរនាំពីតា ស្និទ្ធស្នេហាតាមជនព្រៃ
លុះដល់ស្ពឹងមួយនៃ ហោរនឹកភ័យខ្លាចស្លាប់ខ្លួន ។
ហើយពិចារណាថា ស្រីនេះណាមិននឹងខ្លួន
ហ៊ានសម្លាប់ប្តីខ្លួន មុខជាផ្តួនដល់អញទៀត ។
ហោរគិតឃើញសព្វគ្រប់ ហើយក៏ឈប់លែងហ៊ានបៀត
ថាស្រីនេះហោលម្យៀត គួរអញឃ្លៀតលែងរាទៅ ។
លុះកេទបាយបាន ថាកល្យាណបូរនាងទៅ
ចង់យកអីវ៉ាន់ពៅ ហោលឆ្លងទៅដាក់ត្រើយនាយ ។
ចាំមរៀមមកចម្លង យកទូនល្អង់ឡើងរាងាយ
យើងហែលទឹកសប្បាយ ហើយគៀកកាយគ្នាលេងផង ។

ចោរយកទ្រព្យរបស់ សព្វគ្រប់អស់ហើយហៃលឆ្ងន
ផល់គោកស្រែកថាហង កុំមួហ្ងអញណាហើយ ៗ
នៃមេកញ្ញើជុះ ឃើញតែប្រុសបេះតែដោយ
អញលៃងហានឯងហើយ កុំសោកឡើយណាមាសមេ ៗ
ស្ត្រីកាឡកណ្ណី ព្ធោរស្តីប្រទេចដេរ
ខឹងគួលក្ងនកាយេ ថាអ្នកមេម្ចាស់ប្អូនអើយ ៗ
អាណិតយកប្អូនផង ប្អូរៀមបងកុំទុកឡើយ
ប្អូននៅតែឯងហើយ ណាអ្នកអើយអាស្អូរពៅ ៗ
មេចោរស្រែកប្រាប់ថា មេសាក៉ៃង៉ងកុំហៅ
អញទុកមេឱ្យនៅ ក្នុងព្រៃជ្រៅឥតសោកា ៗ
លុះចោរគេចទៅបាត់ នាងសោកក្តាត់ក្តៅកាយា
យំសោ៊ងរៀបរាប់ថា ឱអនិច្ចា ស្តាយអើយស្តាយ ៗ
បើអញយកប្តីមុន មិនខុសស៊ិននៅមេម៉ាយ
ដូចអាចោរអន្តពាយ ខាតទាំងកាយខូចទាំងកេរ្តិ៍ ៗ

ក្រោយដែលទួញរៀបរាប់ នាងរម្ងាប់ទុក្ខការយេ

និត្យនៅខ្លួនទទេ ក្បែរទីផ្នូរស្ពឹងនោះឯង ។

## ពន្យល់ពាក្យ

ពិចារណា ន. ការត្រិះរិះ, រំពឹង, គិត, ជញ្ជឹង ។ ខ្មែរយើងប្រើជា កិ. « ត្រិះរិះ, រំពឹង, គិត, ត្រេះគិត »។ កល្យាណ គុ. ដែលមានលំអគួររាប់អាន, គួរស្រឡាញ់ ។ សោកា ន. (ម. សោក) សេចក្ដីឈឺផ្សាចិត្ត សេចក្ដីស្ដាយស្រណោះ ។ ប្រើជា កិ. " ស្ដាយស្រណោះ, អាណោះអាល័យ " ។ អន្តរាយ ន. ធម៌ដែលមកក្នុងរវាងនៃបុគ្គិនឹងបដិសន្ធិ, ហេតុដែលមកដំទាស់ក្នុងចន្លោះ ឬក្នុងពាក់កណ្ដាល, សេចក្ដីទើសទាក់, ដំណើរខូចប្រយោជន៍, សេចក្ដីវិនាស ។ ខ្មែរប្រើជា កិ. ផង សំដៅសេចក្ដីថា " វិនាស, ខូច, ហិនហោច " ។

---

## រឿងបូទ្រធនុគ្គហបណ្ឌិត (តចប់)

គ្រានោះសហស្សនេត្ត ទ្រង់សង្កេតឃើញជាក់ស្ដែង
ក៏ចុះចាកកន្លែង មកក្លែងធ្វើចចកចាស់ ។
ពាំសាច់មួយដុំធំ ភ្ដោះមកចំនាងឃើញច្បាស់

ទេវបុត្រមួយទៀតផ្លាស់ ប្រែក្រឡាស់ខ្លួនជាត្រី ។
ឡើងពីទឹកងងាស(១) បបកចាស់បានឃើញត្រី
ហោលសាប់ស្ទុះទៅខ្ចី ប្រុងចាប់ត្រីត្រីលោតបាត់ ។
មានទេវបុត្រមួយទៀត មកឈ្លបឈ្លៀតក្លែងជាសត្វ
ខ្លែងមួយធំពេកក្តាត់ ឆាបសាច់បាត់ពីកន្លែង ។
បបកបែរស្ទុះមក ប្រាថ្នាយកសាច់នោះឯង
ស្រាប់តែអ្នកបាទខ្លែង ឆាបបំប្លែងយកបាត់ទៅ ។
នាំឃើញបបកចាស់ ប្រឹងស្ទុះណាស់ក្នុងព្រៃជ្រៅ
រកសាច់ដែលបាត់ទៅ ហើយឈប់នៅហត់ញ័រកាយ ។
ក៏នឹកអស់សំណើច ណាន់មាត់សើចខ្លាំងក្អាកក្អាយ
ភ្លេចគិតដល់រូបកាយ ដែលសហាយធ្វើដូច្នេះ ។
បបកបែរមកស្តី ថាឃើញស្រីចង្រៃនេះ
សើចអីក៏ស្រួលម៉្លេះ ខ្មោចមេផែះមិនខ្មាសគេ

---

១ អ. បិ.គគ្គ: ។

បើនៅទីនេះឯង គ្មានឃើញល្បែងរបាំទេ
ឬក៏ប្រៀនបំពេ គ្មានសោះទេតើសើចអ្វី ?
ស្ត្រីប្រាប់ថាអញសើច នឹងអាខ្មោចឯងគិតខ្លី
ពោលសាប់ស្រស់ថ្មី ៗ ស្រកត្រី ត្រីរត់ស្វាត់ ៗ
ហើយវិលមកកន្លែង ស្រាប់តែខ្លួនឆាបសាប់បាត់
ឯងរត់ញ៉ាខ្លួនក្តាត់ រកសាប់បាត់បានអញសើច ៗ
ចចកថាទោសគេ ម្តេចក៏មេអស់សំណើច
ត្រង់ទោសខ្លួនហិនហោច នៅត្រមោចម្តេចមិនគិត ៗ
ពីតាស្តាប់ឮច្បាស់ ថាប្រសាសន៍នេះត្រូវពិត
បំភឿនខ្ញុំប្រព្រឹត្ត ហិនអស់មិត្រពិតមែនហើយ ៗ

## ពន្យល់ពាក្យ

សហស្សនេត្ត ន. អ្នកមានភ្នែកមួយពាន់, អ្នកមានភ្នែកច្រើន គឺអ្នកដែលអាចពិចារណា ឬប្រមើលឃើញហេតុយ៉ាងច្រើនបានភ្លាម ៗ (ព្រះឥន្ទ្រ)។

ក្លែង កិ. ធ្វើឲ្យប្លែកពីរូបដើមទៅជារូបរាងថ្មី ដើម្បីកុំឲ្យគេស្គាល់ ។

និយាយបង្វែងដានឲ្យខុសជាកសំដីដើម ដើម្បីកុំឲ្យគេដឹង ។ **សង្កេត** ន. (ម.) ការណាត់គ្នា, ការមត់គ្នា, ការពិនិត្យ, ការកំណត់ដឹង ។ ខ្មែរប្រើជា កិ. សំដៅសេចក្ដីថា "រំពឹងមើល, ពិនិត្យមើល, មៀងមើល" ។ **ទេវបុត្ត** ន. កូនប្រុសរបស់ទេវតា, ទេវតាប្រុស ។ **ក្រាឡាស់** កិ. ប្រែខ្មែរ, ផ្លាស់ ។ **ខ្លែង** ន. ឈ្មោះសត្វ ។ **សហាយ** ន. (ម.) សម្លាញ់, មិត្រសម្លាញ់, អ្នកដែលទៅមកជាមួយគ្នា ។ **ត្រមោច** កិ. វិ. ឯកឯង, នៅតែឯង, នៅកំព្រាក្នុងទីស្ងាត់តែឯង ។ **ប្រសាសន៍** ន. ពាក្យបង្គាប់, ពាក្យផ្ដាំផ្ញើ, បណ្ដាំ ។ ខ្មែរយើងប្រើពាក្យនេះបំពោះតែ សំដីរបស់អ្នកធំ ។

---

# ដំបូន្មាន

## (បទកាកគតិ)

*ហេតុនេះអ្នកស្ដាប់ កុំយកតម្រាប់ តាមរឿងនេះណា ទោះបី*
*រៀនសូត្រ ឬមួយធ្វើការ ត្រូវចាប់ត្រង់ណា ឲ្យខ្ជាប់ត្រង់ណោះ ។*
*កុំគ្រាន់តែល ឃើញជូនដើរង សុះរត់លោតផ្លោះ*

ឃើញស្រាលស្រួលងាយ លូកចាប់ច្បោះ ៗ មិនសម្រេចអស់ ដើរចោលទៅទៀត ៗ កុំគ្រាន់តែសាក ដឹងថាពិបាក លះបង់ចោលម្យៀត ឃើញគេបានល្អ ទើបប្រឹងម្តងទៀត ដឹងថាបង្អៀត រត់លែងងាកក្រោយ ៗ កុំកាន់ធូរ ៗ ស្មានចាប់ជាយូរ ប្រាសចោលកន្តើយ ឃើញគេបានស្រួល ទៅប្រឹងបង្ហើយ មិនទាន់ដល់ត្រើយ រត់លែងងាកមុខ ៗ កុំចាប់ស្ទើរស្ទាក់ ស្មានថាច្បាស់ជាក់ ហើយបង្អាក់ទុក ដល់ខ្លួនត្រូវការ ស្រាប់តែរពុក ប្រើការទៅមុខ មិនកើតសោះឡើយ ៗ

## ពាក្យពន្យល់

ពិបាក គុ. ធ្វើបានដោយកម្រ; លំបាក ។ វិបាក ន. ផល, ផលកម្ម. សេចក្តីទុក្ខ ។

## រឿងពោធិរាជកុមារ

ពោធិរាជកុមារ ជាព្រះរាជបុត្រានៃព្រះបាទមាគធសេនិយ-ពិម្ពិសារ ព្រះចៅក្រុងរាជគ្រឹះ មគធរដ្ឋ មជ្ឈិមប្រទេស ភាគ

កណ្តាល ៗ ព្រះអង្គម្ចាស់នេះ មានព្រះប្រីជាញាណនឹង សមត្ថភាព មួយអន្លើដោយចំណេះវិជ្ជាដ៏ពិចិត្រ តែទ្រង់មិន ព្រមទទួលភារៈធ្វើរាជការ ទ្រង់ទូលអង្វរព្រះវររាជបិតា សូម-ឲ្យទ្រង់ព្រះមេត្តាប្រោសព្រះរាជានុញ្ញាតបើកឱកាស ធ្វើពាណិជ្ជ-កម្ម ដូចបណ្តាពស្ត្រាំងពួង ៗ ព្រះរាជឱរសពាណិជអង្គនេះ បាន បាត់ការឲ្យវិឡ្យក់អ្នកមានថ្វៃ ធ្វើប្រាសាទជានិវេសនដ្ឋាន ឲ្យ មានសភាពសណ្ឋានដ៏ស័ក្តិសមពិសេសឥតមានពីរ ជាទីនៅអា-ស្រ័យរបស់ខ្លួន ៗ កាលជាងឈើ កំពុងធ្វើប្រាសាទជាព្រះ រាជនិវេសន៍នោះពុំទាន់សម្រេច ស្រាប់តែព្រះរាជបុត្រពាណិជ នេះ មានយោបល់កលកិច្ចឧបាយគិតថា នឹងប្រហារពិឃាត ជាងនោះចោល ក្នុងកាលណាដែលការនោះហើយស្រេច ដើម្បី វៀសវាងកុំឲ្យជាងនោះ ត្រាច់ចរទៅកគេហដ្ឋានឲ្យអ្នកដទៃបាន តទៅទៀត ក្រែងគេមានគំនិតឆ្លៀតរិះរកមធ្យោបាយដ៏បវរ ឲ្យ មានលំអលើសលុបប្លែកត្រកាល ជាងគ្រឹហាវេស្មន៍របស់ខ្លួន ៗ

ប៉ុន្តែជាកត់ព្វគាប់ប្រសើរណាស់ មេជាងនោះ បានដឹងការណ៍ច្បាស់ដោយសារពេជសេវ័កម្នាក់ ជាកល្យាណមិត្រលបប្រាប់ ៗ ជាងឈើក៏លៃលករកឧបាយធ្វើអាកាសយន្តតារុម័យ ជាជំនិះជិះចេញទៅតាមវេហាស៍នភាល័យប្រទេស ជាមួយនឹងភរិយាបុត្រធីតា ត្រាតែដល់ទីក្សេមក្សាន្ត ដោយសុវត្ថិភាព ៗ

## ពន្យល់ពាក្យ

ពោធិរាជកុមារ ន. ព្រះរាជកុមារព្រះនាមពោធិ ។ មាគធសេនិយពិម្ពិសារ (អ.ប. មាគ: ធ: សេណិយ: ពិមពិសារ) ន. ព្រះរាជាជាធំក្នុងដែនមគធ: ព្រះនាម សេនិយពិម្ពិសារ ។ រាជគ្រឹះ ន.(ម. រាជ-គហ) ឈ្មោះរាជធានីនៃដែនមគធ: ។ មគធរដ្ឋ ន. ដែនឈ្មោះមគធ: ។ ក្នុងពុទ្ធសម័យ, មគធរដ្ឋ មានក្រុងរាជគ្រឹះជារាជធានី ៗ ប្រជាញាណ ន. (< ប្រជា "ការកំណត់ដឹង, ការយល់ដាក់, ប្រាជ្ញា" + ញាណ "សេចក្តីដឹង") ប្រជានិងញាណ, ញាណដែលអាស្រ័យនឹងប្រជា ។ សមត្ថភាព ន. ភាពនៃសេចក្តីអង់អាច, ភាពនៃសេចក្តីអាចហាន ។ ពិធ័ត្ខ ន. (អ. ប. ពិទ័ក)

គុ. វាងវៃ, ប៉ិនប្រសប់, ឆ្លៀវឆ្លាស, ឬពូកែសវៃ ។ ភារៈ បន្ទុក, គ្រឿងផ្ទុក, ការរវល់, កិច្ចធុរៈ ។ រាជការ ន. ការរបស់ព្រះរាជា, ការផែនដី, ការរក្សាប្រទេស ។ វរបិតា (ស. ប. វរបិតា) ន. បុរសអ្នកបីបាច់រក្សាកូនដ៏ប្រសើរ បិតាដ៏ខ្ពង់ខ្ពស់ (ប្រើតែក្នុងពាក្យរាជស័ព្ទ) ។ ពាណិជ្ជកម្ម ន. ការរបរលក់ដូរ ។ រាជឱរស (ស. ប. -រស់) បុត្របង្កើត (កូនប្រុសបង្កើត) របស់ព្រះរាជា ។ ប្រើចំពោះតែរាជស័ព្ទ ។ ពាណិជ ន. អ្នកលក់ដូរ អ្នកជំនួញ, ឈ្មួញ ។ មធ្យោបាយ ន. ឧបាយជាកណ្ដាល, យ៉ាងកណ្ដាល ។ គ្រឹហា ន. ផ្ទះ, លំនៅ ។ វេស្ម័ន ន. លំនៅ, ដំណាក់, វាំង, ផ្ទះ ។ ការណ៍ ន. ហេតុ ។ រាជសេវក ន, អ្នកបំរើព្រះរាជា, អ្នកចាំទទួលការបំរើ, អ្នកគាល់បំរើ ។ កល្យាណមិត្ត ឬ មិត្រ ន. អ្នករាប់អានគ្នាជិតដិតល្អ, សម្លាញ់ល្អ, មិត្រដែលមានអធ្យាស្រ័យល្អ ។ អាកាសយន្ត ន. គ្រឿងប្រដាប់ដែលកម្រើកបានដោយកម្លាំងចក្រប្រកបគ្នាសម្រាប់ហោះហើរលើអាកាស, យន្តហោះ ។ ទារុម័យ គុ. ជាវិការៈនៃឈើ, ដែលគេធ្វើដោយឈើ ។ នភាល័យប្រទេស ន. ប្រទេសជាលំនៅនៃពពក, មេឃ, អាកាស ។

សុវត្ថិភាព ៩. ការមានសួស្តី, ការប្រកបដោយសេចក្តីសុខសប្បាយ ។

# រឿងអ្នកស្រែល្ងង់និងសត្វស្វា

មានកសិករម្នាក់ឈ្មោះ សុមន: បានបរិហារចិញ្ចឹមស្វាមួយ ៗ ស្វានោះឯង ជាសត្វមានសរីរកាយរៈថ្លោសគ្រលុចជាត់ធំ ដោយសារម្ចាស់ខុបត្ថម្ភបំប៉នចំណីអាហារដ៏បរិបូណ៌ ពុំដែលលស់ខាន ។ ថ្ងៃមួយ អ្នកស្រែនោះបានប្រុងប្រៀបរៀបបំអីរ៉ៃអែកាន់ ជាគហិតព្យុត្តកណ្ហាតាមសូប្តួនសព្វគ្រប់ គឺរេចបាយសម្លហូបក្រៀមផ្សំដោយទឹកខ្ចប់ស្រេចបាច់ ហើយត្រាប់បរទៅកាន់ស្រុកដទៃ យកទាំងស្វានោះទៅជាមួយផង ។ លុះដល់ពេលកត្តកាល គាត់ឃ្លានបាយពន់ពេក ចួនជាពោលក្អកក្រឡេកមើលទៅឃើញស្រះមួយ មានរាំរជ្រៅជ្រះត្រចះថ្លាធ្លង់សឹងប្រកបដោយផលជាត ទឹនសេវាលជាតិផ្សេង ១ ៗ អ្នកស្រែបានឃើញដូច្នោះហើយ ទើបដាក់ស្បៀងក្រោមគល់ឈើ តែស្រ

ឆ្នេរស្រះ ហើយចុះទៅលានជំរះធ្មេញ ស្រោចស្រពលាបស្រឡាបខ្លួនប្រាណក្នុងស្រះនោះឯង ។

ឯពានរវិលរបុលរប៉ូចនោះកាលម្ចាស់ចុះទៅក្នុងស្រះទៅក៏តាំងប្រាព្វហែកកញ្ចប់ស្បៀងស៊ីអស់ ឥតសេសសល់ដល់តិចតួចឡើយ ហើយយកទធិដែលប្រឡាក់ជាប់នឹងដៃខ្លួន ទៅលាបមាត់ពពែមួយដែលឈរនៅក្បែរនោះ ហើយគេចវេះទៅពួនក្នុងទីឆ្ងាយពុំនាំពាឡើយ ។ អ្នកស្រែជាមនុស្សល្ងង់ឥតបើគិត មិនពិនិត្យពិច័យករណីនោះឲ្យប្រាកដជាក់ច្បាស់ លុះលាងជំរះធ្មេញរួចឡើងមកវិញ ស្រាប់តែមិនឃើញស្បៀងអាហារ មើលទៅចង្កានឹងមាត់ពពែ ឃើញសសំព្រុះប្រឡាក់ប្រឡូសដោយទធិក៏សំគាល់ថាពពែនោះស៊ីស្បៀងខ្លួន ទើបគទ្រាក់ដំបងសំពងពពែ ជាសត្វឥតកំហុសឥតទោសពៃរ៍ ស្ទើរតែក្សណក្ស័យជន្មជីវិត ត្រង់គំនិតខ្លួនថោកទាបគិតមិនឃើញសោះ ឯស្វាខ្ចបបានឆ្អែតពោះស្កប់ស្កល់រួចខ្លួនទទេ ។ គួរឲ្យសង្វេគ! មនុស្សអាក្រក់

ធ្វើខុសខ្លួនឯងត្រឡប់ក្លែងទម្លាក់កំហុសនោះទៅលើអ្នកដទៃវិញ !

មនុស្សល្ងង់ច្រើនតែធ្វើអំពើលាមកអាក្រក់តាមតែនឹកឃើញ ឥតត្រិះរិះពិចារណារកហេតុផល ឲ្យឃើញជាក់ច្បាស់ឡើយ ។

មនុស្សខូបធ្វើខ្វីកម្មអាក្រក់ អាប់ឱនលាភមផងទាំងឡាយ
អំពើនោះឯងតែងផ្សព្វផ្សាយ ប៉ះពាល់ដល់កាយសាធុជន ។
ដូចយ៉ាងពានរស៊ីចំណី ពពែរងក្តីទុក្ខលើសលន់
គឺត្រូវដំបងគេយ៉ាងធ្ងន់ ស្ទើរក្ស័យជីពជន្មនៃអាត្មា ។

## ពន្យល់ពាក្យ

**កសិការ** អ្នកធ្វើកសិកម្ម ។ **កសិកម្ម** ន. ការភ្ជួររាស់, ការងារដែលគេប្រកបដោយការភ្ជួររាស់, ការធ្វើស្រែចំការ ។ **បរិហារ** ន. ការពោលដោះស្រាយ, ការពោលដោះប្រស្នា, ការរក្សា, ការថែទាំ ។ ក្នុងទីនេះប្រើជា កិ. "រក្សា, ថែទាំ" ។ ម្យ៉ាងទៀតប្រើជា កិ. វិ. (អ. ថ. ប-ហារ) ១. ដើរបរិហារ, និយាយបរិហារ គឺនិយាយផ្សាយសេចក្ដីឲ្យឮសាយសុះ ។ **សរី-រាវយវៈ** ន. ( < សរីរៈ "អត្តភាព, រូប, រាងកាយ, ខ្លួនប្រាណ" + អវយវ

" បំណែក, បែ៉ក ") បំណែកតូចធំនៃរាងកាយ ។ ត្រលុជ គុ. ដែលមានសាច់, ដែលធាត់សាច់ណែន ។ គហិតព្វយុត្តកណ្ហា ន. គ្រឿងប្រើប្រាស់ ឬ អីវ៉ាន់ ឬក៏គ្រឿងប្រដាប់ដែលគួរគប្បីកាន់យក ។ សច្ឆន្ទ (អ. ថ. ស៊័ច-ឆ័ន) ន. សេចក្តីពេញចិត្តរបស់ខ្លួន ។ ទធិ ន. ទឹកដោះជូរ ។ ភត្តកាល ន. ពេលបរិភោគភោជន, ពេលបាយ ។ វារី ន. ទឹក (ម. វារិ) ។ ជល-ជាត ន. អ្វីៗ ដែលកើត, ដែលដុះក្នុងទឹក ។ សេវាលជាតិ ន. ពួកជលជាតមានសារ៉ាយ, បកជាដើម ។ ស្រព កិ. លាង, ជំរះ ។ វានរ ន. សត្វមានរូបរាងស្រដៀងនឹងមនុស្ស (ស្វា) ។ នាំពា កិ. អើពើ ។ ពិនិត្យពិច័យ កិ. ពិនិត្យដោយល្អិតល្អ, សង្កេតឲ្យហ្មត់ចត់ ។ (< សំ. វិនិឝ្ចយ; ម. វិនិច្ឆយ ន. " ការពិចារណា, ការកាត់សេចក្តី, ការវិនិច្ឆ័យ " + សំ. ម. វិចយ ន. " ការរើសយក, ការគន់រក, ការជ្រើសរើស ") ។ ការណ៍ ន. ហេតុ, ហេតុភេទ, ដំណើរទំនងដែលបណ្តាលកើតឡើង ។ ទោសពៀរ ន. (សំ. ទោស + វៃរ, រ > ព; ម. ទោស វេរ) ទោសនិងពៀរ ។ ជន្ម (អ. ថ. ជ៉ន់) ន. ជីវិត ។ សង្វេគ (អ. ថ. សង់-វេក)

ន. សេចក្ដីតក់ស្លុតចិត្ត, ដំណើរតក់ស្លុត ។ ខ្មែរប្រើជា កិ. ខគួរសង្វេគ បាន
សេចក្ដីថា គួរឲ្យស្លុត, គួរឲ្យខ្លាចរអាណាស់ក្ដី ! ។ លាមក (អ. ថ. លា-
មក់) គុ. អាក្រក់, ថោកទាប, អន់ថយ, ពុំប្រសើរ ។ សាធុជន ន.
ជនល្អ, ជនអ្នកត្រឹមត្រូវ, ជនអ្នកប្រព្រឹត្តល្អ ។

# ព្រះរាជបុត្រដែលគួរគ្រងរាជសម្បត្តិ

នៅនានគរមួយ មានព្រះរាជបុត្របីព្រះអង្គ ទ្រង់ចេញទៅ
សិក្សាសិល្បសាស្ត្រផ្សេង ៗ ពីគ្នា គឺព្រះអនុជទ្រង់រៀនសិល្ប
... ព្រះរៀមបន្ទាប់ទ្រង់រៀនក្បូនពេទ្យ ព្រះរៀមច្បង
... ទ្រង់រៀនវិជ្ជាខាងត្រូតរេហ៍ពលសកលយោធា ។ លុះ
... ទ្រង់សិក្សាចេះចប់សព្វគ្រប់ សមតាមព្រះរាជបំណងហើយ
... ទើបត្រឡប់វិលមកព្រះនគរជាជាតិភូមិវិញ ព្រមគ្នាទាំង ៣
ព្រះអង្គ ។

សម្ដេចព្រះភូមិន្ទនរបតីជៀស្ឋជ័យចេស្ដា ជាព្រះវររាជបិតា
ទ្រង់ពិចារណាពុំដាច់ស្រេចក្នុងព្រះរាជហឫទ័យ នឹងគិតលៃឲ្យ

ព្រះរាជបុត្រណាសោយរាជ្យស្នងព្រះអង្គពុំបាន ទើបទ្រង់ត្រាស់ព្រះរាជបញ្ញា ប្រើព្រាហ្មណ៍អ្នកប្រាជ្ញរាជបុរោហិត នូវអស់នាម៉ឺនមុខមន្ត្រី សេនាបតីគរីបណ្ឌិត ព្រឹទ្ធាចារ្យ ឲ្យទៅស្នើការសួរព្រះមហាឫសីថា អ្នកទាំងបីគួរឲ្យនរណាសោយរាជ្យ ? ។ អស់ពួកសេវកាមាត្យ បានទទួលព្រះរាជឱង្ការនាំគ្នាទៅគាល់ទូលស្នើព្រះមហាឥសី ពិតពុទ្ធដីកាតាមដំណើរសេចក្តីដែលព្រះចក្រីទ្រង់ប្រើមក ។ ព្រះមហាឫសីឆ្លើយថា ព្រះរាជបុត្រដែលទ្រង់យកព្រះទ័យទុកដាក់ទឹងរហ័ពលសកលយោធា គួរបានជាស្តេចសោយរាជ្យស្នងអង្គតរៀងព្រះវររាជបិតា ព្រះអង្គម្ចាស់ដែលសិក្សាខាងធនុគ្គហសាស្ត្រគួរតាំងជាអគ្គមហាសេនាបតី ឯអង្គដែលសម្កីខាងហោរាសាស្ត្រ គួរតាំងជាមហាឧបរាជ អាចយន់យល់ការណ៍គាប់ខុសស្នងព្រះអង្គស្តេច ជាសូរបដោយនូវប្រការអម្បាលនេះឯងហោង ។

## ពន្យល់ពាក្យ

អនុជ (អ.ជ. អៈណុជ ន. អ្នកកើតបន្ទាប់, អ្នកកើតក្រោយ (ប្អូន)។

រៀម ន. (រាជស័ព្ទ) បង ។ ធ្នូ ន. (ម. ធនុ) អាវុធដែលគេធ្វើដោយឈើ, ឬស្សី ឬក្រាំងមានដង មានខ្សែបន្ទោះ សម្រាប់បាញ់ដោយព្រួញ ។ ហោរា (អ. ថ. -រ៉ា) ន. ក្បួនហោរ ។ វេហ៍ពល (អ. ថ. វេពល់) ន. (សំ. វិហ "បៀតបៀន, ប្រហារ, ឃាត", វិហ > វេហ; ពល "កម្លាំង, ពល") ពលអ្នកបៀតបៀន គឺពួកទាហាន, កងទ័ព ។ សកល (អ. ថ. សះកល់) គុ. ទាំងអស់, ទាំងមូល ។ យោធា ន. (ម. សំ. យោធ, ពហុ. យោធា) អ្នកច្បាំង ទាហានទាំងឡាយ, កងទាហាន ឬ ពួកទាហាន ។ ក្សិន្ទ ន. អ្នកដែលជាធំជាងប្រជាជនលើផែនដី (ព្រះរាជា) ។ នរបតី (អ. ថ. នរប៉ប៉ះដី) ន. (ម. នរបតី) ម្ចាស់នៃនរៈ, ម្ចាស់នៃពួកជន (ព្រះរាជា) ។ ជៀស្នជ័យ (អ. ថ. ជៀសជៃ) គុ. ដែលជាចម្បង, មានជ័យជំនះលួះអស់សត្រូវផង ។ ចេស្ដា (អ. ថ. ចេសស្ដា) គុ. មានតេជះអំណាច ។ ព្រាហ្មណ៍ ន. មនុស្សដែលមានពូជកើតពីព្រះឧស្សព្រហ្ម ។ បុរោហិត ន. ព្រាហ្មណ៍ អ្នកបំពេញប្រយោជន៍ដល់បុរី; អ្នកធ្វើសេចក្ដីទំនុកបំរុងដល់បុរី ឬព្រះនគរ ។ សេនាបតី ន. អ្នកជាចៅហ្វាយនៃសេនា,

អ្នកដាធំជាងសេនា ត្រូវនឹងពាក្យថា រដ្ឋមន្ត្រី ដែលប្រើសព្វថ្ងៃនេះ ៗ បណ្ឌិត ន. អ្នកប្រាជ្ញ ។ ព្រឹទ្ធាចារ្យ ន. អាចារ្យចាស់, អាចារ្យដែលមានចំណាស់ ឬអាចារ្យដែលមានអាយុច្រើន ។ មហាឫសី ន. អ្នកស្វែងរកគុណដ៏ធំ, តាបសធំ, ឥសីប្រសើរ ។ ជួនកាលប្រើជា មហាឥសី តាមបាលី, ន័យរបស់ពាក្យទ្វិបក្ខ ។ សេនាមាត្យ ន. មន្ត្រីអ្នកគាល់បំរើព្រះរាជា ។ រាជឱង្ការ ន. សំដីព្រះរាជា, ព្រះបន្ទូលព្រះរាជា ។ ចក្រី ន. (ម. ចក្រី) អ្នកមានចក្រ, អ្នកទ្រទ្រង់ចក្រ, (ព្រះមហាក្សត្រ) ។ អគ្គ-មហាសេនាបតី ន. សេនាបតីដែលធំលើសសេនាបតីទាំងអស់ ស្មើនឹងពាក្យថា នាយករដ្ឋមន្ត្រី ដែលប្រើសព្វថ្ងៃ ៗ សម្ភី ឧហាត, សង្វាត, ចំប្រឹង, ប្រឹងប្រែង ។ ហោរាសាស្ត្រ ន. ក្បួនហោរ, ក្បួនទាយ ។ ឧបរាជ ន. ព្រះរាជាបន្ទាប់, ព្រះរាជារង គឺព្រះអង្គម្ចាស់ដែលមានព្រះរាជ-សក្តិបន្ទាប់ព្រះរាជាទ្រង់រាជ្យ ។ យដ៏យល់ ក. យល់ជាក់, យល់ច្បាស់, ដឹងពិត, ឈ្វេងយល់ ។ ការណ៍ ន. ហេតុ ៗ

# សិលាប្រាសាទនឹងខ្មែរបុរាណ

ប្រទេសកម្ពុជា ជាប្រទេសកុះករបរិបូណ៌ដោយសិលាប្រាសាទ ដែលជាកេរ្តិ៍ដំណែល នៃពួកបុព្វបុរសរបស់ខេមរជនក្នុងបុរាណសម័យ ។ ប្រាសាទថ្ម ដែលមានលំអដ៏បវរសក្តិសមឥតមានពីរនោះ គឺប្រាសាទនគរវត្ត ដែលសព្វថ្ងៃហៅក្លាយជា អង្គរវត្ត ។ សិលាប្រាសាទនេះ មានក្បូរក្បាច់របនាដ៏បណ្តាច់អស្ចារ្យ កុំថាតែមនុស្ស ពោះទាំងទេពតាក៏គង់ទំយមសរសើរពុំខាន ។ តាមពាក្យបរម្បរាថា ព្រះពិស្ណុការមកជួយសាង តែបើតាមសិលាចារឹកជាក់ស្តែង ថាជាការស្នាដៃនៃពួកពង្សឱ្យក៏ជាមនុស្សជាតិខ្មែរសុទ្ធ ជាពួកកុលបុត្រតក្កវិទ បេះពិនិត្យកិច្ចការជាអ្នកបរិបូណ៌ដោយសិល្បសាស្ត្រវិទ្យា សាងក្នុងពង្សព្រះកេតុ-មាលាក្សត្រាធិរាជខេមរជាតិ ។

ខេមរជនក្នុងសម័យបុរាណ ច្រើនជាអ្នកមានអធ្យាស្រ័យគម្ភីរភាពពេញចិត្តនឹងការសិក្សាចំណេះវិជ្ជា ទាំងផ្លូវលោកទាំង

ផ្លូវធម៌ ហើយខំសង្រហ៍ស្រវាស្រទាញរៀនទន្ទេញ ដោយការមុឺងម៉ាត់ ប្រយ័ត្នក្រែងសាបសូន្យការចេះដឹង ។ ព្រោះហេតុហ្នឹងហើយ បានជាខេមរជនជាបុព្វបុរសរបស់យើងធ្វើសិលាប្រាសាទប្លែក ៗ អនេកអនន្តអស្ចារ្យ ស្ទើរតែនឹងគណនាត្រាប់ឲ្យសព្វគ្រប់ពុំបាន ។ ជាតិខ្មែរក្នុងជំនាន់បុរាណ មិនមែនចេះតែត្រឹមការហត្ថកម្មប៉ុណ្ណោះទេ សូម្បីតក្កវិជ្ជានឹងវិទ្យាអក្សរសាស្ត្រ ព្រមទាំងសិល្បការក្បួនច្បាប់ក្រិត្យក្រមតូរ្យតន្ត្រី ក៏មានល្បីថាចេះគ្រប់មុខ មានតែងគាថាជាពាក្យកាព្យឆន្ទសំស្ក្រឹត ដោយពិនិត្យពិច័យជាសំណាដៃនៃបណ្ឌិតកវីអ្នកប្រព័ន្ធ មានលក្ខណៈត្រឹមត្រូវគ្រប់គ្រាន់ ឥតមានវិបត្តិល្អៀងឃ្លៀងឃ្លាតខាតខុសឡើយ ។

## ពន្យល់ពាក្យ

បុព្វបុរស ន. បុរសខាងដើម; ពួកញាតិទាំងបុរសទាំងស្ត្រីទាំងអស់ដែលទៅកាន់បរលោកហើយ តាំងពីជីដូន ជីតា ទួត លួត លា ជាដើមឡើងទៅ ហៅថា បុព្វបុរស ។ បរម្បរា ន. ពាក្យដែលនិយាយតៗគ្នា

មក ។ ភស្តុតាង ន. របស់ជាតឹកតាង ជាគ្រឿងសំគាល់ ឬជាសំអាង ។ តក្កាវិទូ ន. អ្នកចេះតក្កវិជ្ជា គឺចេះបំណេះខាងការពិចារណារិះរកហេតុផលដែលប្លែក ឲ្យឃើញជាក់ច្បាស់ដោយគំនិតខ្លួនឯង; អ្នកចេះវិជ្ជាខាងត្រិះរិះ ។ គម្ភីរភាព គុ. ដែលមានភាពជ្រាលជ្រៅ ។ ឧស្សាហ៍ ន. សេចក្ដីខ្មីឃ្មាត, ការខំប្រឹងមិនខ្ជិលច្រអូស ។ ខ្មែរប្រើជា កិ. " សង្វាត, ខំប្រឹង " ។ ស្រវាស្រទេញ កិ. ខំប្រឹងខ្លាំង, ខ្មីឃ្មាតខ្លាំង, ប្រឹងសង្វាតពេញកម្លាំង ។ ប្រយ័ត្ន ន. (ម. បយតន) ការលាង, ជំរះ, សំអាត, ការប្រុងមិនធ្វេសប្រហែស ។ ខ្មែរយើងប្រើជា កិ. សំដៅសេចក្ដីថា "ប្រុង" ។ គណនា ន. ការរាប់, ដំណើររាប់ឲ្យដឹងចំនួន ។ ក្នុងទីនេះប្រើជា កិ. សំដៅសេចក្ដីថា នឹងរាប់កត់ត្រាថាប៉ុណ្ណេះឬប៉ុណ្ណោះឲ្យសព្វគ្រប់ពុំបាន ។ ហត្ថកម្ម ន. ការដែលត្រូវធ្វើដោយដៃ, ការរបស់ជាង, ជំនាង ។ សិល្បការ ន. ជាង, អ្នកធ្វើជាង ។ ក្រឹត្យក្រម ន. លំដាប់នៃកិច្ច, ក្បួនច្បាប់ ។ តូរ្យតន្ត្រី ន. គ្រឿងភ្លេងដេញដំផ្លុំក្លួត ។ គាថា ន. កម្រងពាក្យដែលមានរបៀបកំណត់ដោយខ្យល់អក្សរ មានឆន្ទៈ គណៈ ឃ្លា ល្បះ ដ៏ត្រឹមត្រូវ ហៅថា គាថា (ពាក្យកាព្យបាលី) ។ កាព្យ ន. (សំ. កាវ្យ) របៀបពាក្យចួន មានឃ្លោងឃ្លា

វគ្គភេទ មានច្រើនបទ ច្រើនបែប ។ ឆន្ទៈ ន. ឈ្មោះដំណើរកាព្យឃ្លោង ។
(អ. ថ. ឆ័ន) ។ **សំគ្រាត** ន. ពាក្យសំរិតសំរាង, សេចក្តីសំរាង, ភាស
សម្រាំង ។ **សំណាដៃ** ន ថ្វីដៃ, ស្នាដៃ ។ **ប្រព័ន្ធ** ន. (អ. ថ. ព័ន)
កិ. បង់រឹតរួត, បង់ក្រង, បង់ក្រងជាពាក្យឃ្លោង ។ **វិបត្តិ** (អ. ថ. ប័ត) ន.
ការភ្លាត់ខុស, ការខុសទំនង ឬ ការទាស់ឆ្គង ។

---

# រឿងបើ្មរព្រៃម្នាក់

*កាលកន្លងយូរយារណាស់ទៅហើយ មានបើ្មរព្រៃម្នាក់ នៅ*
*ក្នុងក្រុងពារាណសី ជាព្រែនជីវ៉ទ គឺអ្នករកស៊ីបរបាញ់ម្រឹគម្រឹគា*
*នាំសព្វប្រទេស ។ ថ្ងៃមួយ ព្រានប្រមាញ់នោះឯង បានស្ព*
*ស្វែងត្រាច់ចរដោយបាទបរណ៍ ដរាបដល់ព្រៃហិមពាន្ត ដោយ*
*មានបំណង ដើម្បីបរបាញ់សត្វ ស្រាប់តែវង្វេងទិសនៅកណ្តាល*
*អដ្វា កំព្រាអនាថា ត្រមង់ត្រមោចតែម្នាក់ឯង ។ កាលនោះ*
*ព្រះពោធិសត្វកំពុងតែត្រាច់រង្គាត់ អន្ទោលទៅមកក្នុងភត្តវជ្ជ-*
*សង្គ្រា បានសម្តែងយានយកកំណើតកើតជាដំរីសារ មាន*

សពាង្គកាយសគ្រុស ដូចផ្កាឥណ្ឌាបុស្ស ឬសំពត់កោសេយ្យ-ពស្ត្រសសុទ្ធ មានលំនាំសមសារដ៏សក្តិសមឥតខ្ចោះ ឈ្មោះសីលវនាគរាជ ព្រោះជាសត្វមានសីល ៗ ដំរីនោះ លុះឮស្នូរស័ព្ទព្រានទន្គឹះខ្សឹកខ្សួលក្នុងព្រៃដូច្នោះ មហាបុរសក៏នឹកអា-ណិតអាសូរស្ដើរខ្លោចចិត្ត ទើបបញ្ជិះមគ្គឲ្យបុរសលើខ្នង នាំចេញពីព្រៃទៅកាន់គ្រឹហាស្ថានរបស់ព្រាននោះ ៗ រីឯវនចរនោះជាមនុស្សទ្រុស្តមិត្ត ចិត្តពោរសាមាន្យ ក្លាហានឃោរឃៅ កាលដែលដំរីជូនដំណើរទៅ បានសង្កេតចំណាំឈើព្រៃខ្ទាលតាវល្លិគិរីបព៌ត ស្ទឹងបឹងបួរជ្រោះជ្រលងជងអូរក្នុងព្រៃធំនោះ ដោយជាក់ច្បាស់ ៗ

បំណោរកាលតមក ព្រាននោះនឹកក្នុងចង់បានភ្លុកដំរី ដើម្បីយកមកលក់ដូរចិញ្ចឹមជីវិតក្រុមគ្រួសារ បានប្រុងប្រៀបរៀបចំស្បៀងអាហារ គឺសដូវក្រៀម, កាំបិតនឹងរណារ ហើយទៅកាន់ព្រៃដែលដំរីនោះនៅ បានសុំនាគទន្តនឹងដំរីសារនោះឯង ៗ ឯដំរីនោះ ក៏ព្រមឲ្យព្រានអប្រិយនោះអារយកតាមប្រាថ្នាអស់វារៈ

ពីរដង ដោយសំដីដ៏ផ្អែមល្ហែម ហើយធ្វើបណិធានយ៉ាងនេះថា " ខ្ញុំមិនមែនឲ្យដោយអស់សង្ឃឹមជាភ្លុកទាំងឡាយនេះ មិនជាទីស្រឡាញ់របស់ខ្ញុំទេ ប៉ុន្តែបានជាខ្ញុំស៊ូប្ដូរឲ្យជាទានដល់អ្នកនេះ ព្រោះខ្ញុំស្រឡាញ់សព្វញ្ញុតញ្ញាណលើសលុបជាងភ្លុករបស់ខ្ញុំមួយសែនគុណទៅទៀត, ព្រោះហេតុនោះ ខ្ញុំសូមប្រាថ្នាដោយផលានិសង្សនៃទន្តទានរបស់ខ្ញុំនេះ សូមជាបច្ច័យឲ្យបានសម្រេចនូវសព្វញ្ញុតញ្ញាណកុំខាន ! " ។ លុះដល់វារៈជាគំរប់បី ព្រានអកតញ្ញូនោះក៏ទៅសុំភ្លុកដំរីទៀត ។ ម្ដងណោះ ព្រានទម្លុះសាច់តាស់គល់ចង្កូមអារដោយរណារ ដោយមានបំណងថានឹងយកឲ្យអស់តែម្ដង ហើយជៀសចេញទៅ ។ ឱ គួរអនិច្ចា ! ព្រាននោះគ្រាន់តែអារហើយចេញទៅ ទើបតែកន្លងនូវទស្សនូប-ចារនៃដំរី មហាប្រឋពីសូម្បីធ្លាប់តែទ្រនូវបន្ទុកដ៏ធ្ងន់មានភ្នំសិនេរុយុគន្ធរជាដើម ក៏ហាក់ដូចជាមិនអាចទ្រ នូវគំនរទោសរបស់ព្រាននោះបាន ក៏បែកសញ្ញែកញែកបន្លោះឲ្យព្រាននោះបុះទៅ

កាន់អវិចិមហានរក រងទុក្ខតាមយថាកម្មរបស់ខ្លួន ។

អស្ចារ្យណាស់ ! ក្នុងឱកាសដែលព្រះធរណីស្រូបព្រាន នោះ ពួកទេវតា ទេពារក្ស ដែលនៅក្នុងព្រៃនោះទាំងប៉ុន្មាន បានសំដែងអាការអេបអរសាទរ ហើយពោលគាថាដែលមានក្នុង សីលវជាតក ត្រង់អដ្ឋមវគ្គ គម្ពីរឯកនិបាតថា

អកតញ្ញុស្ស បោសស្ស និច្ចំ វិវរទស្សិនោ
សព្វញ្ចេ បឋវឹ ទជ្ជា នេវ នំ អភិរាធយេ ។

សត្វអកតញ្ញូអាក្រក់ក្រៃ ស្វែងរកទោសពៃរ៍ជាធម្មតា
នោះបើគេឲ្យភូមិថ្លៃថ្លា នៅក្នុងទ្វីបាគ្រប់ទាំងអស់ ។
យ៉ាងនេះក៏ដោយគង់មិនអាច ធ្វើចិត្តកំណាចអសប្បុរស
ឲ្យត្រេករីករាយសប្បាយស្រស់ ចំពោះរបស់នោះបានឡើយៗ

## ពន្យល់ពាក្យ

ជ្រើរព្រៃ ន. អ្នកដើរព្រៃ, ព្រានព្រៃ ។ យូរយារ គុ. ដែលយូរអង្វែង ណាស់, យូរហួសកំណត់ណាស់ហើយ ។ ទ្រឹតជីវ៉ង ន. អ្នកចិញ្ចឹមជីវិត

ដោយការបរបាញ់ម្រឹគ ។ **ម្រឹគីម្រឹគា** ន. ម្រឹគញីនិងម្រឹគឈ្មោលទាំងឡាយ ។ ពួកសត្វចតុប្បាទព្រៃ មានសីហៈ, ខ្លា, រមាស, ប្រើស, ឈ្លូស ជាដើម ហៅថា **ម្រឹគ** ។ **អរញ្ញប្រទេស** ន. ប្រទេសដែលមានក្នុងព្រៃ ។ **ប្រមាញ់** ន. អ្នកបាញ់ ឬ អ្នកបរបាញ់សត្វ ។ **បាទចរណ៍** ន. ការដើរដោយជើង ។ **អទ្ធា** ន. ផ្លូវ, ជិតផ្លូវ, កណ្ដាលផ្លូវ ។ **អឆាជោ** គុ. ដែលឥតទីពឹង, ឥតពំនាក់, ដែលណែលណោល ។ **អឆ្នោល** កិ. (សំ. "ក្រវី, ស្អុះសឿន") ព្រាច់វង្កាត់កើតស្លាប់ក្នុងវដ្ដសង្សារ, វិលកើតវិលស្លាប់ ។ **សម្ភព** (អ. ថ. សំភប់) ន. ការកើត, កំណើត, ប្រសូតិ ។ ខ្មែរប្រើជា កិ. "កើត, ប្រសូត" ។ **ដំរីសារ** ន. ដំរីស្ដ ឬ ដំរីមានភ្លុកធំបំបង ។ **សពាង្គកាយ** (អ. ថ. ស័រពាងកាយ) ន. រូបរាងកាយទាំងមូល (សំ. សវ៌ + អង្គ; ម. សព្វ + អង្គ) ។ **អផ្កាបុស្ស** ន. ឈ្មោះឈើផ្កាមួយយ៉ាង មានផ្កាពណ៌ស ។ **កោសេយ្យពស្ត្រ** (អ. ថ. កោសៃ-យៈ ព័ស) ន. (សំ. កោសេយវស្ត្រ; ម. កោសេយ្យវត្ថ) សំពត់សូត្រ ឬ សំពត់ព្រៃ ។ **លំហាំសមសារ** ន. ដំណើរឫកពា, បែបភាពរាងកាយ ។ **សីលវនាគរាជ** ន. ស្ដេចនៃដំរីឈ្មោះសីលវៈ ឬ ស្ដេចដំរីមានសីល ។

មគ្គមូឡ្ហបុរស ន. បុរសដែលវង្វេងក្នុងផ្លូវ ឬ បុរសដែលមមីងមមាំងក្នុងផ្លូវ ។ វនចរ ន. អ្នកត្រាច់ទៅក្នុងព្រៃ, ថ្មើរព្រៃ, ព្រានព្រៃ ។ សាមាន្យ គុ. (សំ. ; ម. សាមញ្ញ) ដែលស្មើ ៗ គ្នា, ពោរសាមាន្យ គឺពោរស្មើ ៗ គ្នា ឬជាពោរយ; ពោរចង្រៃ ។ រុក្ខា ន. (ម. រុក្ខ, ពហុ. រុក្ខា) ឈើទាំងឡាយ ។ លតា ន. (ម. សំ.) វល្លិ ។ គិរី ន. (ម. សំ. គិរី) ភ្នំ ។ សម្ពល ន. អាហារធ្វើដោយប្រអ្លូលផង់ឬ ម្សៅក្លួត សម្រាប់ទុកបរិភោគបានយូរ ប្រើជាស្បៀងក្នុងវេលាដើរផ្លូវឆ្ងាយដាច់ស្រយាលជាដើម ។ ស្បៀង ន. គ្រឿងបរិភោគចិញ្ចឹមជីវិតក្នុងការដើរផ្លូវឆ្ងាយ ។ ឆាកទន្ត ន. ភ្លុកដំរី ។ បណិធាន ន. ការផ្តួចផ្តើមប្រាថ្នា, ការតាំងសេចក្តីប្រាថ្នា ។ សព្វញ្ញុតញ្ញាណ (អ.ឋ. ស័ប ព័ញ-ញុ-ត័ញ ញាន) ន. ញាណឬប្រាជ្ញាដែលដឹងសព្វ (ញាណរបស់ព្រះសព្វញ្ញុពុទ្ធ) ។ ផលានិសង្ស ន. ការហូរមកមិនដាច់នៃផលអានិសង្សនៃផល ។ ឧត្តាន ន. ការឲ្យភ្ញាក់ ។ បច្ច័យ ន. ហេតុជាទីអាស្រ័យគ្នា, ទំនង, ហេតុដែលនាំឲ្យផលប្រព្រឹត្តទៅ ។ អកតញ្ញូ ន. អ្នកមិនដឹងឧបការគុណដែលគេធ្វើចំពោះខ្លួន ។ ឧស្សូបចារ ន. ឧបចារៈ

នៃការមើលឃើញ គឺទីដ៏គួរមើលឃើញ ។ មហាប្រឋពី ន. ផែនដីធំ។ អវិចិ ន. ឈ្មោះស្ថាននរកធំមួយ ។ សត្វដែលមានបាបធ្ងន់ តែងទៅកើតក្នុងនរកនេះ ។ យថាកម្ម ន. កម្មឬអំពើដែលខ្លួនធ្វើយ៉ាងណា ។ អសប្បុរស ន. បុរសអ្នកមិនស្ងប់ គឺបុរសស្ត្រីអ្នកកាន់អំពើអាក្រក់ដោយកាយវាចាចិត្ត, អ្នកមានចិត្តអាក្រក់ ។ ភូមិ ន. ដី, ផែនដី ។

---

# រឿងបងប្អូនបីនាក់

ក្នុងបច្ចន្តជនបទ មានត្រកូលមួយ មានបុត្របីនាក់ ។ ជេដ្ឋបុត្រភេទប្រុស ចេញទៅបួសសំណាក់ក្នុងព្រះពុទ្ធសាសនា បានសិក្សាធម្មវិន័យជាសាសនប្បដិបត្តិ មានកិត្តិស័ព្ទល្បីរន្ទឺលេចឮទៅឆ្ងាយថាជាអ្នកប្រាជ្ញពហុស្សូត មានសមណសក្តិជាទីពជាគណៈ ។ អនុបុត្រ ក៏ជាភេទប្រុសដែរ បានចេញទៅរៀនបំណេះវិជ្ជាអក្សរសាស្ត្រជាអាទិ ហើយបានឋានន្តរសក្តិជាឧកញ៉ាពិជិតសេនា ស្តីពជការទីមហាតាមភោជក ។ ឯកនិដ្ឋបុត្រ ជាភេទស្រី មានស្វាមី ជាអ្នករកស៊ីកាយធរណី ។ លុះអំណើះ

កាលតមក អ្នកតាំងពីរប្ដីនឹងប្រពន្ធក៏កាន់តែជក ដល់នូវភាពជាអ្នកទ័លក្រហិនហោ គួរអាណិតអាសូរ រករបររលៀនជីពជន្មដោយខ្លួនឯងពុំបាន ក៏ចូលទៅជ្រកកោននៅក្នុងវត្ត អាស្រ័យដោយសារព្រះមហាថេរជាបុត្របង្ស នៅពុំសុខបានយូរប៉ុន្មានព្រោះពួកបរិស័ទវិយាសាទ តែងប្រមាថលើកទោសជានិរន្តរ៍ក៏ថយខ្លួនទៅនៅពឹងពាក់ពំនាក់អាស្រ័យ ដោយសារលោកអ្នកទកញ៉ាំជាបុត្របន្ទាប់ ៗ នៅក្នុងទីនោះក៏ពុំសុខបានបិតថេរបីរកាល ដោយហេតុលោកជំទាវនោះមិនមែនជាបងបង្កើត គ្រាន់តែជាបងថ្លៃប៉ុណ្ណោះ សូម្បីបងប្រុសដែលមានពហូសក្តិដល់ម្ល៉ោះក៏ពុំអាចគ្រប់គ្រងឲ្យបានសេចក្ដីសុខសមតាមប្រាថ្នា តែវេលាណាលោកចៅហ្វាយចេញទៅធ្វើការ គេតែងប្រមាថបៀតបៀនជានិច្ចម្ល៉ោះហើយក៏ចិញ្ចឹមជីវិតបានដោយលំបាក វៀនកបដកបមក ៗ ។

## ពន្យល់ពាក្យ

បច្ចន្តជនបទ ន. ជនបទនៅចុងដែន ឬជនបទដែលនៅជិត

ព្រំប្រទល់ដែន ។ ជេដ្ឋបុត្រ ន. កូនច្បង ។ សាសនប្បដិបត្តិ ន. សេចក្ដីប្រតិបត្តិតាមសាសនា ។ កិត្តិសព្ទ ន. សូរសរសើរ, សម្លេងសរសើរ ។ ពហុស្សុត ន. អ្នកដែលបានស្ដាប់ច្រើន ឬអ្នកដែលបានរៀនច្រើន ឬជាអ្នកដែលមានចំណេះវិជ្ជាច្រើន ។ សមណសក្តិ ន. សក្តិសម្រាប់សមណៈ គឺឋានន្តរសក្តិសម្រាប់បព្វជិតក្នុងប្រទេសនីមួយ ៗ ។ រាជាគណៈ ន. ពួក ឬ ក្រុមរបស់ស្ដេច ។ ពាក្យសម្រាប់ហៅបព្វជិតដែលមានសមណសក្តិ ថ្នាក់ណាមួយ ក្នុងកម្ពុជរដ្ឋ ។ អនុបុត្រ ន. កូនបន្ទាប់ ។ ឋានន្តរសក្តិ ន. អំណាចតាមមុខងារ, បណ្ដាសក្តិធំតូចតាមមុខងារ ។ ឧកញ៉ា ន. ពាក្យសម្រាប់ប្រើជាឋានន្តរសក្តិ នៃមន្ត្រីខាងអាណាចក្រថ្នាក់ខ្ពស់ជាងទីព្រះ សំដៅសេចក្ដីជាអ្នកមេត្រួតត្រាមុខការក្នុងក្រសួង ឬ នាទីរបស់ខ្លួន ។ ពិជិតសេនា ន. គោរមងាររបស់មន្ត្រី ប្រែជាសេចក្ដីថា អ្នកឈ្នះសេនា ។ មហាគាមភោជក ន. ចៅហ្វាយស្រុក, អ្នកបរិភោគ ឬ ប្រើប្រាស់នូវផលប្រយោជន៍ដែលកើតក្នុងស្រុកដ៏ធំ ។ កនិដ្ឋបុត្រ ន. កូនពៅ ។ អំណើះ និ. តមក, ចំណេរកាល តមក ។ ជរា ន. ការគ្រាំគ្រា, សេចក្តី

ទ្រុឌទ្រោម, ដំណើរទ្រមនៃខ្លួន, ចំណាស់ ។ ហាណិហៃ ន. ដែលថយថោក ឬដែលវិនាស នឹងថយថោកជានិច្ច ។ លៀងកិ. ចិញ្ចឹម, រក្សា ។ ជីពជន្ម ន. ជីវិត ។ មហាថេរ ន. ព្រះថេរៈធំ ។ វិឃាសាទ ន. អ្នកបរិភោគភោជន៍ដែលសេសសល់ពីគេ គឺអ្នកស៊ីញាយដែល ។ ជំទាវ ន. បណ្ដាសក្តិសម្រាប់ស្ត្រីជាភរិយាសេនាបតី ដោយព្រះករុណាជាម្ចាស់ជីវិតទ្រង់ប្រោសព្រះរាជទានតាំង; លោកស្រី ។ ពហុសក្តិ ន. សក្តិច្រើន, អំណាចច្រើន ឬ អំណាចខ្លាំងកម្លាំងច្រើន ។

---

# រឿងព្រាហ្មណ៍ទុគ៌ត

មានព្រាហ្មណ៍កំសត់ទុគ៌តអនាថា កំព្រាគោកយ៉ាកមួយនាក់ឈ្មោះ ស្វការក្ខុបណៈ ស្ថិតនៅក្នុងកុសុមបុរី ។ ព្រាហ្មណ៍នោះឯង តែងត្រាច់ចរយាត្រាលីលា ទៅកាន់ស្រុកតូច-ធំ និគមជនបទ រាជធានី ខណ្ឌខេត្រផ្សេងៗ ដើម្បីស្វែងរកភោជ្ជ័ស្តុអម្រែសអម្រ យកមកបរិហារថែរក្សាសពាង្គ-កាយ លៀងជីពជន្មរបស់ខ្លួនជានិរន្តរ៍ ពុំដែលលស់ខាន ។ មានកាលថ្ងៃមួយ កាលព្រះទិនករបរព្រះទីន័ររថ បត់ឡើងផុត

បាកដើងមេឃទិសបូព៌ា ជាគ្រាឧទ័យនៃអរុណព្រឹកព្រហាម តាព្រាហ្មណ៍ស្ពាយ យាមយីកយោក ៗ គួរឲ្យអណោគអធ្យាស្រ័យ គា-ណិតកាសូរពន់ប្រមាណ ចេញពីគ្រឹហាស្ថានវេស្ម័នកាន់ឈើច្រត់ស្ពាយស្បង់ពីខាងមុខទ្រឹប ៗ ទៅកាន់យាបនដ្ឋាន សូមបានសដូវទៅតាកមួយឆ្នាំង ក៏រលះរលាំងរវៀសរវៃវិលមកកាន់គ្រឹហាអាត្មាវិញ ៗ ក្រោយដែលតាព្រាហ្មណ៍ព្រឹទ្ធាចារ្យបរិភោគភោជនាហារឆ្អែតស្កប់គាប់គួរដល់ជួនបៃ ហើយពុំលង់ឡើយ គាត់ក៏ព្យួរភាជន៍ដ៏ពេញដោយកត្ត នៅលើនាគទន្ត គឺដៃកែវ ក្បែរមេញ្ញកដ្ឋានចុងជើង ហើយឡើងទៅដេកផ្ងារស្រទៀកសំឡឹងមើលក្តូះ ៗ ស្រាប់តែបែកគំនិតព្រោងព្រាត លន្ទង់លន្ទោចស្រដេះស្រដោចយ៉ាងនេះថា

"យីអើហ្ន៎! អាត្មាអញបានសដូវមួយឆ្នាំងនេះ ពេញហៅមានក៏ព្យួរគាប់ប្រសើរណាស់ បើសិនណាជាស្រុកកើតទុរ្ភិក្សរើកឡើងក្នុងពេលណា ក្នុងពេលនោះអាត្មាអញនឹងលក់សដូវនេះទៅសមនឹងបានប្រាក់មួយរយរៀលដោយពិត, កាលបើអញបាន

ប្រាក់មកយ៉ាងនេះហើយអញនឹងទិញមេពពែពីរ , មិនយូរប៉ុន្មាន អញនឹងបានហ្វូងពពែកាន់តែច្រើន ដោយសារមេពពែទាំងគូនោះ ដែលសម្រាលកូនក្នុង៦មាសម្តង អញនឹងលក់ហ្វូងពពែទាំងនោះ ទៅទៀត យកប្រាក់មកទិញមាសបានមួយរយតម្លឹង ហើយអញ នឹងទិញមេសេះពីរទៀត អំណើះតទៅអញនឹងបានសេះច្រើន ព្រោះកើតភាលវាលគុម្ព អំពីមេសេះទាំងពីរនោះ អញនឹងលក់មេ សេះទាំងឡាយនោះទៅទៀតនឹងបានមាសកាន់តែច្រើនឡើងៗ ។

## ពន្យល់ពាក្យ

ទុគ៌ត គុ. ដែលដល់នូវសេចក្ដីលំបាក ដែលទ័លក្រ, ដែលក្រីក្រទ្រព្យ ដែលខ្វត់ទ្រព្យ ។ អនាថា គុ. ដែលឥតទីពឹង, ដែលឥតពំនឹង ឥតពំនាក់ ។ ស្វភាវ:ក្ឫបណា: (ថ.អ. ស្វ:ភាវ:ក្រិបណ: ) ន. ឈ្មោះរបស់ព្រាហ្មណ៍ នោះបើប្រែមកថា "អ្នកកំព្រាតាមធម្មតារបស់ខ្លួន" ។ កុសុមបុរី ន. ក្រុង ឈ្មោះកុសុម ។ ទិវាករ ន. អ្នកធ្វើនូវថ្ងៃ (ព្រះអាទិត្យ) ។ ឧទ័យ ន. ការ ឡើង, ការលេចឡើង ។ ប្រើជាកិ. "រះ" ។ អរុណ ន. ព្រះអរុណ, ព្រះអាទិត្យ

ដែលទើបភ្លឺក្រាលពីទិសខាងកើត, ពេលព្រឹកព្រហាមស្រាង ។ **អធ្យោគ** (អ. ថ. អ័ត- ធ្យោក) ន. ពាក្យប្រើក្លាយមកពីសំ. ម. អធិយោគ " ព្យាយាមមុតមាំ " ។ ខ្មែរយើងប្រើពាក្យនេះសំដៅសេចក្ដីថា " ការអត់ខន ឬ ការអត់អាស្រ័យឲ្យ, អត់ធ្មត់ " ។ ប្រើជា កិ. ក៏បាន ។ **អធ្យោគ អធ្យាស្រ័យ** អធ្យាស្រ័យអត់ខន ។ **យាចនដ្ឋាន** (អ. ថ. យាចៈ ណ័តថាន) ន. កន្លែងដែលជាទីសូម ។ **ទោតាគ** ន. បាយហាល; បាយដែលគេហាលឲ្យក្រៀមទុកបង្ការប្រើក្នុងគ្រាក្រ ។ **គ្រឹហា** (អ. ថ. គ្រឹះហ៊ា) ន. ផ្ទះលំនៅ ។ **អាត្មា** ន. ខ្លួន ។ **ភោជនាហារ** ន. អាហារសម្រាប់បរិ-ភោគ ។ **ដួងចៃ** ន. ហទយវត្ថុ, ចិត្ត, តួចិត្ត ។ **ភាជន៍** ន. ប្រដាប់សម្រាប់ដាក់ភោជនីយាហារមានបាយជាដើម ។ **ភត្ត** ន. បាយ, អាហារ ។ **មញ្ចកាដ្ឋាន** ន. កន្លែងនៃគ្រែ, កន្លែងដែលដាក់គ្រែ ។ **ភ័ព្វ** (អ. ថ. ភាប់) គុ. ដែលគួរ ។ ខ្មែរប្រើសំដៅសេចក្ដីថា " សំណាង, វាសនា " ។ **មានភ័ព្វ** គឺមានសំណាង ។ **ទុរ្ភិក្ស** (អ. ថ. ទុរ-ភិក) ន. (សំ; ម. ទុព្ភិក្ខ) ដំណើរក្របាយ, ដំណើរអត់បាយ ឬ អត់ឃ្លាន ។ **ឆមាស** ន. ប្រាំមួយខែ, បីខែពីរដង ។

# រឿងព្រាហ្មណ៍ទុគ៌ត (តចប់)

រួចហើយ អញនឹងសង់គ្រឹះស្ថានមួយមានល្វែងបួន រៀបចំឲ្យស្អាតបាតល្អ គួរជាទីសរសើរត្រេកអរនៃជនទិករដែលពិតពិលរមិលមើលមក ៗ សម័យមួយ មានព្រាហ្មណ៍ម្នាក់ស្លៀកពាក់យ៉ាងសង្ហាយាត្រាមកលេងលំនៅអញ បានឃើញផ្ទះដេរដាសដោយធនធាន មានសំហារិមកណ្ឌ គីតុបូគោអីច្រើន ក៏លើកកូនក្រមុំមួយ មានឆវិវណ្ណស្រស់បស់ឆើតឆាយ មានឫកពាមារយាទស្រគត់ស្រគំ សមរម្យដូចពួកស្រីទេពអប្សរបវរកញ្ញា សឹងមានកាត្នាអលង្ក្រិតវិភូសិត ដោយគ្រឿងធ្នមអម្ពរពស្ត្រាអលង្ការគ្រប់បែប ឲ្យមកជាភរិយារបស់អញ, លុះនៅរួមសុខទុក្ខស្រណុកកាយសប្បាយចិត្តយូរទៅ នឹងបានកូនប្រុសមួយ អញសន្មតនាមថា សោមសមិៈ ៗ គ្រាមួយ អញនឹកអផ្សុកអប្សាន្តក្នុងចិត្ត នឹងចូលទៅមើលសាស្ត្រាក្បួនច្បាប់ក្រឹត្យក្រមគម្ពីរដីកាក្នុងរោងសេះ ឯកូននោះវារតេះតះតើម ៗ

ដោយផ្គន់ចូលទៅតាមអញ អញនឹងក្តាញ់មួម៉ៅក្នុងចិត្ត ផ្សិត ប្រពន្ធអញរាប់បេះតែបណ្តោយ ឲ្យកូនវារលេងផ្តេសផ្តាស ទើប ហៅប្រពន្ធថា "គេហ៍អើយ! មកយកកូនទៅផងរុី" សោតឯ ប្រពន្ធនោះ កំពុងរវល់ខ្វល់វីវក់នឹងរៀបចំផ្ទះសំបែងមិនខ្វះខ្វែងស្រុះ ប្រញាប់មកយកកូន ឲ្យស្រែកទាន់ចិត្តអញឡើយ ៗ ក្សណ នោះ អញខ្ញរខ្ញីងធុរ ធ្វើខ្ពុលបុងប្រមុះ នឹងស្ទុះលោតផ្លោះទៅ ធាក់ប្រពន្ធដោយជើងទាំងពីរ "

ប៉ុង! ប៉ុង! ប្រាវខ្លាក! ឆ្នាំងដំពេញដោយសត្វត្រូវនឹងជើង ព្រាហ្មណ៍ដែលធាក់ដោយកំហឹង នឹងប្រពន្ធធន់មិនបានក៏ធ្លាក់ពី លើដៃកែវបែកខ្ទេច ស្មើគ្នានឹងគំនិតទើបតាព្រាហ្មណ៍ព្រឹទ្ធភ្ញាក់ខ្លួន ព្រើតកើតទោមនស្សតូចចិត្ត ត្បិតខាតទ្រព្យធនជាទុនដើម ។

អ្នកប្រាជ្ញទាំងឡាយបានយល់ស្ថានការណ៍នៃតាព្រាហ្មណ៍ ព្រឹទ្ធាចារ្យនេះហើយ ទើបប្រឌិតប្រព័ន្ធគាថាជាភាសាសំស្រ្កឹត ទុកជាជំបូន្មានមហាជនថា

ជនឯណាធ្វើនូវគំនិត    អនាគតពិតឥតប្រយោជន៍
រីជននោះពិតនឹងផ្សាខ្លោច    បង់ទ្រព្យហិនហោចដូច
ព្រាហ្មណ៍ព្រើល ។

## ពន្យល់ពាក្យ

ជនធិការ (អ.ថ. ជៈនៈ-) ប្រជុំជន, ពួកជន ។ សង្ហា (អ.ថ. សង់ហា) គុ. ដែលរុងរឿង, ដែលស្រស់បស់, ដែលថើតឆាយ, ដែលមានរូបល្អអង់អាច ។ ធនធាន ន. ទ្រព្យ, សម្បត្តិ ។ សំហារិមកណ្ឌ (អ.ថ. ស័ងហារិមៈ-ភ័ន) ន. ទ្រព្យ, របស់ ឬវត្ថុដែលនាំយក ឬ ដែលលើកយកទៅមកបាន, ដែលអាចធ្វើឲ្យកម្រើក ឬឲ្យឃ្លាតចាកទីបាន ។ ធនវណ្ណ ន. សម្បុរថ្លៃ, ពណ៌សម្បុរស្បែក។ ទេពអប្សរ ន. ស្រីទេពតា, ស្រីសួគ៌ ។ បវរកញ្ញា ន. ស្ត្រីក្រមុំដ៏ប្រសើរ ។ អលង្ក្រឹត (អ.ថ. អៈលុ័ងក្រឹត) គុ. ដែលធ្វើឲ្យសមរម្យ គឺដែលប្រដាប់តាក់តែងហើយ, ដែលប្រដាប់ឲ្យល្អ ។ វិភូសិត គុ. ដែលតាក់តែងហើយ ដែលស្អិតស្អាងស្រេចហើយ ។ ឆ្ពិមអម្ពរពស្ត្រា ន. សំពត់សម្រាប់ស្លៀកពាក់តាក់តែងខ្លួន, គ្រឿងប្រដាប់កាយ, គ្រឿងតែងខ្លួន ។ អលង្ការ (អ.ថ. អៈលុ័ងកា) ន. គ្រឿងប្រដាប់សម្រាប់តាក់តែងខ្លួន មានចិញ្ចៀន, កងដៃជើង ។

**សោមសមិ:** (អ. ថ. សោមះ ស័រះ ម៉ះ) ន. ឈ្មោះរបស់កូនព្រាហ្មណ៍នោះ ។ **អផ្សុក** ក. (ម. អផាសុក) ន. សេចក្ដីមិនសប្បាយ, ការព្រួយចិត្ត, ដំណើរមិនស្រួលចិត្ត ការខ្វល់ចិត្ត, មិនសប្បាយ, ព្រួយចិត្ត, ធុញទ្រាន់នៅមិនសុខ ។ **អប្បសាទ** (អ. ថ. អប់-ប្បាន) គុ. ដែលមានសេចក្ដីស្ងប់តិចគឺដែលព្រួយចិត្ត។ ច្រើនប្រើជាបរិភាសត្ថរបស់អផ្សុកជា *អផ្សុកអប្បសាទ* អផ្សុកខ្លាំង, អផ្សុកពេកទៅជារសាប់រសល់ខ្វល់ក្នុងចិត្ត ។ **សាស្ត្រា** (អ. ថ. សាស. ត្រ្តា) ន. ក្បួន, ច្បាប់ ។ **គម្ពីរ** ច្បាប់ឬក្បួនដែលរួបរួមជាពួកៗឬជាក្រុម ។ **ដីកា** ន. ឈ្មោះគម្ពីរដែលសំដែងសេចក្ដីអធិប្បាយប្រាប់ពន្យល់ ឲ្យពិស្ដារទូលំទូលាយងាយស្ដាប់បំណែកមួយ ដែលកែសេចក្ដីអធិប្បាយបន្ទាប់ពីអដ្ឋកថា ។ **គេហ៍** (អ. ថ. គេ) ន. អ្នកផ្ទះ ។ ពាក្យសម្រាប់ប្ដីប្រពន្ធហៅគ្នាទៅវិញទៅមកដោយស្មោះស្មើ ។ **ក្សណានោះ** (និបាតប្រាប់កាល) គ្រានោះ, វេលានោះ ។ **ព្រឹទ្ធ** គុ. ចាស់, ចំរើន (ម. វុឌ្ឍ) ។

---

# រឿងខ្លាចាស់ចាំសីល

មានខ្លាចាស់មួយ ធ្វើពិធីមុជទឹកលាងជំរះបាបក្នុងស្រះមួយ ហើយកាន់ស្បូវក្តាំងឡើងមកឈរទៀបមាត់ស្រះ ស្រែកដង្ហោយ

ហៅអ្នកដំណើរម្នាក់ថា “នែអ្នកដើរ ! មកយកកងមាសឯណោះ ចា ៗ ក្សណនោះ អ្នកដំណើរឮដូច្នោះហើយ ក៏កើតមានអភិជ្ឈា គឺការចង់បានអន្ទះសាខ្វារក ដោយសេចក្ដីលោភហួសប្រមាណ ទើបគិតថា “អាត្មាអញមានបុណ្យវាសនាធំណាស់តើ ! ត្រូវបាន កងមាស តែក្នុងទីនេះ ប្រកបដោយសេចក្ដីភ្កៀសសម្បដិភ័យ ក្រែងមានសេចក្ដីអន្តពយ ឧបាទវ៍ណាមួយ កើតមានដល់អាត្មាអញ ទេដឹង អាត្មាអញមិនគួរពានពារខ្លួនទេ ព្រោះមានសុភាសិត ថា “កុំដើរពានស្កុន កុំស្កាត់ប្រកផ្លូវ កុំផ្ញើស្រែស្រូវ នាផ្លូវដើរ” ៗ ទឹកអម្រឹតលាយដោយពិសពុល មានក្នុងទីណា ទីនោះគេអាប ស្អប់បាន ៗ ការស្វែងរកទ្រព្យសម្បត្តិក្នុងទីទាំងពួង នឹងថាមិន ត្រូវពានពារឧបសគ្គឧបទ្ទវៈណាមួយ ក៏មិនមែនដែរ ៗ គិតដូច្នោះ ហើយក៏ស្រែកសួរតបម្ដាយថា “នៅឯណាកងនោះ ? ” ៗ ខ្លា លើកជើងមុខបង្ហាញឲ្យមើល ៗ អ្នកដំណើរឆ្លើយថា “ធ្វើម៉េចឲ្យ ខ្ញុំទុកចិត្តស្និទ្ធស្នាលនឹងអ្នកឯងបាន បើឯងជាសត្វខ្លា មានហឹសាជា ប្រក្រតី ចូលចិត្តស៊ីសាច់ប្របាច់គេដូច្នេះ ” ៗ ខ្លាឆ្លើយថា “នែ

អ្នក! អ្នកចូរស្ដាប់ខ្ញុំ កាលខ្ញុំនៅពីបឋមវ័យ ខ្ញុំប្រព្រឹត្តអាក្រក់ ដូច្នោះមែនដោយសារអំពើអាក្រក់ដែលខ្ញុំបានធ្វើនោះតាមផ្ដល់ឲ្យ ផល កូនប្រពន្ធខ្ញុំស្លាប់ហិនហោចអស់ ខ្ញុំផុតពូជអម្បូរអស់ហើយ នៅកំព្រាត្រមោចតែម្នាក់ឯង ។

## ពន្យល់ពាក្យ

អភិជ្ឈា ន. (< អភិ + ឈា) ការចង់បាន, ការចង់បានហួសហេតុ ហួសទំនង, ការចង់បានណាស់, ចង់បានហួសពេក ។ សប្បដិភ័យ (អ ប. សប៉ប៉ះដិភៃ) គុ. ដែលប្រកបដោយភ័យធំពន្លឹក, ដែលប្រកបដោយភ័យគួរភ្ញាក់, ដែលភ័យខ្លាំង ។ ហឹសា ន. ការបៀតបៀន, ការធ្វើទុក្ខគ្នា, ការធ្វើអាក្រក់ចំពោះគ្នា ។

## រឿងខ្លាចាស់ហឹសីល (ត)

បំណោរបីរកាលតមក មានតាបសជរាជរមួយរូប មានសេចក្ដី អាណិតអាសូរដោយការពេញភាពដ៏ខ្ពង់ខ្ពស់ចំពោះខ្ញុំ បានទូន្មានខ្ញុំ ដោយពាក្យដំបូន្មានដ៏ប្រសើរផ្សេងៗ ប្រដៅខ្ញុំថា "នែអ្នក! អ្នក ចូរប្រព្រឹត្តធម៌ ចូរសមាទានរក្សាសីល កុំប្រព្រឹត្តអាក្រក់ កុំ

ៀតបៀនប្រមាថពាធជន្មជនដទៃ ក្រែងទោសពៀរនឹងមានដល់

ាត្មា” ៗ តាំងពីកាលនោះមក ខ្ញុំប្រតិបត្តិតាមពាក្យ

ណ្តាំរបស់តាបសបុរសនោះ មិនហ៊ានប្រព្រឹត្តគន្លង ធ្វើបាន

បុន្មាននោះទេ តែងប្រព្រឹត្តមុជទឹកលាងបាប កាន់និច្ចសីល

ើបុណ្យឲ្យទានជាប្រក្រតី មានមេត្តាករុណា ពេលនេះខ្ញុំក៏

ាន់តែចាស់ជរាទុព្វលភាព កំឡាំងពលំកំពុំសូវមានបរិបូណ៌

ញក្រេបគក់រេចរលអស់រលីងហើយ ដូចម្តេចក៏អ្នកនៅតែមិន

ៀទុកចិត្តខ្ញុំ មិនព្រមយកខ្ញុំជាវិស្សាសកូមិតទៅ ? នែអ្នក !

ឡូវខ្ញុំអស់សេចក្តីលោភលើងហើយ រហូតដល់មកបានចិត្ត

ាថ្នានឹងបរិច្ចាគកងមាស ដែលនៅក្នុងដៃខ្ញុំនេះ ឲ្យជាទាន

ល់អ្នកណាមួយថែមទៀត តែទោះបីខ្ញុំប្រព្រឹត្តល្អមានធម៌នៅក្នុង

ន្តានចិត្ត ប្រព្រឹត្តលាងជំរះបាបដូច្នេះហើយ ក៏នៅតែពិបាក

ងគេចវៀះវៀសវាងឲ្យផុត ពីពាក្យគរហានិន្ទានៃមនុស្ស

ព្រោះមនុស្សលោកតែងនិយាយប្រាប់កូនចៅថា សត្វខ្លាស៊ី

ាប់មនុស្ស ៗ

# ពន្យល់ពាក្យ

**តាបស** (អ. ប. តាបស់) ន. អ្នកបួសខាងក្រៅពុទ្ធសាស កាន់ព្រហ្មចរិយធម៌ វៀរចាកមេថុនធម៌ ប្រព្រឹត្តកាន់តបៈ គឺការប្រព្រឹត្តកាន់ យ៉ាងតឹង ដើម្បីធ្វើកាយចិត្តឲ្យស្ងប់ ។ **ជដាធរ** ន. ( < ជដា "ផ្នួងស ព្រៃស្អាប់; ធម្មជាតិដែលទ្រុបទ្រុល, ចាក់ស្រែះ កណ្ដាញ់ដូចជាផ្នួងសក់ ឬ ជាព្រៃស្អាប់ (តណ្ហា) + ធរ "អ្នកទ្រទ្រង់") អ្នកទ្រទ្រង់ផ្នួងសក់, ទុកផ្នួងសក់ ។ **ការុញ្ញភាព** ន. ភារៈនៃសេចក្ដីអាណិត ។ ឧត្ត ភាព ន. ភាវៈជាអ្នកមានកម្លាំងជ័យ ឬជ័យកម្លាំង ឬជា ដែលទ្រមចមទ កម្លាំងដុនជាបទុរនទុក ។ **វិស្សាសភូមិ** (អ. ប. វិស- សាសៈភូមិ) ភូមិឬជាន់, ថ្នាក់លំដាប់នៃសេចក្ដីស្និទ្ធស្នាល, ដំណើរជឿចិត្តគ្នា ។ **បរិច្ចា** (អ. ប. បរិច្ចាគ) ន. ការលះទ្រព្យធ្វើអ្វីមួយ ឲ្យជាប្រយោជន៍ក្នុងស្រុក ប្រទេស ។ ប្រើជា កិ. "លះ, លះបង់" ។ **គរហា** (អ. ប. គរះ ហ ន. ពាក្យតិះដៀល, ពាក្យដំណិះដំនៀល, ពាក្យដៀល ។ **និន្ទា** (អ. ប និន្ទា) ន. ដំណើរតិះដៀល, ដំនៀល ។

## រឿងខ្លាចាស់ហិសីល (ត)

*មនុស្សលោកតែងរៀនទៅតាមដំណើរការណ៍ដែលក*

ៅហើយ មិនយកធមិជាប្រមាណ ខ្ញុំបានរៀនគម្ពីរធម្មសាស្ត្រ
ះចប់អស់ដើមហើយ ក្នុងគម្ពីរនោះលោកប្រដៅថា ជីវិតរបស់
ន ជាទីស្រឡាញ់ពេញចិត្តខ្លួនយ៉ាងណា, ជីវិតរបស់ជនដទៃ
យ៉ាងនោះដែរ លោកសប្បុរសតែងធ្វើសេចក្តីស្មោះស្ម័គ្ររាប់
ាន អាណិតអាសូរចំពោះសព្វសត្វ ព្រោះលោកយកខ្លួន
បស់លោកជាគ្រឿងឧបមា ។ ម្យ៉ាងទៀត ភ្លៀងដែលបង្អុរចុះ
កលើផែនពសុធាដែលរីងស្ងួតហួតហែងយ៉ាងណា ការឲ្យភោជ-
ាហារដល់ជនស្រេកឃ្លាន អត់បាយក្រហាយទឹកក៏ដូច្នោះដែរ ។
ារឲ្យទានបានផលានិសង្សច្រើននោះគឺឲ្យទានដល់មនុស្សក្រីក្រ
ាកយ៉ាក ឯខ្លួនអ្នកនេះ ជាមនុស្សកំសត់ទុគ៌តក្រៃលែង ព្រោះ
ហតុនោះបានជាខ្ញុំខ្នះខ្នែងជាបំផុត ដើម្បីនឹងបរិច្ចាគទានដល់អ្នក
ព្រោះខ្ញុំយល់ជាក់ច្បាស់ថា ទានជារបស់ត្រូវតែឲ្យ តែបើឲ្យដល់
កមិនមានឧបការគុណ ក៏មិនសូវបានកុសលផលបុណ្យច្រើន
ន្មានដែរ, ការឲ្យទានដែលមានមហប្ផលនោះ គឺឲ្យត្រឹម
វតាមកាលៈទេសៈ នឹងឲ្យដល់បុគ្គលដែលមានឧបការៈគួរឲ្យ។

ហើយចុះអ្នកចូរទៅមុជទឹកលាងបាបក្នុងត្រពាំង ឲ្យស្អាតបា
សិន សឹមឡើងមកយកកងមាសពីខ្ញុំទៅ ។ ក្បិណានោះ អ្ន
ដើរផ្លូវ លុះឮពាក្យខ្លាចាស់ ពោលលួងឲ្យវង្វេងស្មុគគំនិ
ដូច្នោះហើយ ក៏ដើរចុះទៅមុជទឹកលាងបាប ក្នុងត្រពាំងមួយ
តែស្រះនោះ ស្រាប់តែផុងខ្លួនលង់ទ្រនេសជាប់ក្នុងភក់លប់ ទី
គេចរៀះរត់លូនទៅពួនឯណាក៏ពុំបាន ។

## ពន្យល់ពាក្យ

ការណ៍ (អ. ថ. កា) ន. ហេតុ ។ ធម្មសាស្ត្រ
(អ. ថ. ធ័ម ម៉ះ សាស) ន. ឈ្មោះគម្ពីរមួយដែលអានសំដែងសេចក្ដីអំពីយុត្ត
ធម៌ ។ ឧបមា (អ. ថ. អ៊ុប៉ះម៉ា) ន. សេចក្ដីប្រៀបធៀប, ការប្រៀបប្រដូច
ការប្រៀបផ្ទឹម ។ ប្រើជា កិ. "ប្រៀប, ប្រៀបប្រដូច, ប្រៀបដូចជា"
ពសុធា ន ផែនដី ។ ភោជនាហារ ន. អាហារសម្រា
បរិភោគ ។ ផលានិសង្ស (អ. ថ. ផះ ល៉ានិសង់) ន អានិ
សង្សនៃផល, ការហូរមកមិនដាច់នៃផល ។ ឧបការគុណ ន. គុណ
ដែលមានព្រោះទំនុកបំរុង ។ មហប្ផល ន. ផលច្រើន ។ ឧប

ភាព: ៦. ការទំនុកបំរុង, ការផ្ដួចផ្ដើម, ការផ្គត់ផ្គង់, ប្រយោជន៍, គុណប្រយោជន៍ ។

# រឿងខ្លាចាស់ចាំសីល (ត)

ឯខ្លាចាស់ កាលបានឃើញបុរសដើរផ្លូវផុនលន់ទ្រទេសសិប់ ជាប់រើបច្រុះខ្លួនមិនរួចផ្លូវបោះហើយ ទើបក្លែងធ្វើជាស្រែកជួយភ័យថា « អា! អា! យើអើ! អ្នកផុនលន់ក្នុងកក់ល្បប់ហើយតើ, មិនអីទេ! មិនអីទេ! ចាំខ្ញុំទៅជួយយកគេយានស្រោចស្រង់ឡើងប៉ិពីព្យតោបាត អ្នកកុំភ័យ » ថាហើយក៏ដើរចុះទៅ សន្សឹម ៗ ធ្វើហាក់ដូចជាស្ងួនស្ងាបបន្តិច ១ ខ្លាចផ្លន់ខ្លួនឯង ចូលទៅចាប់អ្នកដំណើរនោះជាប់ ។ ឯអ្នកដំណើរនោះ កាលបើខ្លាចាស់ចាំសីល កកិលចូលទៅសង្គ្រុបគ្រប់ខ្ទាប់កណ្ដៃ រត់ទៅណាពុំរួចផ្លូវបោះហើយ ក៏នឹកគណិតខ្លួនពេកយំសម្រក់ទឹកភ្នែកហូរសស្រាក់ ហៀរជោរជោកថ្ពាល់ ទាំងសង្ខាន់កើតសង្វេគតក់ស្លុតចំពោះជីវិតសង្ខារ ពោលពាក្យត្រះតិះដៀល

បន្ទោសខ្លួនឯងថា "ឱ! មនុស្សចិត្តអាក្រក់សាមាន្យ នឹងសំគាល់បានដោយគ្រាន់តែចេះគម្ពីរធម្មសាត្រក៏មិនមែន ឬថាចេះស្វាធ្យាយមន្តអាគមគាថាតម្រាសៃយវេទ ក៏មិនមែនដែរ ។ ការធ្វើអ្វីផងទាំងពួង នៃមនុស្សមានឥន្ទ្រិយ មិនស្រគត់ស្រគំ មានលំនាំសមសារ ឬកពាកិរិយាមារយាទ មិនលុះក្នុងអំណាចខ្លួន ក៏ប្រាកដដូចជាការលាងដំរះដំរី ឥតបានផលប្រយោជន៍អ្វីតិចតួចឡើយ ។ ម្យ៉ាងទៀត បំណេះវិជ្ជាកាលបើប្រាសចាកការប្រព្រឹត្តប្រតិបត្តិធ្វើឲ្យជាប្រយោជន៍ហើយ ក៏នាំឲ្យធ្ងន់ខួរក្បាលអសារឥតការ ដូចគ្នានឹងការបំពាក់គ្រឿងអលង្ការណ៍ ដែលមានលំអអនេកអនន្តឲ្យកិរិយាចង្រៃក្បត់ចិត្តដូច្នោះឯង ។

## ពន្យល់ពាក្យ

ព្យគោចាត ន. (សំ.វ្យគោបាត) ខាតយ៉ាងធំ, សេចក្ដីលាញធំ។ សង្ខារ ន. ការពាក់តែង គ្រឿងប្រកប, គ្រឿងប្រុង; ជីវិត ។ ធម្ម. សាត្រ (អ. ថ. ធ័មមះសាត) ដូចគ្នានឹងធម្មសាស្ត្រ មើលពាក្យនោះ ។

ស្វាធ្យាយ កិ. សូត្រ ឬខ្សឹប ៗ, ទន្ទេញ ។ សៃយវេទ ន. ឈ្មោះគម្ពីរមួយបែបប៉ែកខាងលទ្ធិព្រាហ្មណ៍ ។ អលង្ការណ៍ (អ. ថ. អះល៊ុងក) ន. គ្រឿងតែងខ្លួន, ឬគ្រឿងប្រដាប់សម្រាប់តែងខ្លួន ។

## រឿងខ្លាបាស់បាំសីល (តចប់)

អាត្មាអញធ្វើសេចក្តីស្និទ្ធស្នាលទុកចិត្តមនុស្សទុរជនអាក្រក់សាមាន្យ មានសន្តានចិត្តឥតដឹងគុណគេយ៉ាងខ្លានេះ ដោយហេតុណា, ដោយហេតុនោះ អាត្មាឈ្មោះថាប្រមូលកៀគរនូវគំនរទុក្ខដ៏គណ្ឋក មកប្រគល់ឲ្យខ្លួនឯងវិញទេតើ, ឱសត្វអកតញ្ញូ តែងសំឡឹងទោសពៃរគេជានិច្ចហ្ន៎! ហេតុនេះហើយបានជាអ្នកប្រាជ្ញចាស់ទុំជំនាន់បុរាណ តែងទូន្មានមហាជនថា នរជនមិនគួរស្នេហ៍ស្និទ្ធទុកចិត្តទឹកទន្លេ, បុគ្គលមានគ្រឿងសស្ត្រាវុធយុទ្ធកណ្ឋកក្នុងដៃ, សត្វមានក្រចកមុត, សត្វមានស្នែង និងស្រីស្នំក្រមការ ក្នុងរាជត្រកូលទាំងឡាយឡើយ ។ ឱអញអើយ ! មុខជាស្លាប់អសារឥតការ ក្នុងកណ្តាប់ដៃខ្លាចង្រៃនេះមិនខាន ។

មិនមែនតែអាត្មាអញម្នាក់ឯងទេ សូម្បីព្រះបន្ទូលទ្រង់នូវសហស្ស-រង្សី ត្រាច់ចររុងរឿងព្វជំនកាល័យ កំចាត់បង់នូវងងឹតអន្ធការ អ័ព្ទសូន្យស្រុងកណ្តាលដួងតារា ក្នុងទិសាសន្ធ្យាកាល សូម្បីមានឫទ្ធិតេជះអំណាចដល់ម្ល៉ោះ ដល់វេលាគ្រោះជោគគ្រោះជាំមកដល់ កំត្រូវរាហូចាប់លេបបានដែរ, នរណាហ៊ុន ទឹងគេចវេះឲ្យផុតអំពីលិខិត ដែលព្រះម្ចាស់ត្រាទុក ព្វជ័ថ្វាសបាន ។

ឱគួរសង្វេគ! អ្នកដំណើរនោះ កំពុងវិតក្កទល់ទុក្ខយ៉ាងក្រៃលែង ស្រាប់តែត្រូវខ្លាចាស់ចាំសីល ខាំជញ្ជូនហែកស៊ី សូមឲ្យជីវិតេន្ទ្រិយអន្តរធាន ព្វជ័កាលគ្រានោះឯងហោង ។

## ពន្យល់ពាក្យ

ស្វ័រជន ន. ជនដែលស្វ័រ, ដែលកំណាញ់រឹតត្បិតតតក្អស ។ យុទ្ធកណ្ឋា (ស.ថ. យុគធៈភ័ណ) ន. គ្រឿងបំពាំង ។ ស្នំក្រាម-ការ ន. ស្រីអ្នកបំរើក្សត្រទ្រង់រាជ្យ, ពួកស្ត្រីស្នំអ្នកធ្វើការបំរើក្សត្រទ្រង់រាជ្យតាមលំដាប់វេន គឺធ្វើការចេញវេនចូលវេនតាមលំដាប់ ។ សហស្សរង្សី ន.

អ្នកមានរស្មីច្រើន (ព្រះអាទិត្យឬព្រះចន្ទ) ។ អន្ធការ ន. ងងឹត ។ តារា (ស. ប. ដារា) ន. ផ្កាយ ។ និសា ន. យប់, រាត្រី ។ សន្ធ្យាកាល ន. កាលជាទីអស្តង្គតនៃព្រះអាទិត្យ, វេលាថ្ងៃលិច ។ វិតក្កា ((ស. ប. វិតុក) ន. ក្រើជា កិ. ត្រិះរិះ ។ សុញ្ញ (ស. ប. ឝ្យូន) គុ. ឃែត, ទទេ, សោះ, ពេង ។ អន្តរធាន ន. ការខូច, សេចក្តីវិនាស, ខ្មែរប្រើជា, កិ. " បាត់, ខូច វិនាស, អន្តរាយ, ខូចបង់ " ។

---

# រឿងព្រះបាទតុង្គពលរាជ

នៅក្នុងប្រទេសកាន្យកុព្ជៈ មានព្រះរាជាមួយព្រះអង្គព្រះនាមវីរសេនរាជ ។ ព្រះរាជាអង្គនេះ បានប្រគល់រាជសម្បត្តិថ្វាយព្រះរាជឱរសមួយព្រះអង្គ ព្រះនាមតុង្គពលរាជ ឲ្យគ្រប់គ្រងវីរបុរីរាជធានី រក្សាប្រទេសជាតិមាតុភូមិស្នងអង្គ តវង្សទ្រង់ព្រះករុណារៀងរាបមក ។ ព្រះរាជបុត្រអង្គនេះ ទ្រង់តាំងនៅក្នុងប្រថមវ័យឧត្តម សម្បូណ៌ដោយស្រីស្នំក្រមការនីស្រីស្រឹង្គារបរិវារ ព្រមទាំងព្រះរាជទ្រព្យទាំងឡាយ ។

ថ្ងៃមួយ កាលព្រះបាទទុគ្គពលរាជ ស្ដេចយាងចេញលំហែព្រះទ័យតាមវិថី ក្នុងព្រះរាជធានី ទ្រង់បានទៀងព្រះនេត្រទតទៅឃើញកិរិយាបុត្រពាណិជម្នាក់ឈ្មោះនាង លាវណ្យវតី ជាស្ត្រីនៅកំពុងពេញតរុណវ័យ ល្អឥតខ្ចោះត្រង់ណា ៗ លុះព្រះរាជាយាងត្រឡប់ ចូលកាន់និវេសន៍វាំងវិញ ព្រះរាជហឫទ័យពេញពោរដោយសេចក្ដីស្នេហា បងចាំរូបសោភានៃនាងនោះមិនភ្លេចសោះ ដូចជាត្រូវសររបស់កាមទេព ទ្រាំមិនបានក៏ទ្រង់ត្រាស់ព្រះរាជបញ្ជា ឲ្យស្ត្រីមេអណ្ដើកម្នាក់ ទៅនាំនាងនោះមកថ្វាយ ៗ រីឯនាងលាវណ្យវតីតាំងពីបានប៉ះភ្នែកដោយព្រះនេត្រព្រះបាទទុគ្គពលរាជ ក៏មានចិត្តប្រតិព័ទ្ធនឹកមមៃពុំមានភ្លេច ហាក់ដូចជាត្រូវបួសដោយសរ ដែលព្រះកាមទេពថ្វេងមកចំដួងចិត្តចាប់ពេតស្អិតគិតតែផ្លូវមួយ ៗ

## ពន្យល់ពាក្យ

ការឲ្យការុញ្ញៈ (អ.ថ. កាន-យ: គុបហ្ស៊ែ) ។ រាជសម្បត្តិ

(អ.ថ. ភជៈសំបាត់) ន. សម្បត្តិសម្រាប់ព្រះរាជា ។ តុង្គពលរាជ (អ.ថ. តុង-គៈពៈ-លៈរាជ) ។ ប្រថមវ័យ (អ.ថ. ប្រថៈមៈវ៉ៃ) ន. វ័យទី១ ។ ស្រី ស្រឹង្គារ ន. ស្រីដែលមានលំអគួរឲ្យកើតសេចក្ដីស្រឡាញ់ ។ វិថី ន. ផ្លូវ ។ នេត្រ (អ.ថ. នេត) ន. ភ្នែក ។ ពាណិជ ន. (អ.ថ. និច) អ្នកជំនួញ, ឈ្មួញ ។ លាវណ្យវតី (អ.ថ. លាវ័ន យ៉ះ វតី) ។ តរុណវ័យ ន. វ័យនៅក្មេង, នៅជំទង់, នៅក្រមុំ ។ រូបសោភា ន. លំអនៃរូប ។ ប្រតិព័ទ្ធ កិ. ស្រឡាញ់ ។

## រឿងព្រះបាទតុង្គពលរាជ (ត)

គ្រាកាលដែលនាងលាវណ្យវតី ស្រីចិត្តចើក បានស្ដាប់ពាក្យដឹកនាំនៃនាងមេអណ្ដើកនោះហើយ ក៏ក្លែងធ្វើកលមាយា តែក្រោយនិយាយម៉ិកម៉ក់តបថា “ខ្ញុំមានចិត្តស្មោះស្ម័គ្រស្មូរ័កស្និទ្ធស្នេហាចំពោះស្វាមី ឲ្យខ្ញុំប្រព្រឹត្តល្មើសក្បត់ចិត្តប្ដីខុសគន្លងធម៌ ជាអតិចារនៃស្រីខាតល័ក្សណ៍ដូចម្ដេចកើត ? ព្រោះថា បើកស្ដា

ពេញចិត្តស្និទ្ធស្នាល បំពោះពនិតាជាភរិយាហើយ សូម្បីពួក ទេវតាទេពារក្ស ក៏ជួយអភិរក្សកែកាយស៊ើបសរសើរជាពុំខាន ហេតុនេះ បើស្វាមីជាម្ចាស់ប្រាណខ្ញុំ មានបំណងយ៉ាងណាក្តី រឿងនេះ ខ្ញុំប្រតិបត្តិតាមបំណងនោះ ខ្ញុំពុំហ៊ានឆ្វេសទ្វៃប្រែ ប្រែកែក ដោះសារេពចិត្តឡើយ ” ។ ឮដូច្នោះហើយ នាង មេអណ្តើកនោះ ក៏ហោះត្រឡប់ចូលទៅកាន់ព្រះរាជគំនាល់ នាំ យកសេចក្តីទៅក្រាបបង្គំគាល់ ព្រះករុណាព្រះបាទតុង្គពលរាជ តាមដំណើរការណ៍ ដែលភរិយាពាណិជបុត្រ សាស័ត្វក៏យ៉ាប់ ប្រាប់មក ឲ្យព្រះករុណាទ្រង់ជ្រាបសព្វគ្រប់ប្រការ ។

ព្រោះនិទាននេះ ព្រះបាទតុង្គពលរាជ ទ្រង់ព្រះសណ្តាប់ អស់អាថ៌សេចក្តីសព្វសេចគ្រេច ទ្រង់ក៏នៅតែមិនជាប់ព្រះទ័យ ពីនាងនោះ ទើបមានព្រះរាជឱង្ការថា បើដូច្នោះ តើគិតដូចម្តេច ឲ្យប្តីវាសុខចិត្តព្រមនាំនាងលាវណ្យវតីនោះមកថ្វាយអញបាន ? នាងមេអណ្តើកក្រាបទូលថា សូមទ្រង់រិះរកមធ្យោបាយដ៏វិសេស ឲ្យម៉ឺនម៉ាត់ម៉ត់បត់ បើព្រះករុណាទ្រង់ព្រះតម្រិះរកកល • ឧបាយ

ស្រួលហើយនោះ មិនចាំបាច់ប្រើព្យាយាមទេ ។

## ពន្យល់ពាក្យ

រម្យរតិ គិ. រួមសេចក្ដីស្រឡាញ់ គឺរួមដំណេក របស់បុរសនឹងស្ដ្រី ។ អតិចារិនី (អ. ថ. អៈតិចារិណី) ន. ស្ដ្រីផិតប្ដី, ស្ដ្រីប្រព្រឹត្តកន្លងចិត្តប្ដី ។ ភស្តា (អ.ថ. ភ័សស្ដា) ប្ដី ។ ពនិតា ន. ស្ដ្រី, ភរិយា ។ ឆេពារក្ស ន. ទេពតាអ្នកបីបាច់រក្សាលោក ។ អភិរក្ស គិ. រក្សាដោយប្រយ័ត្ន ។ ពាណិជបុត្រ ន. កូនអ្នកជំនួញ ។ និទាន ន. រឿង, ដើមហេតុ, ហេតុ ។ អាជិ (អ.ថ. អារ) ន. សេចក្ដី, ប្រយោជន៍ ។

## រឿងព្រះបាទតុង្គពលរាជ (៣)

សម្ដេចព្រះជៀសជ័យចេស្ដា លុះទ្រង់ព្រះសវនាការពាក្យទូលទេស នៃនាងមេអណ្ដើកនោះហើយ ទើបទ្រង់ត្រាស់ឲ្យហៅ កូនពាណិជឈ្មោះ ចារុធត្ត ជាស្វាមីនៃនាងលាវណ្យវតី ឲ្យចូលមកកាន់ព្រះរាជគ្រឹហា ទ្រង់តាំងជាព្រះរាជសេវកនៅបំរើផ្ទាល់ព្រះអង្គ តែងប្រោសប្រោណមេត្តារាប់អាន

ដោយសេចក្ដីស្និទ្ធស្នាលដ៏ក្រៃលែង ។

ថ្ងៃមួយ ព្រះបាទតុន្ធពលរាជ ទ្រង់ស្នានព្រះឧទកវារីស្រេច ស្ដេចប្រោះព្រំព្រះសពាង្គកាយ ដោយគ្រឿងគន្ធពិដោរឈ្ងុយឈ្ងប់ក្រសអួបពួសាយ ទ្រង់ប្រដាប់ដោយគ្រឿងអលង្ការដ៏ហើយដោយមាសពេជ្រនិលចិន្ដាមណី ក្សត្រាទ្រង់ចរចារួសរាយសប្បាយព្រះទ័យ មួយអន្លើដោយសហការីរបស់ព្រះអង្គ ។ ក្រោយនោះ ទ្រង់មានព្រះបន្ទូលសួរសីហនាទ ទៅកាន់កូនពាណិជថា “ម្នាលបារុទត្ត! ចាប់តាំងពីថ្ងៃនេះតទៅ យើងនឹងធ្វើពិធីគោរព្រេត ថ្វាយទេពតាចំនួនមួយខែ, ដូច្នេះអ្នកត្រូវទៅស្វែងរកស្ត្រីក្រមុំ មានរូបសក្ដិសមល្អ ជាស្ត្រីមានត្រកូលយកមកឲ្យយើងមួយនាក់ ៗ រាល់រាត្រី យើងឲ្យទ្រព្យសម្បត្តិមាសប្រាក់កែវពិទូរ្យសូរ្យកាន្ត នឹងឋានន្តរស័ក្តិយសតាមកម្មវិធី-បុណ្យ ” ។ ឯបារុទត្តពាណិជបុត្រ ក៏ទទួលព្រះរាជឱង្ការចាត់ចែងរកស្ត្រីក្រមុំថ្មី ៗ តាមព្រះរាជសា យកមកថ្វាយរាល់វេលារាត្រីពុំដែលលស់ខាន ហើយពួនសម្ងំចាំមើលឲ្យដឹងថា

ព្រះករុណាទ្រង់ធ្វើដូចម្ដេចខ្លះ ។

## ពន្យល់ពាក្យ

ចេស្ដា ន. តេជះអំណាចនៃព្រះមហាក្សត្រិយ៍ ។ សវនាការ

. អាការនៃកិរិយាស្ដាប់, អាការស្ដាប់ ។ ឧបទេស ន. ការពន្យល់, ការ

ណែនាំ, ការឲ្យន័យឲ្យទំនង, ការបញ្ចេះ, ការប្រៀនប្រដៅ ។ រាជគ្រឹហា

. រាជនិវេសន៍ ។ រាជសេវកា ន. មន្ត្រីអ្នកគាល់បំរើព្រះរាជា, ខ្ញុំរាជការ

ព្រះអង្គ ។ ស្នានកិ. (រាជស័ព្ទ) ទ្រង់ស្រង់ទឹក ។ ឧទកភារី ន.

ក ។ សព្វាង្គ (អ. ថ. ស័ព ពាង) អវយវៈទាំងអស់ ។ គន្ធពិដោរ

. ក្លិនក្រអូបល្អយល្ងប់, ក្រអូបល្អ ។ ពេជ្រ ន. ឈ្មោះត្បូងវិសេស

នសាច់រឹងមានពន្លឺបាំងផ្លុះព្រាត ៗ ។ និល ន. ឈ្មោះត្បូងពណ៌ខៀវ (ត្បូង

ណ្ឌៀង) ។ ចិន្ដាមណី (អ. ថ. ចិណ្ដាមៈនី) ឈ្មោះកែវ ១ យ៉ាង ។

បហាការី ន. អ្នកធ្វើការជាមួយគ្នា ។ ស្ររសីហនាទ ន.

ហនាទដ៏ក្លៀវក្លា, ព្រះរាជាព្រះករុណាទ្រង់រាជ្យប្រកាសឲ្យសាធារណជនដឹង ។

ភាវីព្រាន (អ. ថ. ព្រាត់) ឈ្មោះពិធីបុណ្យ ១ យ៉ាងខាងសាសនាព្រាហ្មណ៍។

ទ្យុះ ពេជ្រឆ្អែកផ្កា ។ កម្មវិធី ន. វិធីនៃកម្ម របៀប ឬ បែបនៃអំពើដែល

ត្រូវធ្វើ ។ រាជាសា (< រាជ + អាសា) ន. បំណង ឬ សេចក្ដីត្រូវការនៃព្រះរាជា ។

## រឿងព្រះបាទតុង្គពលរាជ (តចប់)

បពិត្រអើយ ក្នុងកាលនោះ សម្ដេចព្រះភូវន័យបរមបរមេស្ឋ ទ្រង់សណ្ឋិតក្នុងទូរដ្ឋាន មិនបានធ្វើឲ្យប៉ះពាល់ដល់សរីរាវយវៈ នៃស្ត្រីក្រមុំព្រហ្មចារីទាំងនោះទេ ទ្រង់ព្រះរាជទានគ្រឿងអលង្ការ ធ្មុមអម្ពរពស្ត្រា លំអិតខ្ចុមចន្ទន៍សក្រហម ព្រមទាំងគ្រឿងស្លៀកពាក់ សុទ្ធសឹងតែមានដំឡៃអនេកអនន្ត ហើយបង្គាប់ឲ្យរាជង្គរក្សាថែរក្សាមើលការខុសត្រូវជូនដំណើរត្រឡប់ទៅគ្រឹហាឋានវិញ មិនឲ្យមានមោះហ្មងអ្វីសូម្បីបន្តិចបន្តួចឡើយ ។ ចារុទត្តបុត្រពាណិជ លបមើលឃើញរាជព្រឹត្ត ដ៏បរិសុទ្ធសព្វគ្រប់ប្រការដូច្នោះហើយ ក៏ជឿទុកចិត្តស្ងាប់គំនិតឈឹង សំឡឹងមើលទៅពួកនារីទាំងនោះ ឃើញបានរបស់ល្អ ៗ ក៏មានសេចក្ដីលោភខុសទំនង ទើបទៅនាំកិរិយាខ្លួន យកមកថ្វាយ ។

ព្រះបាទតុង្គពលរាជ គ្រាន់តែឃើញនាងលាវណ្យវតីស្រីកំពូលព្រះទ័យមានលំអដ៏ប្រសើរដែលទុកស្មើកែវវិសេសមកដល់ភ្លាម ទ្រង់ត្រេកអរសប្បាយព្រះទ័យ ស្ទុះរវះរវាមទៅចាប់ត្រកងប្រកៀកប្រឱបដក់ថើប នាំទៅឯទៃនទីសយនាគ្រឡាព្រះបន្ទំ ភ្លើតភ្លើនព្រះចិន្តាភ្លេចស្មារតី បើកព្រះនេត្រព្រឹម ៗ ត្រដាក់ដួងកមលស្កល់ព្រះរាជហឫទ័យ ៗ ឯចារុទត្តជាស្វាមីបានឃើញដូច្នោះអស់បើគិតក័ន្ទភាំងគំនិតគាំងរេងស្លុក ឈរទើងថ្កល់ដូចកល់រូបគំនូរទោមនស្សតូចចិត្តយ៉ាងក្រៃលែង ៗ ព្រោះហេតុនោះឯង បានជាលោកនិព័ន្ធគាថាថា បុត្រពាណិជបានឃើញព្រះរាជាចាប់ប្របាច់ដោះក្បុំក្រពុំដូចផ្លែម្នាប់ផ្កាប់ឱរា នៃករិយាជាទីស្នេហាប្រចក្សដោយភ្នែកខ្លួនឯង ឥតស្ញប់ស្ញែងអាអែងក្រែងទោសពៃរ៍ នឹងកើតមានដល់ព្រះអង្គស្តេច ជាសូរេចដោយនូវប្រការអម្បាលនេះហោង ៗ

## ពន្យល់ពាក្យ

បរមេស្វ (អ.ប.ប៉ះរ៉ះមេស) ន. អ្នកដែលជាធំក្រៃលែង អ្នក

អ្នក

ប្រសើរលើសលុប ។ **ធុរដ្ឋាន** ន. ទីធ្លាយ ។ **ព្រហ្មចារិណី** (អ.ថ. ព្រហ្មៈចារិណី ) ន. ស្ត្រីអ្នកប្រព្រឹត្តព្រហ្មចារ្យ ។ **រាជង្គរក្ស** (អ.ថ. រ៉ក) ន. អ្នករក្សាអង្គព្រះរាជា, ទាហានក្រុមរក្សាព្រះអង្គ ។ **រាជព្រឹត្ត** ន. មារយាទ ឬ សណ្ដាប់ធ្នាប់ព្រះរាជា ។ **បរិសុទ្ធ** គុ. ស្អាតវិសេស, ដែលឥតមោះហ្មង។ **ឱរា** (ក្លាយមកពីឧរា, ម. ឧរ) ទ្រូង (រាជស័ព្ទ) ។

---

## សេចក្ដីសរសើរព្រៃខេមមិគទាយពន

*ព្រៃខេមមិគទាយពន ជាមហាវ័នមានពណ៌ល្អមហិមា គួរជាទីពិតពិលរមិលមើលយល់ល្អស្រស់ពណ្ណរាយជាលំនៅនៃបក្សីផងទាំងឡាយគឺកង់កេងកងប ករវិក កិន្នរ កិន្នរី កំលែង កំបុក ក្ង-ក្ងាន ក្ងោក ក្រួច ក្រៀល ក្អែក; ខ្លុតដី ខ្លែង ខ្លែក, គួក គួលីត គ្រលេង-គ្រលោង គ្រលែងវែក; ចង្កៀលខ្យង ចចាត ចក្រពាក ចាប ប្រៃឡ; ដីវិតដីវាក ជៀចកប្លាស ជ្រីង; ណូរី; តាវៅ ត្មាត ត្របៀកកាំ ត្រដក់ ត្រដេវ ត្រដេវវិច ត្រយង ត្រុំ តុម ត្វា, ទទឹកត្រៃ ទទា ទីទុយ ទុកទ្រូ ទុង ទៀវ ទោម ទម័កខ្វា; បរគាវ ប៉ោលគោក ប្រចៀច ប្រចៀវ ប្រមង់; ពពូល ពាង ព្រហីត ព្រាប*

មានទឹក មាន់ទោរ មៀម, ហោរកក ទោល ក្ទួច រាំងព្រៃ អោក រំពេ, លលក ល្វាបេក ល្អូត; សត្វា សារិកា សេកយារ ស្វាំង ស្មោញ ស៊ិតទៅ ហង្ស អក តទ្រី ឧទ្ឋ ឧទ្ឋុង ៗ ក្នុងភូមិឋាន ទៀតសោតក៏ពាបស៊ើស្ទើរសព្វអន្លើប្រកបដោយនូវស្រះបោក្ខរណី មានធ្លរនោះគ្រង់ កំពង់នោះពាបស្មើអធិកពន្ទឹក មានទឹកជ្រៅជ្រះ គ្រប់ះថ្លា យង់យល់ដ៏ដ៏មានផ្កា កុមុទ សេតុប្បល រត្តុប្បល លំបង់ សត្តបត្ត័ដបត្តុលណី រាគសុសស្គាយ ឆ្ពាស់ពណ៌ល្អនេក ដ៏ប្រដាប់ នូវក្រោលតាវល្ម៉ែផងតាំងឡាយគឺស្វាយ ខ្វិត ក្រសាំង ខ្នុរណាំង ធាយស្រា ភ្លៅ បន្តោ ពទ្រី ដកត កណិការ លំពស់ លំពាន់ ក្រពាន់ ក្រៀលស្វាតារ សៃស្វង កំភ្លង ប្រកៃងនួយ ស្តុកស្តុរ បុស-នាគ សំយាកសំយុង ទ្រង់ទីទៅនូវផ្លែផ្ការយោនរយោន មានមួបត្រឈឹងត្រឈៃ សឹងដុះជាជួររៀងដោយនូវកំពែងថ្នល់មណ្ឌលស្រះ ល្អូតលាស់លំពង់នូវផ្កាយ៉ាងស្រដាស់ ល្អល្អះពណ្ណរាយតាំងពីគល់ដល់ចុង ហាក់ដូចចុងសំយុងព្យួររយោលចុះមកបោលភ្ញៀនពិ-ដោរដុំគ្រអួបឈ្ងុយឈ្ងប់គ្រប់ទិសានុទិស, ជាបើនណាមាន

ទុក្ខអផ្សុកសព្វសាន្តយ៉ាងណាក៏ដោយ ឲ្យតែបានចូលទៅដល់ យល់ព្រៃនោះហើយ សឹងកើតសេចក្តីស្រណុកកាយសប្បាយចិត្ត ក្រៃពេកហោង ។

## ពន្យល់ពាក្យ

**ខេមមិគទាយពន** (អ. ថ. ខេម៉ះមិគះទាយះពន់) ន. ព្រៃដែលឥស្សរជនមានស្តេចជាដើមឲ្យអភ័យដល់ពួកម្រឹគ គឺព្រៃដែលគេហាមប្រាមមិនឲ្យឈ្មោះណាមួយបៀតបៀនពួកម្រឹគដែលនៅអាស្រ័យក្នុងព្រៃ, ពួកសត្វដែលនៅក្នុងព្រៃនោះ បានសេចក្តីសុខក្សេមទាំងអស់ ទើបគេហៅថា ខេមមិគទាយពន ។ **មហាវ័ន** ន. ព្រៃធំ ។ **មហិមា** គុ. ដែលគួរស្ញើម, ដែលសំបើម ។ **ពណ្ណរាយ** (អ. ថ. ពន់ណះរាយ) គុ. ដែលភ្លឺត្រចះ, ដែលមានរស្មីរុងរឿងចាំងព្រោងព្រាយ ។ **បក្សី** ន. សត្វមានស្លាប, សត្វស្លាប ។ **ពោក្ខរណី** ន. ស្រះមានឈូក, ស្រះឈូក ។ **អធិកា** គុ. ដែលលើសលុប, ដែលលើសលន់ពន់ប្រមាណ ។ **កុមុទ** ន. ឈូកក្រហម ។ **សេតុប្បល** (អ. ថ. តុប បុល) ន. ព្រលិតផ្កាស, ព្រលិតស ។ **រត្តុប្បល** (អ. ថ. រ័ត តុប បុល) ន. ព្រលិតផ្កាក្រហម, ព្រលិតក្រហម ។

**សត្តបណ្ណ** (អ. ថ. ស័ត តះ បង់ ណប់) ន. ឈ្មោះឧប្បលមួយយ៉ាង ផ្កាតូច ។ សម្បុរក្រហមព្រាល ។ **ចង្កុលណី** (អ. ថ. ច័ង កុ លណី) ន. ឈ្មោះភិរីជាតិមួយយ៉ាង ក្នុងពួកឈូក ។ **អប្បសាន្ត** (អ. ថ. អប់ ប្បាន) គុ. ដែលមានសេចក្ដីស្ងប់តិច គឺដែលព្រួយចិត្តរសាប់រសល់ខ្វល់ក្នុងចិត្ត ។

# បញ្ជីសៀវភៅរបស់បណ្ណាគារ ជឹង-ង្វួន-ហ្វួត

លេខ ២៣ ខ, វិថីសម្តេចសង្ឃនាយកសុ៊ក ក្រុងភ្នំពេញ គឺ:

| | | |
|---|---|---|
| ១– ពុទ្ធប្រវត្តិពាក្យកាព្យ | ថ្លៃ | ១៧៛០០ |
| ២– ភេសជ្ជក្ខន្ធកៈ ទី៦ | 〃 | ២០៛០០ |
| ៣– ប្រស្នាពុទ្ធសាសនា | 〃 | ៨៛០០ |
| ៤– សុន្ទរកថា | 〃 | ៨៛០០ |
| ៥– យកក់សធម៌ ទនី ច្បាប់ទូន្មានកូនចៅ | 〃 | ៥៛០០ |
| ៦– សំវេគកថា | 〃 | ៤៛០០ |
| ៧– ប្រជុំពុទ្ធភាសិត | 〃 | ៨៛០០ |
| ៨– បញ្ហាសង្គម | 〃 | ១៤៛០០ |
| ៩– បុគ្គលកថា | 〃 | ៥៛០០ |
| ១០– ហិបហោះ | 〃 | ៨៛០០ |
| ១១– សន្និសីទ ស្តីពីសាសនា, បទបញ្ញត្តិ គោលធម៌របស់សាសនា និងការឧបត្ថម្ភព្រះពុទ្ធសាសនា | 〃 | ៥៛០០ |

១២- ប្រស្នាវិន័យបញ្ញត្តិ ទី ១ ថ្លៃ ៨៛០០

១៣- " ទី ២ " ១២៛០០

១៤- ប្រជុំសិក្ខាបទ " ១០៛០០

១៥- សន្ទនាត្រៃភាសាខ្មែរ-បារាំង-យួន " ១៧៛០០

១៦- សរសេរតាមសូត្រ ពន្យល់ " ២៥៛០០

១៧- រឿងម៉ាក់ប៉ាយុនកែវ ទី ១-២-៣ " ១០៛០០

១៨- អន្តរជានកថា " ១០៛០០

១៩- រឿងដាក " ១០៛០០

២០- រឿងព្រះបាទជយវរ្ម័នទី៧ ពាក្យកាព្យ " ៥៛០០

២១- ប្រស្នាកច្ចាយនរូបត្តមក: នាមនិទ្ទេសទី ២ " ២០៛០០

២២- ច្បាប់រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា " ១០៛០០

២៣- ជីវណកថា " ៣៛០០

២៤- អនុពុទ្ធប្រវត្តិ ភាគទី១ " ២៥៛០០

" " ទី២ " ៥៛០០

២៥- បណាមគាថា " ៣៛០០

| | | |
|---|---|---|
| ២៦– អរិដ្ឋកថា | ថ្លៃ | ២២៛០០ |
| ២៧– រឿងបុទ្ធិវង្ស ទី ១-២ | " | ៨៛០០ |
| ២៨– រឿងមើលពន្យល់ថ្នាក់ទី ៦ | " | ២៣៛០០ |
| ២៩– រឿងវរនេត្រវរនុជ ទី ១ | " | ១០៛០០ |
| ៣០– រឿងសុវណ្ណហង្ស ទី ១.២.៣.៤ | " | ១០៛០០ |
| ៣១– ព្រះមហោសថ | " | ១០៛០០ |
| ៣២– សំយោគវិធាន | " | ១៣៛០០ |
| ៣៣– អរិយមគ្គាធិប្បាយ | " | ២៦៛០០ |
| ៣៤– វេយ្យាករណបទីប | " | ៤០៛០០ |
| ៣៥– វត្តក្ខន្ធក ទី ១៨ | " | ៦៛០០ |
| ៣៦– ធម្មវិចារណកថា | " | ១៣៛០០ |
| ៣៧– វិន័យសង្ខេប សិក្ខាបទក្រៅបាតិមោក្ខ | " | ១៥៛០០ |
| ៣៨– អធិប្បាយប្រជុំកងធម៌ពិស្តារ ថ្នាក់ទោ ភាគទី២ | " | ១៨៛០០ |
| ៣៩– បញ្ហាធម្មវិភាគ ថ្នាក់ទោ ភាគទី ១-២ | " | ១៨៛០០ |
| ៤០– ពុទ្ធានុពុទ្ធប្បវត្តិ | " | ២៨៛០០ |

| | | |
|---|---|---|
| ៤១– គោលពុទ្ធសាសន៍ | ថ្លៃ | ២៨រ០០ |
| ៤២– សង្គីតិកថា | " | ១៥រ០០ |
| ៤៣– ប្រស្នាសង្គីតិកថា | " | ១៨រ០០ |
| ៤៤– ពោធិសត្តកថា | " | ១០រ០០ |
| ៤៥– ក្បួនពារសៅរ៍ | " | ៥រ០០ |
| ៤៦– ឥន្ទទំនាយ | " | ៥រ០០ |
| ៤៧– អនុបុព្វីកថា | " | ៨រ០០ |
| ៤៨– ប្រស្នាសង្ឃកម្ម | " | ៧រ០០ |
| ៤៩– បញ្ហាធម្មវិភាគ ថ្នាក់ត្រី ទី២ | " | ១៥រ០០ |
| ៥០– អធិប្បាយសាសនសុភាសិត ថ្នាក់ឯក ទី១ | " | ២០រ០០ |
| ៥១– អំបែងបែក ទី១ | " | ១៦រ០០ |
| ៥២– " ទី២ | " | ១៥រ០០ |
| ៥៣– សេនាសនទាន | " | ៥រ០០ |
| ៥៤– ពុទ្ធប្បវត្តិនិទាន | " | ១៨រ០០ |
| ៥៥– អភិធម្មត្ថសង្គហៈ ពិស្តារ | " | ២៥រ០០ |

| | | |
|---|---|---|
| ៥៦– វេយ្យាករណ៍អក្ខរាវិរុទ្ធខ្មែរ | ថ្លៃ | ១៥៛០០ |
| ៥៧- វិជ្ជាភាសាអង់គ្លេសខ្មែរ | " | ១៨៛០០ |
| ៥៨- អធិប្បាយប្រជុំគន្ធធម៌ ថ្នាក់ត្រី ភាគទី ១-២ | " | ១៨៛០០ |
| ៥៩- អង់គ្លេស-ខ្មែរ | " | ២៨៛០០ |
| ៦០– វេយ្យាករណ៍អង់គ្លេស ភាគ ១ | " | ២៨៛០០ |
| ៦១- ក្បួននពុទ្ធ ភាគ ១ | " | ២៥៛០០ |
| ៦២– " " ២ | " | ៤៨៛០០ |
| ៦៣–គោលតែងសេចក្តី | " | ១៨៛០០ |
| ៦៤– ក្បួននពុទ្ធ ចោទ-ឆ្លើយ | " | ៤៤៛០០ |
| ៦៥– រឿងលិនថោង ភាគ ១-២-៣- | " | ១២៛០០ |
| ៦៦- រឿងពលឯក ទី ១-២-៣ | " | ១០៛០០ |
| ៦៧- ពុទ្ធប្បវត្តិ សន្តិកេនិទាន | " | ១៨៛០០ |
| ៦៨– ប្រស្នា " " | " | ២០៛០០ |
| ៦៩– អភិធម្ម ៧ គម្ពីរសង្ខេប | " | ១៧៛០០ |
| ៧០– លេខសាស្ត្រ | " | ២៨៛០០ |

៧១- សាសនប្រតិបត្តិ ផ្នែកគ្រហស្ថ ថ្លៃ ៣៥៛០០

៧២- ប្រជុំគន្ធធម៌ ថ្នាក់ទោ " ១២៛០០

៧៣- ប្រជុំប្រស្នាគន្ធធម៌ ថ្នាក់ត្រី ភាគ១ " ២២៛០០

៧៤- បញ្ហាធម្មវិភាគ ថ្នាក់ត្រីភាគទី១ " ១៨៛០០

៧៥- រឿងសព្វសិទ្ធិ ថ្នាក់ទី ៤ ទំនើប ១ខ្សែបប់ " ២៥៛០០

៧៦- " ហង្សយន្ត ថ្នាក់ទី ៣ ទំនើប ១ខ្សែបប់ " ២៥៛០០

៧៧- " សុបិន ថ្នាក់ទី ៥ ទំនើប " ១០៛០០

៧៨- ច្បាប់ទូន្មានខ្លួន – ច្បាប់ពាក្យចាស់

ច្បាប់វិធុរបណ្ឌិត ថ្នាក់ទី៣ទំនើប " ៤៛០០

៧៩- ច្បាប់កូនចៅ - ច្បាប់ក្រម - ច្បាប់កេរ្តិ៍កាល

ច្បាប់ត្រីនេត ថ្នាក់ទី៤ទំនើប " ៦៛០០

៨០- ច្បាប់ស្រី · ច្បាប់ប្រុស - ច្បាប់បណ្តាំឪពុក

ច្បាប់ហៃមហាជន, ច្បាប់កូនចៅល្បើក

ថ្នាក់ទី ៥ ទំនើប " ១០៛០០

| | | | |
|---|---|---|---|
| ៨១ – | ពង្សាវតារខ្មែរសង្ខេប | ថ្លៃ | ១៥៛០០ |
| ៨២ – | ភាសា ចិនតាជីវ.ខ្មែរ. យួន | ” | ១០៛០០ |
| ៨៣ – | ចតុព្វិធលេខ | ,, | ១៣៛០០ |
| ៨៤ – | លោកនីតិ | ,, | ១៩៛០០ |

នៅមានបោះពុម្ពសៀវភៅប្លែក ៗ ច្រើនមុខទៀត, ព្រមទាំងមានលក់សៀវភៅបារាំង ប្រដាប់ប្រដាសម្រាប់ គ្រូ-សិស្ស នឹងសំបុត្រ, ក្រដាស, លិខិតផ្សេង ៗ ច្រើនមុខ ៗ បើអស់លោក-អ្នក-នាង ត្រូវការជាវដុំយកទៅលក់ត ខ្ញុំបាទនឹងគិតកាត់រង្វាន់ទុកជូនឲ្យបានគាប់ចិត្ត ។

សូមលោក-អ្នកនាង កុំភ្លេច បណ្ណាគារ ជឹង-ងួន.ហួត លេខ២៣ ខ, វិថីសម្តេចសង្ឃនាយក ស៊ុក ខាងកើតផ្សារធំថ្មី ភ្នំពេញ ។

# សេចក្ដីបញ្ជាក់

ខ្ញុំសូមសំដែងនូវសេចក្ដីអរគុណ ដ៏លើសលុបក្រៃលែង ចំពោះអស់លោក-អ្នក, នាង សិក្ខាកាមទាំងឡាយ ដែលនិយមរាប់អានសៀវភៅ សរសេរតាមសូត្រ-ពន្យល់ នេះ ។ ការដែលអស់លោក អ្នក នាង ទាំងឡាយនិយមរាប់អានសៀវភៅនេះ ឈ្មោះថា ជួយលើកដំកើងនូវអក្សរសាស្ត្រជាតិដោយពិត ព្រោះសៀវភៅនេះ ជាសៀវភៅសម្រាប់សិក្សាភាសាអក្សរសាស្ត្រជាតិឲ្យបានវិសេសឡើង ។

ការបោះពុម្ពលើកទី ៤ នេះ ខ្ញុំបានពិនិត្យដោយផ្ចិតផ្ចង់ជាថ្មី ដើម្បីជៀសវាងកំហុសគ្រប់យ៉ាង កំប៉ុន្តែបើសិនជានៅតែមានភ្លាំងភ្លាត់ ខុសខ្លះដោយអន្លើ ដោយអ្នកធ្វើមិនមានចេតនាសោះនោះ សូមអស់លោក-អ្នក, នាង មេត្តាអភ័យទោស ។

សូមអរគុណ

ជា-ទង់

រោងពុម្ព
អ៊ុក-ហ៊ី-ភុល